# ទស្សនាវដ្ដី កសិកម្ម

# THE AGRICULTURE MAGAZINE




ឆ្នាំទី ១៥ ត្រីមាសទី ១ (មករា-មីនា) ឆ្នាំ ២០១៦ លេខ ៥៧

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

## មាតិកា ទំព័រ


- សុន្ទរកថា**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥ ....................01
- ជំនួយស្មារតីឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបុណ្យដារលាននៅភូមិស្លកភាជ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង....................០៥
- សុន្ទរកថាឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទសន្និបាតកសិករលើកទី៧....................១១
- ចំណាប់អារម្មណ៍ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះសួរសុខទុក្ខកងវរៈសេនាតូចការពារព្រំដែនលេខ៣០៣ ....................១៧
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត....................២១
- ដំណាំឪឡឹក....................៣៧
- ឧបករណ៍ដាំស្រូវជាជួរសម្រាប់បំពាក់គោយន្ត....................៥០
- វិធីសាស្រ្តថ្លឹងស៊ូប៉ាប់ត្រាក់ទ័រ....................៥១
- ការចិញ្ចឹមគោជាលក្ខណគ្រួសារ (តចប់ពីលេខ ៥៦)....................៥៤
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ....................៦១



ម.ឯ.ឯ.ក AIDOC
Code:
Date:
Donated by:

# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥

នៅសណ្ឋាគារសុខាភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៦

- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងអង្គពិធីទាំងមូលជាទីមេត្រី!




*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយ ដោយបានមកចូលរួមនៅក្នុងពិធីបើកវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥ ដែលបានរៀបចំឡើងយ៉ាងឱឡារិកនាពេលនេះ។ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមកោតសរសើរចំពោះសហព័ន្ធស្រូវអង្ករកម្ពុជា ដែលបានសហការជាមួយសហព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំឱ្យមានព្រឹត្តិការណ៍ ដ៏មានសារៈសំខាន់នេះឡើង។ វេទិកាស្រូវអង្ករកម្ពុជានេះ គឺជាឱកាសមួយដែលផ្តល់លទ្ធភាពដល់ភាគីពាក់ព័ន្ធនានា បានផ្លាស់ប្តូរយោបល់ បទពិសោធន៍និងព័ត៌មានផ្សេងៗ ពីគ្នាទៅវិញទៅមក សំដៅស្វែងរកដំណោះស្រាយនូវបញ្ហាប្រឈមនានា ពាក់ព័ន្ធទៅនឹងវិស័យស្រូវអង្ករនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

កន្លងមក លទ្ធផលការងារ នៅក្នុងវិស័យកសិកម្ម ពិសេសការងារបង្កើនផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម សម្រេចបានជោគជ័យគួរជាទីមោទនៈ ដោយសារការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល និងគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសការចូលរួមយ៉ាងសស្រាក់សស្រាំពីបងប្អូនកសិកររបស់យើង។

ខ្ញុំសូមយកឱកាសនេះបញ្ជាក់ថា គោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករដែលរាជរដ្ឋាភិបាលបានដាក់ចេញនៅឆ្នាំ ២០១០ មានគោលដៅធំពីរ គឺ (១). ជំរុញការផលិតស្រូវឱ្យបានច្រើនជាង៤ លានតោន ក្នុងនោះបរិមាណអង្ករ សម្រាប់នាំចេញ ត្រូវសម្រេចឱ្យបានយ៉ាងតិច ១ លានតោន (២). លើកឈ្មោះអង្ករកម្ពុជានៅលើឆាកអន្តរជាតិ ។ ជារួម យើងសម្រេចបាននូវគោលដៅទាំងពីរយ៉ាងត្រចះត្រចង់ដោយកម្ពុជាបាននាំអង្ករទៅកាន់ទីផ្សារនានាលើពិភពលោកជាង ៦០ ប្រទេស ជាមួយគ្នានេះ អង្ករកម្ពុជាត្រូវបានជាប់ជាចំណាត់ថ្នាក់អង្ករឆ្ងាញ់បំផុតលើពិភពលោកជាបន្តបន្ទាប់ ។ ចំណែកគោលដៅទីមួយ យើងសម្រេចបានមួយនិងមួយភាគពីរ ពោលគឺបរិមាណស្រូវដែលលើសតម្រូវការក្នុងស្រុកបានកើនឡើងពី៣លាន៥សែនតោននៅឆ្នាំ២០០៩ មកដល់ ៤ លាន ៧ សែនតោន នៅឆ្នាំ ២០១៥ ។ ចំណែកគោលដៅនៃការនាំចេញ គឺយើងសម្រេចបានពាក់កណ្តាល ដោយនាំចេញអង្ករបានប្រមាណ៥៣ ម៉ឺនតោន នៅឆ្នាំ២០១៥ នៃគោលដៅ ១ លានតោន ។ សរុបមក យើងអាចសម្រេចបានជាង ៨៧,៥០% នៃគោលដៅ ដែលយើងបានដាក់ចេញ ដែលអាចចាត់ទុកបានថាជាលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។

ខ្ញុំសូមឆ្លៀតឱកាសនេះ សម្តែងការកោតសរសើរចំពោះការខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្មពីសំណាក់ស្ថាប័នទាំងអស់ ទាំងជាតិ និងទាំងអន្តរជាតិ ដែលបានរួមគ្នាប្រែក្លាយគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករទៅជាសកម្មភាពជាក់ស្តែង និងទទួលបានលទ្ធផលដ៏ល្អប្រសើរនាពេលនេះ ។ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមកោតសរសើរជាពិសេសចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងផ្នែកផលិតកម្មស្រូវ ក្រសួងពាណិជ្ជកម្មក្នុងផ្នែកនាំចេញអង្ករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងផ្នែកហិរញ្ញប្បទាន

ព្រមទាំងសហព័ន្ធស្រូវអង្ករក្នុងការជំរុញការទទួលស្គាល់ជាអន្តរជាតិ ។ ជាមួយគ្នានេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងអស់ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធទាំងជាតិ និងអន្តរជាតិបានចូលរួមចំណែកធ្វើសកម្មភាពតាមសមត្ថកិច្ចរៀងៗខ្លួនយ៉ាងសស្រាក់សស្រាំ ដើម្បីសម្រេចបានលទ្ធផលប្រកបដោយមោទកៈភាពនេះ ។ ពិសេសបំផុត ខ្ញុំសូមអរគុណដល់កសិករកម្ពុជាដែលខិតខំប្រឹងប្រែងតស៊ូព្យាយាម និងសង្វាត ក្នុងការងារផលិតកម្មស្រូវ ហើយផលិតបានអង្ករដ៏ឆ្ងាញ់សម្រាប់ពិភពលោក ។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥

ទន្ទឹមនេះ ជាមួយនឹងលទ្ធផលដែលយើងសម្រេចបាននៅពេលនេះ កិច្ចការសំខាន់ដែលយើងត្រូវបន្ត គឺការរក្សាលទ្ធផលដែលយើងសម្រេចបានជាមួយនិងការខិតខំស្វែងរកវិធីសាស្ត្រ និងធ្វើសកម្មភាពបន្ថែមទៀត ដើម្បីជំរុញការងារផលិតកម្មស្រូវ និងការនាំចេញអង្ករនៅកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការវិវត្តន៍យ៉ាងលឿននៃស្ថានភាពសកលលោកនាពេលបច្ចុប្បន្ននេះ ។ ប្រសិនបើយើងពិនិត្យឱ្យបានស៊ីជម្រៅបន្តិច ការដែលយើងមិនអាចសម្រេចបាននូវគោលដៅ ដែលដាក់ចេញបានទាំងស្រុងនោះ គឺមានទាំងកត្តាអន្តោម៉ែតផង និងកត្តាសត្យានុម័តផង ។ កត្តាអន្តោម៉ែត ដោយសារយើងនៅមិនទាន់ដោះស្រាយបានគ្រប់គ្រាន់នៅឡើយ លើបញ្ហាប្រឈមមួយចំនួន ដូចជាបញ្ហាការផ្គត់ផ្គង់ទឹក ការប្រើប្រាស់ពូជសុទ្ធបច្ចេកទេសកសិកម្មទំនើប កង្វះទុនបង្វិល ឃ្លាំងស្តុក និងទីផ្សារជាដើម។ ដែលធ្វើឱ្យបរិមាណស្រូវមួយចំនួនត្រូវបាននាំចេញទៅប្រទេសជិតខាង ។ ចំណែកកត្តាសត្យានុម័ត គឺប្រទេសនានានៅក្នុងតំបន់ និងពិភពលោក ក៏ជាប្រទេសផលិតស្រូវដូចកម្ពុជាពិសេសនៅក្នុងប្រទេសបណ្តាមេគង្គ ដូចជា: វៀតណាម ថៃ ឡាវ និងមីយ៉ាន់ម៉ា ដែលនាំដល់ការធ្លាក់ចុះតម្លៃអង្ករ ក្នុងទីផ្សារពិភពលោក ដែលធ្វើប៉ះពាល់ដល់ទីផ្សារអង្ករកម្ពុជាផងដែរ ។





ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥

ក្នុងស្មារតីដោះស្រាយ នៅបញ្ហានេះ ខ្ញុំសូមឱ្យឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិសហការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហព័ន្ធស្រូវអង្ករកម្ពុជា ព្រមទាំងក្រសួងពាក់ព័ន្ធផ្សេងៗទៀត សិក្សាវាយតម្លៃគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដើម្បីធ្វើជាមូលដ្ឋានក្នុងការដាក់ចេញនូវគោលដៅពង្រឹងក្របខ័ណ្ឌគោលនយោបាយនិងសម្រួចវិធានការណ៍បន្ថែមទៀត ។ ជាការពិត កិច្ចការនេះនិងត្រូវសម្របសម្រួលដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** ដើម្បីធានាថា វិធានការណ៍ទាំងអស់មានភាពប្រទាក់ក្រឡាគ្នាបំពេញគ្នាទៅវិញទៅមក និង អនុវត្តទៅបានប្រកបដោយសង្គតិភាព ។





*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងវេទិកាស្រូវអង្ករកម្ពុជាលើកទី ៥*

- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងអង្គពិធីទាំងមូលជាទីមេត្រី !

សម្រាប់វិស័យស្រូវអង្ករ ខ្ញុំយល់ឃើញថា នៅតែជាវិស័យដ៏មានសក្ដានុពលនៅថ្ងៃអនាគត ពីព្រោះតម្រូវការអង្ករដែលជាស្បៀងនេះ និងចេះតែកើនឡើងជាមួយនិងកំណើនចំនួនប្រជាជនក្នុងពិភពលោក ទោះបីជានៅពេលប្រទេសកាន់តែមានចំណូលខ្ពស់ ការបរិភោគអង្ករកាន់តែតិចក្ដី ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជានិងបន្តជំរុញដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ជាមួយនិងការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងកិច្ចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ក្នុងគោលដៅពង្រឹងនូវសមត្ថភាពប្រកួតប្រជែង និងការសម្រួលដល់ធុរជនលើការធ្វើពាណិជ្ជកម្មអង្ករកម្ពុជា ។ ទាក់ទងនិងការជំរុញវិស័យនេះ ខ្ញុំសូមទាញការចាប់អារម្មណ៍លើចំណុចគន្លឹះចំនួនដូចតទៅ ៖

ទី១. ប្រព័ន្ធធារាសាស្ត្រ គឺជាធាតុចូលដ៏ចាំបាច់ក្នុងការធ្វើកសិកម្មៈ ប្រព័ន្ធធារាសាស្ត្ររបស់យើងនៅមិនទាន់គ្របដណ្ដប់លើផ្ទៃដីដាំស្រូវបានធំទូលាយនៅឡើយ ដូច្នេះក្រសួងធនធានទឹក និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទព្រមទាំងអាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋានត្រូវសហការគ្នាក្នុងការបន្តស្ដារ និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងស្វែងរកយន្តការក្នុងការគ្រប់គ្រងទឹកឲ្យមានប្រសិទ្ធភាព ដើម្បីផ្ដល់លទ្ធភាពដល់កសិករក្នុងការធ្វើស្រែបានច្រើនដង ពីមួយដង ទៅពីរដង ឬពីពីរដងទៅបីដងក្នុងមួយឆ្នាំ ។

ទី២. ការលើកស្ទួយម៉ាកអង្ករកម្ពុជានិងការស្វែងរកទីផ្សារជាការចាំបាច់ៈ កន្លងមកអង្ករផ្កាំរំដួលរបស់កម្ពុជាជាប់ចំណាត់ថ្នាក់ជាអង្ករមានគុណភាពល្អបំផុត លើពិភពលោក ៣ ឆ្នាំជាប់គ្នា គឺឆ្នាំ ២០១២ ឆ្នាំ ២០១៣ និងឆ្នាំ ២០១៤ ។ នេះជាឱកាសមួយសម្រាប់កម្ពុជាធ្វើយុទ្ធនាការផ្សព្វផ្សាយនូវកិត្យានុភាពអង្កររបស់យើងនៅក្រៅប្រទេស ។ ក្នុងន័យនេះ សហព័ន្ធស្រូវអង្ករកម្ពុជាត្រូវសហការជាមួយភាគីពាក់ព័ន្ធក្នុងការបង្កើតម៉ាករួមរបស់អង្ករកម្ពុជា ហើយនិងត្រូវចុះបញ្ជីឱ្យបានច្បាស់លាស់ ។ ទន្ទឹមនេះ ត្រូវមានយន្តការត្រួតពិនិត្យឱ្យបានហ្មត់ចត់លើការប្រើប្រាស់ម៉ាក ការក្លែងបន្លំដោយប្រការណាមួយ ។

ទី៣. ការផលិតពូជស្រូវឱ្យបានស្របតាមតម្រូវការរបស់ទីផ្សារៈ ចំណុចនេះ ត្រូវមានភាពស៊ីចង្វាក់គ្នារវាងអ្នកផលិត និងអ្នកកែច្នៃនាំចេញ ទាំងបរិមាណ ទាំងទំហំ និងប្រភេទស្រូវ ។ ភាពមិនស៊ីចង្វាក់គ្នារវាងតួអង្គទាំងអស់នៅក្នុងចង្វាក់ផលិតកម្មនេះ គឺជាមូលហេតុមួយដែលធ្វើឱ្យយើងមានស្រូវលើស ប៉ុន្តែការនាំចេញរបស់យើងនៅមានកម្រិតនៅឡើយ ។ ឧបមាថា កសិករដាំស្រូវជលសារ នាងខុន។ល។ ឯអ្នកនាំចេញ នាំចេញអង្ករផ្កាំរំដួល ដែលធ្វើឱ្យយើងផលិតស្រូវហើយគ្មានទីផ្សារលក់ ឬមានទីផ្សារហើយខ្វះស្រូវកិនឱ្យត្រូវទៅតាមតម្រូវការ ។

ទី៤. ការផ្ដោតលើពូជស្រូវផ្កាំរំដួល ដែលជាពូជមានគុណភាពខ្ពស់ និងមានទីផ្សារៈ យើងគួរជំរុញកសិករក្នុងការដាំដុះពូជនេះ ទៅតាមប្រភេទដីដែលអំណោយផល ។ ប៉ុន្តែស្រូវផ្កាំរំដួលប្រកាន់រដូវ ដែលយើងផលិតបានតែក្នុងរដូវវស្សាមួយដងក្នុងមួយឆ្នាំ ។ ទន្ទឹមនេះ យើងត្រូវបង្កើនការផលិតពូជស្រូវផ្សេងទៀត ដែលមិនប្រកាន់រដូវ ផលិតបានច្រើនដងក្នុងមួយឆ្នាំ និងមានតម្លៃខ្ពស់ជាងអង្ករស ។ យើងមានពូជស្រូវខ្លះជាស្រូវក្រអូប ជាពូជមិនប្រកាន់រដូវ ហើយយើងលក់បានតម្លៃថ្លៃជាងអង្ករសធម្មតា ។ យើងគួរជំរុញការដាំពូជដែលមានលក្ខណៈប្រភេទនេះ ដើម្បីបង្កើននូវអង្ករសសម្រាប់ការនាំចេញ ជាមួយគ្នានេះជួយដល់ការធានានិរន្តរភាពផ្គត់ផ្គង់ និង



*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទស្សនាពិព័រណ៍ផលិតកសិកម្មក្នុងវេទិកាស្រូវអង្ករកម្ពុជា លើកទី ៥*

ដំណើរការ នៃការកែច្នៃរបស់រោងម៉ាស៊ីនឱ្យដំណើរការបានក្នុងកម្រិតអតិបរមានៃសកម្មភាពរបស់ខ្លួន ។

ទី៥. ការផលិតពូជសុទ្ធ ឱ្យបានគ្រប់គ្រាន់ សម្រាប់ការដាំដុះ ពូជគ្រិះដែលផលិតដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍនកសិកម្មកម្ពុជា (CARDI) គួរអនុញ្ញាតឱ្យវិស័យឯកជនផលិតពូជបន្តពីពូជគ្រិះនេះទៅឱ្យកសិករ ។ ស្ថាប័នពាក់ព័ន្ធ ត្រូវសិក្សាលើយន្តការ វាយតម្លៃគុណភាពពូជ ឱ្យបានត្រឹមត្រូវមុននឹងផ្គត់ផ្គង់ចៀសវាងការក្លែងបន្លំគុណភាព ដែលប៉ះពាល់ដល់ទំនុកចិត្តក្នុងការប្រើប្រាស់ពូជ ក៏ដូចជាផលិតផលស្រូវដែលត្រូវរំពឹងទុក ។

ទី៦.ការកាត់បន្ថយថ្លៃដើមជាកត្តាមួយសំខាន់ក្នុងការបង្កើនការប្រកួតប្រជែងសម្រាប់វិស័យស្រូវអង្ករជាមួយប្រទេសដទៃទៀតៈ កន្លងមករាជរដ្ឋាភិបាលបានខិតខំក្នុងការជួយសម្រួលដល់វិស័យស្រូវអង្ករ ដោយសារវិស័យអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់ ដូចជាឥណទានដែលមានការប្រាក់អនុគ្រោះដល់វិស័យស្រូវអង្ករតាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ការសម្រួលកម្រៃមួយចំនួននៅកំពង់ផែ ការអនុគ្រោះពន្ធលើតម្លៃបន្ថែមលើការនាំចូលគ្រឿងយន្ត និងឧបករណ៍កសិកម្ម ដែលបម្រើឱ្យវិស័យស្រូវអង្ករ ការសម្រួលដល់ការនាំចេញតាមរយៈការសុំវិញ្ញាបនបត្រសម្គាល់ប្រភពដើមទំនិញតាមប្រព័ន្ធអនឡាញ និងបញ្ចុះតម្លៃអគ្គិសនី ដែលយើងនឹងចាប់ផ្តើមអនុវត្ត ក្នុងពេលខាងមុខជាដើម ។ លើសពីនេះទៀត យើងក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការស្តារ និងអភិវឌ្ឍផ្លូវទឹក និងផ្លូវដែក ដើម្បីបន្ថយថ្លៃដើម និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ទំនិញរបស់យើងនៅក្នុងទីផ្សារអន្តរជាតិ ។

ទី៧. ឃ្លាំងនិងម៉ាស៊ីនសម្ងួតជាកត្តាចម្បងក្នុងការសម្រួលទិញស្រូវរបស់រោងម៉ាស៊ីនសម្រាប់កម្ពុជាៈ ដូច្នេះយើងត្រូវជំរុញការវិនិយោគបន្ថែមនូវម៉ាស៊ីនសម្ងួត និងឃ្លាំងស្តុក ដើម្បីឱ្យការប្រមូលទិញស្រូវស្តុកបានបរិមាណច្រើនសម្រាប់ការនាំចេញ ។ ករណីនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បាន នឹងកំពុងពិភាក្សាជាមួយភាគីចិនក្នុងការសង់ឃ្លាំងមួយចំនួននៅទូទាំងប្រទេស ដើម្បីដោះស្រាយបញ្ហាកង្វះឃ្លាំង និងម៉ាស៊ីនសម្ងួតនេះ ។

- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និង អង្គពិធីទាំងមូលជាទីមេត្រី !

ជាការពិត កំណើនល្អប្រសើរនៅក្នុងវិស័យកសិកម្ម និងអនុញ្ញាតឱ្យប្រជាជនកម្ពុជា ភាគច្រើនលើសលប់ ដែលប្រកបរបរកសិកម្មទទួលបាននូវផលប្រយោជន៍ពីកំណើននេះ ហើយជីវភាពរបស់ពួកគាត់ក៏នឹងត្រូវបានលើកតម្កើងបន្ថែមមួយកម្រិតទៀតដែរ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលប្តេជ្ញាបន្តជំរុញលើកស្ទួយផលិតកម្មស្រូវ និងដោះស្រាយនៅរាល់ឧបសគ្គនានា ដែលបង្កការលំបាកដល់ការនាំចេញអង្ករពីកម្ពុជា ។ ពិតណាស់ថា ជោគជ័យនៃវិធានការដែលយើងបានដាក់ចេញមកនេះនិងចំណុះទៅលើការអនុវត្តជាក់ស្តែង ហើយកិច្ចការនេះ ទាមទារឱ្យមានកិច្ចសហការ សម្របសម្រួល និងការប្តេជ្ញាចិត្តខ្ពស់ ជាពិសេសត្រូវមានជំហរដឹកនាំ និងសកម្មគ្រប់គ្រងពីសំណាក់ក្រសួង-ស្ថាប័ន និងតួអង្គពាក់ព័ន្ធទាំងអស់ ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួង-ស្ថាប័ន រួមទាំងវិស័យឯកជននិងដៃគូអភិវឌ្ឍ ជាពិសេសប្រជាកសិករកម្ពុជានៅទូទាំងប្រទេសនឹងបន្តចូលរួមចំណែកយ៉ាងសស្រាក់សស្រាំក្នុងបេសកកម្មនេះ ដើម្បីភាពរុងរឿងវឌ្ឍនភាព និងវិបុលភាពនៃព្រះរាជាណាចក្រកម្ពុជាយើង ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ភ្ញៀវជាតិ-អន្តរជាតិទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូណ៌ មានសុភមង្គលក្នុងក្រុមគ្រួសារ និងសូមសម្រេចបានជោគជ័យក្នុងគ្រប់ការងារ និងភារកិច្ចរៀងៗខ្លួន ។

**សូមអរគុណ!**

# ជំនួយស្មារតី
## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែង ក្នុងពិធីបុណ្យដារលាននៅភូមិស្លកករាជ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
## ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៦

### I- សេចក្តីផ្តើម

១ - បដិសណ្ឋារកិច្ច:

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- ឯកឧត្តម  លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង
- ឯកឧត្តម  លោកជំទាវ អស់លោក លោកស្រី មន្ត្រីរាជការ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
- លោកតា លោកយាយ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិ  ជាទីនឹករលឹក !



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបុណ្យដារលាននៅភូមិស្លកករាជ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ*

២ - ថ្ងៃនេះ  គឺជាទិវាដ៏នក្ខត្តឫក្សដែលខ្ញុំព្រះករុណាខ្ញុំមានសេចក្តីសោមនស្សរីករាយបានចូលរួមក្នុងពិធីបុណ្យដារលានប្រពៃណីជាតិដ៏ឱឡារិកនេះ  ដែលបានប្រព្រឹត្តទៅក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអគ្គនាយកដ្ឋានកសិកម្មជាមួយមន្ទីរកសិកម្មនិងអាជ្ញាធរមូលដ្ឋានខេត្តកំពង់ឆ្នាំងនាពេលនេះ។  ស្ថិតក្នុងបរិយាកាសដ៏វិសេសវិសាលនេះ  ខ្ញុំព្រះករុណាខ្ញុំ  សូមថ្លែងអំណរព្រះគុណព្រះតេជគុណ  ព្រះថេរនុថេរៈគ្រប់ព្រះអង្គនិងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម  លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ក្មួយៗសិស្សានុសិស្សព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ដែលបានអញ្ជើញចូលរួមយ៉ាងកុះករ ក្នុងពិធីដ៏មានសារសំខាន់នេះ។

៣- ជាមួយនេះដែរ  ក្នុងនាមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្ត និងខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំព្រះករុណាខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខ និងសេចក្តីនឹករលឹកដ៏ជ្រាលជ្រៅពី **សម្តេចអគ្គមហាសេនាបតីតេជោ  ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង  សម្តេចកិត្តិព្រឹទ្ធបណ្ឌិត  ប៊ុន រ៉ានី ហ៊ុន សែន ប្រគេនចំពោះព្រះករុណាគ្រប់ព្រះអង្គ  និងជូនចំពោះ  បងប្អូនជនរួមជាតិទាំងអស់ដែលមានវត្តមាននៅទីនេះ  សូមជួបប្រទះ  តែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខ និងពលៈ  កុំបីឃ្លៀងឃ្លាតឡើយ។

### II- ខ្លឹមសារ

១- ឆ្លៀតក្នុងឱកាសដ៏ឧដុង្គឧត្តមនេះ ខ្ញុំព្រះករុណាខ្ញុំ សូមពិតពុទ្ធដីកា  និងជម្រាបជូនអង្គពិធីទាំងមូលមេត្តាជ្រាបថា  នៅកម្ពុជា  ស្រូវគឺជាដំណាំស្បៀងជាសារវ័ន្តសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ។ បច្ចុប្បន្ននេះ ផ្ទៃដីស្រែប្រមាណ ៧៥%នៃផ្ទៃសរុប  មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ   ហើយអង្ករកម្ពុជាត្រូវបានចាត់ទុកថាជា  មាស  ស  ដែលមានតួនាទីសំខាន់បំផុតក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ ការកាត់បន្ថយភាពក្រីក្រ  និងការធានាសន្តិសុខស្បៀងដល់ប្រជាពលរដ្ឋ។



ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបុណ្យដារលាន នៅភូមិស្តុកគរាជ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ

ស្ថិតក្នុងបរិការណ៍នេះ ដើម្បីប្រែក្លាយអង្ករឱ្យទៅជា **មាសស** ពិតប្រាកដ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តនូវ ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករនៅឆ្នាំ២០១០ ដែលឯកសារនេះ បានគូសវាសនូវមាគ៌ាយ៉ាងច្បាស់លាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណងដ៏ចម្បង តាមរយៈការអនុវត្តនូវវិធានការគោលនយោបាយធំៗចំនួនបួនគឺៈ (១)-វិធានការពាក់ពន្ធ័នឹងផលិតកម្មស្រូវ (២)-វិធានការពាក់ពន្ធ័នឹងការប្រមូលទិញ និងការកែច្នៃស្រូវ (៣)-វិធានការពាក់ពន្ធ័នឹងប្រពន្ធ័សម្រួលការនាំចេញអង្ករ និង (៤)-វិធានការស្វែងរកទីផ្សារ។ ឆ្លើយតបនឹងគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្រាវជ្រាវ អភិវឌ្ឍន៍ និង បញ្ចេញពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ សមស្របតាមប្រព័ន្ធបរិស្ថានដាំដុះផ្សេងគ្នា និងឆ្លើយតបនឹងតម្រូវការទីផ្សារឱ្យកសិករប្រើប្រាស់ បង្កើនសេវាកម្មអន្តរាគមន៍នានាដើម្បីជួយដល់ការបង្កើនផលិតផលស្រូវតាមរយៈការផ្ទេរបច្ចេកទេសសមស្របដល់កសិករដោយតម្រង់ទិសទៅរកការប្រមូលផ្តុំផលិតកម្មស្រូវដែលជាចំណុចគ្រឹះមួយសំដៅសម្រួលដល់ការផ្គត់ផ្គង់ និងប្រមូលទិញជាលក្ខណៈទ្រង់ទ្រាយធំតាមរយៈសហគមន៍កសិកម្ម និងប្រើប្រាស់យន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីធានាបាននូវការផ្គត់ផ្គង់ ទាំងគុណភាព បរិមាណ និងតម្លៃ។

២- ជាក់ស្តែង ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥ ត្រូវបានបញ្ចប់ជាស្ថាពរហើយ។ ជាទូទៅស្រូវវស្សាទទួលបានផលល្អគ្រប់កន្លែង ដោយសារអំណោយផលពីភ្លៀងចុងរដូវ។ មកទល់ពេលនេះ ការងារប្រមូលផលដំណាំស្រូវរដូវវស្សាឈានជិតដល់បញ្ចប់ទូទាំងប្រទេសហើយ គឺនៅសល់តែខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ ប៉ុណ្ណោះ ទន្ទឹមនឹងនោះ ប្រជាកសិករបានបន្តការធ្វើស្រែប្រាំងនិងស្រូវប្រដេញទឹកយ៉ាងមមាញឹក និងបានប្រមូលផលស្រូវរដូវប្រាំងជាបណ្តើរៗ។ ទោះបីជួបប្រទះគ្រោះរាំងស្ងួតកណ្តាលរដូវវស្សាក៏ដោយ ក៏ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ សម្រេចបានចំនួន៤៧៣.៣៦៥ហត ស្មើនឹង១១៣,៤៣% នៃផែនការ៤១៧.៣២៥ហត លឿនជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា។

៣- នៅឆ្នាំ២០១៥នេះ តាមលទ្ធផលនៃការវាយតម្លៃនិងបូកសរុបបឋម ផ្ទៃដីប្រមូលផលសរុបមានចំនួនជាង២,៩៩៦លានហិកតា(រដូវវស្សា២.៥៣៦.១៩៧ហិកតា+រដូវប្រាំង៥៦០.០៦២ហិកតា=២.៩៩៦.២៥៩ហិកតា) តិចជាងឆ្នាំមុនចំនួន៣២.៥៧៧ហិកតា (ឆ្នាំមុន៣,០២៨លានហិកតា)។ បរិមាណផលប៉ាន់ស្មានសរុបមានចំនួនជាង៩,២២៧លានតោន (ឆ្នាំមុន៩,៣២លានតោន) ដែលមានទិន្នផលជាមធ្យមចំនួន៣.០៨០គីឡូ /ហិកតា (ឆ្នាំមុន៣.០៧៩គីឡូ /ហិកតា)។ ដូច្នេះ បើគិតពីតុល្យភាពស្បៀងរវាងសេចក្តីត្រូវការ និងបរិមាណផលស្រូវទទួលបាន ឃើញថា អាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង៤,៥លានតោន(ឆ្នាំមុនសម្រេចបាន៤,៧លានតោន) និងគិតជាអង្ករប្រមាណជាង២,៩១លានតោន (ឆ្នាំមុនជាង៣,០១លានតោន)សម្រាប់នាំចេញ។

៤- ដោយឡែក បរិមាណអង្ករនាំចេញសរុបក្នុងឆ្នាំ២០១៥ មានចំនួន៥៣៨.៣៩៦តោន គឺកើនឡើងប្រមាណ៣៩,១% ធៀបនឹងបរិមាណនាំចេញនៅក្នុងឆ្នាំ២០១៤ដែលមានតែ៣៨៧.០៦១តោនប៉ុណ្ណោះ។ ពិតមែនតែសន្ទុះនៃបរិមាណនាំចេញអង្ករនៅក្នុងឆ្នាំ២០១៥នេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែយើងនៅមិនទាន់បានសម្រេចតាមទិសដៅនៃផែនការដែលបានកំណត់នៅក្នុងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលនៅឡើយ។ ទោះជាយ៉ាងណា ក៏យើងនៅតែមានមោទកភាពក្នុងនាមជាប្រទេសនាំចេញអង្ករដ៏ក្មេងខ្ចីមួយនៅក្នុងតំបន់។

៥- សូមជម្រាបជូនថា អង្ករក្រអូបប្រណីតពូជផ្ការំដួល/ផ្កាម្លិះ បាននាំចេញទៅកាន់ទិសដៅ៦០ ប្រទេសនៅលើសាកលលោក ក្នុងនោះមានសហភាពអឺរ៉ុបចំនួន២៦ប្រទេស សមាជិកអាស៊ានចំនួន ៤ ប្រទេស និងគោលដៅផ្សេងទៀតចំនួន៣០ប្រទេសដែលមានក្រុមហ៊ុននាំចេញអង្ករចំនួន៨០ក្រុមហ៊ុន។ ពិសេសជាងនេះទៀត ការដណ្តើមបានមកវិញនូវឋានៈជាប្រទេសនាំចេញអង្ករមួយក្នុងតំបន់ រួមទាំងកំណើននៃការនាំចេញអង្ករ និង ជាពិសេសការទទួលបាននូវពានរង្វាន់លេខ១លើពិភពលោក ស្តីពីអង្ករដែលមានគុណភាព រសជាតិឆ្ងាញ់ជាងគេ ចំនួន៣លើកជាប់ៗគ្នាកន្លងមកនេះ ពិតជាមានអត្ថន័យដ៏ធំធេងសម្រាប់ប្រជាជាតិយើងទាំងមូល ហើយដែលមិនអាចផ្តាច់បានពីការចូលរួមយ៉ាងសកម្មពីគ្រប់ស្ថាប័នពាក់ព័ន្ធ ជាពិសេសអ្នកបច្ចេកទេសកសិកម្ម កសិករ និងអ្នកនាំចេញនោះឡើយ។

- **ព្រះករុណាគ្រប់ព្រះអង្គ ជាទីសក្ការៈ**
- **អង្គពិធីទាំងមូលជាទីមេត្រី!**

៦- បុណ្យដារលាន ជាពិធីបុណ្យដែលទាក់ទងទៅនឹងជំនឿសាសនាដែលប្រជាពលរដ្ឋភាគច្រើនជាកសិករ តែងតែប្រកាន់ខ្ជាប់នូវប្រពៃណីនេះ ហើយបាននាំគ្នាប្រារព្ធពិធីបុណ្យផ្សេងៗតាមរដូវកាល ជំនឿ និងធនធាន។ ប្រជាកសិករខ្មែរយើង ក្រោយពីបញ្ចប់ការច្រូតស្រូវ និងបោកបែនរួចរាល់ជាស្ថាពរហើយនោះចាស់ទុំក្នុងភូមិតែងតែជជែកពិគ្រោះយោបល់គ្នា ដើម្បីលៃលកពេលវេលាសមស្របណាមួយអាចធ្វើបុណ្យទានផ្សេងៗ ក្នុងនោះក៏មានការរៀបចំពិធីបុណ្យដារលានផងដែរ។ ជារួមប្រពៃណីបុណ្យដារលាននេះ ត្រូវបានប្រារព្ធឡើងក្នុងគោលបំណងរក្សានូវអត្តសញ្ញាណព្រលឹង ជាតិខ្មែរឱ្យបានគង់វង្ស។

៧- អត្ថន័យនៃពិធីបុណ្យដារលានៈ គឺជាបុណ្យមួយដែលគេធ្វើនៅពេលប្រមូលផលបានរួចរាល់ជាស្ថាពរ។ នៅស្រុកខ្លះគេនិយមហៅថា ពិធីបោសលាន ព្រោះគេត្រូវប្រមូលស្រូវឱ្យអស់រលីងពីទីលាន។ គោលបំណងសំខាន់បំផុតរបស់ពិធីនេះមាន៤ គឺៈ **១-** សុំខមាទោសចំពោះអំពើឆ្គាំឆ្គងជាយថាហេតុទាំងឡាយណាដែលគេបានប្រព្រឹត្តប៉ះពាល់ទៅលើស្រូវ អង្ករដែលជាអ្នកមានគុណប្រៀបដូចជាម្តាយ។ នាសម័យដើមគឺនៅពេលមិនទាន់មានម្សៅ ឬទឹកដោះគោបំបៅទារក ម្តាយមិនអាចឃ្លាតចាកទៅឆ្ងាយ



*ប្រជាកសិករអញ្ជើញចូលរួមក្នុងពិធីបុណ្យដារលាន នៅភូមិស្លកវាជ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ*

ពីកូនជាទារកបានយូរឡើយ។ ប្រសិនបើម្តាយបានទទួលអនិច្ចកម្មដោយប្រការណាមួយនោះ ទារកច្បាស់ជាមិនអាចទ្រាំទ្រជីវិតឱ្យបានរស់នៅតទៅទៀតបានឡើយ។ ក្នុងស្ថានភាពលំបាកលំបិនបែបនេះ អ្នកដែលមើលថែទារកតែងតែដោះស្រាយដោយយកអង្ករទៅបបររំងាស់បញ្ចុកទារកដើម្បីឱ្យមានជីវិតរស់នៅបានរហូតដល់ធំពេញរូបពេញរាង។ ទន្ទឹមនឹងនេះក៏មានការសុំខមាទោសចំពោះព្រះធរណីដូចជាការបន្ទោរបង់ទឹកមូត្រ ឬ ដើរជាន់នៅលើទីវាលស្រែជាដើមព្រោះព្រះធរណីជាប្រភពធ្វើឱ្យស្រូវដុះលូតលាស់។ **២-** រំលឹកគុណចំពោះបុព្វការីជនទាំងឡាយដែលបានខិតខំកាប់គាស់ព្រះធរណីដើម្បីឱ្យគេមានដីស្រែធ្វើ និងរំលឹកគុណដល់ព្រះភិរុណដែលបានបង្អុរមកគ្រប់គ្រាន់ធ្វើឱ្យដំណាំរបស់គេបានដុះលូតលាស់ល្អ ផ្លែផ្កាល្អ។ **៣-** បួងសួង សែនព្រេនដល់ព្រះភូមិ ដែលជាម្ចាស់ទឹកម្ចាស់ដី និងដល់វត្ថុស័ក្តិសិទ្ធិសូមមេត្តាជួយឱ្យកសិករបានសេចក្តីសុខ ជួយឱ្យបានភោគផលស្រូវទៅថ្ងៃមុខច្រើនបរិបូរណ៍ដោយកុំឱ្យមានសត្វល្អិត សត្វកណ្តុរ ឬ ចាបសេកស៊ីបំផ្លាញស្រូវឱ្យសោះ។ **៤-** សម្រាកកំសាន្តកំដរជីវិតក្រោយពេលបំពេញការងារយ៉ាងប្តូរផ្តាច់អស់មួយរដូវកាលកន្លងមកដែលកសិករបានទ្រាំទ្រក្រោមកម្តៅថ្ងៃ និងដំណក់ទឹកភ្លៀងនោះ និងដើម្បីភ្ជាប់មនោសញ្ចេតនាសាមគ្គីភាពរវាងញាតិមិត្តជិតឆ្ងាយទាំងអស់។

៨- ទស្សនវិស័យអំពីបុណ្យដារលានៈ ដោយបុណ្យដារលានជាពិធីមួយដែលប្រជាកសិករនិយមធ្វើជាលក្ខណៈគ្រួសារ អន្តរភូមិ និងអន្តរឃុំ តាំងពីយូរយារណាស់មកហើយ។







*សកម្មភាពទូទៅក្នុងពិធីបុណ្យដារលាននៅភូមិស្ពករាជ ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ*

ម្យ៉ាងទៀតដោយពិនិត្យឃើញថាមានភូមិ ឃុំ ស្រុកមួយចំនួនបានបំភ្លេចចោលនូវពិធីនេះខ្លះហើយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានខិតខំស្រាវជ្រាវគាស់កកាយឡើងវិញដើម្បីផ្សព្វផ្សាយឱ្យប្រជាកសិករបន្តធ្វើបុណ្យដារលានដែលជាទំនៀមទម្លាប់ប្រពៃណីខ្មែរមួយដ៏ល្អផូរផង់ ក្នុងបំណងជួយថែរក្សាមរតកវប្បធម៌ដ៏ប្រពៃរបស់យើង តាំងពីយូរយារណាស់មកហើយនេះ។ ពិធីបុណ្យដារលានបានបង្កប់នូវអត្ថន័យជាច្រើនក្នុងការជំរុញអភិវឌ្ឍន៍វិស័យកសិកម្មដូចជា ការអប់រំឱ្យប្រជាកសិករចេះសន្សំសំចៃ និងស្រឡាញ់ស្រូវឱ្យដូចស្រឡាញ់ម្តាយ និងជីវិតខ្លួនឯងនាំ ឱ្យពួកគាត់ចេះយកចិត្តទុកដាក់ក្នុងផលិតកម្មស្រូវ ជាពិសេសគឺការផ្សារភ្ជាប់ទៅនឹងការកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល ការទុកដាក់ពូជដែលជាកត្តាសំខាន់ក្នុងការបង្កើនទិន្នផល។ ការជួបគ្នាក្នុងពិធីនេះក៏ជាឱកាសសម្រាប់កសិករ អ្នកជំនាញ និងថ្នាក់ដឹកនាំស្វែងយល់ពីគ្នាទៅវិញទៅមក អំពីបទពិសោធន៍ និងបច្ចេកទេសថ្មីៗដើម្បីជំរុញអភិវឌ្ឍន៍វិស័យកសិកម្មឱ្យកាន់តែរីកចម្រើនថែមទៀត ហើយក៏ជាឱកាសដ៏ប្រសើរបំផុតដើម្បីរំលឹកដល់កសិករឱ្យចេះថៃទាំសមិទ្ធផលទាំងអស់ដែលរាជរដ្ឋាភិបាលបានកសាងនិងដឹងគុណជានិច្ចចំពោះរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងឈ្លាសវៃបំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានជួយដល់ប្រជាកសិករដ៏ច្រើនលើសលប់កន្លងមកនេះ ជាពិសេសចំពោះគោលនយោបាយមិនយកពន្ធលើដីស្រែ ការទទួលស្គាល់ និងការពារដាច់ខាតនូវកម្មសិទ្ធិស្របច្បាប់បច្ចុប្បន្នរបស់កសិករព្រមទាំងជំរុញប្រពលវប្បកម្ម និងការសាងសង់ប្រព័ន្ធធារាសាស្ត្រដើម្បីជួយអន្តរាគមន៍ផ្សេងៗ ជូនដល់ប្រជាកសិកររបស់យើងក្នុងការងារបង្កបង្កើនផលឱ្យទទួលបានជោគជ័យ។

៩- ឆ្នាំនេះក៏ដូចជាឆ្នាំមុនៗដែរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំពិធីបុណ្យដារលានក្នុងទឹកដីដ៏សែនត្រជាក់ត្រជុំរម្យនាបំផុតនៅភូមិស្ពករាជ ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងយើងនេះ ដែលមានភូមិសាស្ត្រសមស្របគួបផ្សំនឹងស្មារតីឧស្សាហ៍ព្យាយាមអំណត់ធននឹងការងារដាំដុះរបស់បងប្អូនកសិករនៅទីនេះផង បានធ្វើឱ្យវាលស្រែ ដ៏ធំល្វឹងល្វើយនេះ ក្លាយជាជង្រុកស្រូវសម្រាប់បងប្អូនរស់នៅក្នុងតំបន់ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋក្នុងខេត្តកំពង់ឆ្នាំង និងប្រជាពលរដ្ឋទូទាំងប្រទេសផងដែរ។

១០- ឆ្លៀតក្នុងឱកាសដ៏មានអត្ថន័យនេះ ខ្ញុំព្រះករុណាខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួន ដូចខាងក្រោម ៖

ទី១-ត្រូវជ្រើសរើសប្រភេទពូជស្រូវ ដែលឆ្លើយតបនឹងក្សេត្របរិស្ថាន និងតម្រូវការទីផ្សារ និងយកគ្រាប់ពូជស្រូវសុទ្ធ ល្អមកធ្វើការដាំដុះដើម្បីទទួលបានទិន្នផល







ការអញ្ជើញទស្សនាពិព័រណ៍ផលិតផលកសិកម្មក្នុងពិធីបុណ្យដារលាននៅភូមិស្ពកពាជ ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ

ខ្ពស់ គុណភាពល្អ និងថ្លៃខ្ពស់នៅលើទីផ្សារ។

ទី២-ត្រូវរៀបចំដីស្រែឱ្យបានត្រឹមត្រូវដោយភ្លឺរាស់ឱ្យសព្វល្អ និងកៀរពង្រាបឱ្យស្មើល្អ ដើម្បីបង្កលក្ខណៈងាយស្រួល ដល់ការដាំដុះ ការគ្រប់គ្រងទឹក ការគ្រប់គ្រងដី និងការកម្ចាត់សមាសភាពចង្រៃដើម្បីធ្វើឱ្យដំណាំស្រូវ លូតលាស់ល្អនិងផ្ដល់ទិន្នផលខ្ពស់។

ទី៣-បន្តពង្រឹងការងារអប់រំផ្សព្វផ្សាយ បច្ចេកទេសដល់កសិករឱ្យកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀតតាមគ្រប់មធ្យោបាយដូចជា សាលារៀនស្រែកសិករ វគ្គបណ្ដុះបណ្ដាលខ្លីៗ ការធ្វើបង្ហាញនិងទិវាស្រែ និងចងក្រង កសិករជាសហគមន៍អភិវឌ្ឍកសិកម្ម ដែលងាយស្រួលដល់ការអនុវត្តផលិតកម្មប្រមូលផ្ដុំ និងការស្វែងរកទីផ្សារកសិផល។

ទី៤-តម្រង់ទិសទៅរកការពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្មដើម្បីផលិតក្នុងទ្រង់ទ្រាយធំ ដោយអនុវត្តយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យាដោយស្មោះត្រង់រវាងអ្នកផលិតនិងអ្នកប្រមូលទិញប្រកបដោយសមធម៌ និងតាមគោលការណ៍ "ភូមិមួយផលិតផលមួយ " ឬ "ផលិតផលសម្គាល់ភូមិសាស្ត្រ "។

ទី៥-បន្តជំរុញការសិក្សាស្រាវជ្រាវរិះរកពូជស្រូវផ្ដល់ទិន្នផលខ្ពស់ហើយធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងបច្ចេកទេសកសិកម្មសមស្របដូចជាវិធីសាស្ត្រដាំដុះ ការថែទាំនិងបំប៉នដី កិច្ចការពារដំណាំ និង ការងារប្រមូលផលទុកដាក់ជាដើម។ ម៉្យាងទៀត ត្រូវយកចិត្តទុកដាក់ខ្ពស់ ចំពោះការប្រើប្រាស់ សារធាតុគីមីដូចជាជីគីមីនិងថ្នាំកសិកម្មជាដើម ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចៀសវាងការខាតបង់ថវិកា និងប៉ះពាល់ ដល់បរិស្ថាននិងសុខភាព។

ទី៦-ជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំនេះ ឱ្យបានច្រើនស្របតាមលទ្ធភាពទឹកដែលស្រោចស្រពបាន ដោយអនុវត្តតាមបច្ចេកទេសត្រឹមត្រូវដើម្បីទទួលបានទិន្នផល និងប្រាក់ចំណូលខ្ពស់ សំដៅកាត់បន្ថយការធ្វើចំណាកស្រុកដោយងាកមកបង្កបង្កើនផលក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានខ្លាំងក្លាវិញ។ ពិសេស បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការខិតខំថែទាំដំណាំស្រូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗទៀតដែរ និងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងការប្រើប្រាស់ទឹកឱ្យគត់មត់តាមសារាចរណែនាំលេខ០៩ សរណន ចុះថ្ងៃទី២៣ ខែធ្នូ ២០១៥ របស់រាជរដ្ឋាភិបាលស្ដីពីការចាត់វិធានការថែរក្សាទឹកទុក។

ទី៧-បន្ថែមលើផលិតកម្មស្រូវ ត្រូវជំរុញការងារចិញ្ចឹមសត្វ ចិញ្ចឹមត្រី ការងារដាំដុះដំណាំរួមផ្សំគ្រប់ប្រភេទ និងបន្លែកុំឱ្យដីនៅទំនេរ ជាពិសេសឆ្លៀតប្រើប្រាស់ឱ្យអស់លទ្ធភាពពីសំណើមដីស្រែក្រោយពេលប្រមូលផលស្រូវវស្សារួច។ សូមចូលរួមផងដែរដើម្បីជួយទប់







*សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងពិធីបុណ្យដារលាននៅភូមិស្ដុករាជ ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ*

ស្កាត់បទល្មើសព្រៃឈើ ជលផល ការចិញ្ចឹមត្រីរស់ត្រីឆ្អោ ដោយខុសច្បាប់ ព្រមទាំងការទប់ស្កាត់ភ្លើងឆេះព្រៃ ដែលអាចកើតមានឡើងជាយថាហេតុក្នុងរដូវប្រាំងនេះ។

ទី៨-ត្រូវអនុវត្តបច្ចេកទេសប្រមូលផលនិងក្រោយពេលប្រមូលផលឱ្យបានល្អប្រសើរ រួមទាំងការកំណត់ពេលវេលាច្រូតកាត់ ការហាលសម្ងួត និងការទុកដាក់ឱ្យបានត្រឹមត្រូវដើម្បីកាត់បន្ថយការបាត់បង់ផលស្រូវ និងបង្កើនគុណភាពស្រូវ អង្ករ។

ទី៩- បន្តនូវប្រពៃណីកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងដៃគូអភិវឌ្ឍកសិកម្មនានាឱ្យបានល្អប្រសើរដើម្បីផ្ដល់ព័ត៌មានថ្មីៗស្ដីពីបច្ចេកទេសផលិតកម្មកសិកម្មឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីដោះស្រាយបញ្ហាដែលកសិករជួបប្រទះទាន់ពេលវេលា និងមានប្រសិទ្ធភាព។

១០-ជាមួយនឹងពិធីដ៏មហោឡារិកថ្ងៃនេះ ខ្ញុំសូមអំពាវនាវដល់បងប្អូនប្រជាកសិករនិងអង្គភាពជំនាញពាក់ព័ន្ធទាំងអស់ មេត្តាយកចិត្តទុកដាក់ជំរុញការថែរក្សាគុណភាពស្រូវរដូវវស្សាដែលទើបប្រមូលផលរួចឱ្យបានល្អបញ្ចៀសឱ្យបានពីការបំផ្លាញដោយកណ្ដុរនិងសត្វចង្រៃដទៃទៀត ព្រោះនេះជាលទ្ធផលដែលបងប្អូនយើងទទួលបានដោយការចំណាយទាំងកម្លាំងកាយកម្លាំងចិត្ត ប្រកបដោយក្ដីព្យាយាម មិនខ្លាចនឿយហត់ដោយពុះពារគ្រប់ឧបសគ្គ ក្នុងកំឡុងពេលពេញមួយ រដូវវស្សាកន្លងមក។ ម្យ៉ាងទៀត សូមយកអស់ស្មារតីថែទាំស្រូវប្រាំងដែលកំពុងដាំដុះឆ្នាំនេះឱ្យបានល្អប្រសើរក្នុងទិសដៅបង្កើនទិន្នផល និងលើកកម្ពស់គុណភាពស្រូវ-អង្ករឱ្យកាន់តែល្អប្រសើរ ឆ្លើយតបតាមតម្រូវការទីផ្សារ។

១១- ជាថ្មីម្ដងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និង អរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្មខេត្ត និង អង្គភាពជំនាញដែលបានសហការយ៉ាងជិតស្និទ្ធក្នុងការរៀបចំបុណ្យដារលានដ៏រស់រវើកនិងមានអត្ថន័យដ៏ជ្រាលជ្រៅនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរសព្វសាធុការថ្វាយដល់ព្រះករុណាគ្រប់ព្រះអង្គ និង ជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងជនរួមជាតិទាំងអស់ សូមទទួលនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ - សូមអរគុណ !**

# សុន្ទរកថា
# ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦




*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

**សូមគោរព:**

- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា
- បងប្អូនកសិករ សមាជិក សមាជិកានៃអង្គសន្និបាត ជាទីមេត្រី

១. ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមនៅក្នុងពិធីបិទសន្និបាតកសិករ ទូទាំងប្រទេសលើកទី៧ ជាមួយនឹងឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងបងប្អូនកសិករទាំងអស់ដែលបានអញ្ជើញមកពីរាជធានី ខេត្តទាំង២៥ នៅក្នុងវេទិកាដ៏មានសារៈសំខាន់នេះ។ ខ្ញុំសូមសម្ដែងនូវការកោតសរសើរនិងអរគុណចំពោះឯកឧត្តមរដ្ឋលេខាធិការ **ទី សុគន្ធ** ប្រធានគណៈកម្មការរៀបចំសន្និបាត ព្រមទាំងគណៈមេប្រយោគ ទាំងអស់ដែលបានខិតខំបំពេញភារកិច្ចក្នុងការវាយតម្លៃប្រកបដោយសមធម៌ ដើម្បីជ្រើសរើសកសិករឆ្នើមទូទាំងប្រទេស អស់រយៈពេល២ថ្ងៃកន្លងមកនេះ បន្ទាប់ពីបានដំណើរការជ្រើសរើសកសិករឆ្នើមនៅតាមបណ្ដាមន្ទីរកសិកម្មរាជធានី ខេត្តទូទាំងប្រទេសប្រកបដោយស្មារតីទទួលខុសត្រូវ។ ការរៀបចំសន្និបាតកសិករទូទាំងប្រទេសលើកទី៧នេះ ពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការចូលរួមចំណែករបស់យើងទាំងអស់គ្នានៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចធានាសមធម៌ ធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទនៅកម្ពុជា។

២. ក្នុងព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះ តាមរយៈរូបខ្ញុំផ្ទាល់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** សូមជម្រាបសួរសុខទុក្ខ និងសេចក្ដីនឹករលឹកដ៏ជ្រាលជ្រៅ ជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងបងប្អូនកសិករទាំងអស់ដែលមានវត្តមាននៅទីនេះ និងសូមជូនពរបវរប្រសើរ សូមជួបប្រទះ តែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

៣. ការរៀបចំសន្និបាតកសិករលើកទី៧ ដែលបានប្រព្រឹត្តទៅក្នុងរយៈពេលពីរថ្ងៃកន្លងទៅនេះក៏មិនខុសពីឆ្នាំមុនៗដែរ គឺមានគោលបំណងវាយតម្លៃរាល់សមិទ្ធផល ស្នាដៃ និងគំនិតច្នៃប្រឌិតប្រកបដោយភាពម្ចាស់ការរបស់កសិករឆ្នើម ដើម្បីប្រមូលផ្ដុំនូវបច្ចេកវិទ្យា ការអនុវត្តកសិកម្មល្អ និងនវានុវត្តថ្មីៗ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្ថែម និងធ្វើការផ្សព្វផ្សាយដល់កសិករ និងសហគមន៍កសិកម្មដទៃទៀតនៅក្នុងទូទាំងប្រទេស ជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាបៃតងសមស្រប រួមទាំងប្រព័ន្ធគ្រប់គ្រងធនធាន (Resource Management Systems) ការលើកកម្ពស់ការសម្រួលពាណិជ្ជកម្ម និងការទទួលបានទីផ្សារកសិផលឆ្លើយតបទៅនឹងការបង្កើនភាពធន់ នឹងការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយធម្មជាតិនិងហានីភ័យ



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ផ្សេងៗក៏ដូចជាបទពិសោធន៍ក្នុងការគ្រប់គ្រងកសិដ្ឋានមុខរបររបស់កសិករឆ្នើម និងភាពជោគជ័យនៃការដឹកនាំ និងគ្រប់គ្រងសហគមន៍កសិកម្ម ដោយតម្រង់ចក្ខុវិស័យទៅរកការប្រកួតប្រជែងទាំងបរិមាណនិងគុណភាពក្នុងការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ និយាយរួម គឺការខិតខំជំរុញនូវទំនាក់ទំនងសម្រាប់ការធ្វើផលិតកម្ម និងអាជីវកម្ម ក្នុងខ្សែចង្វាក់តម្លៃកសិកម្ម រវាងតួអង្គបីសំខាន់គឺ កសិករ គ្រួសារកសិករខ្នាតតូច សហគ្រាសខ្នាតតូច និងមធ្យម (SME) ក្នុងនោះមានសហគមន៍កសិកម្ម និងវិស័យឯកជនផងដែរ តាមរយៈការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។

**អង្គសន្និបាតជាទីមេត្រី**

៤. ឆ្លៀតឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃអង្គវេទិកាទាំងមូលមេត្តាជ្រាបថា កំណើនវិស័យកសិកម្ម ពិតជាបានមកពីការចូលរួម ប្រតិបត្តិពីកសិករ គ្រួសារកសិករខ្នាតតូច និងសហគមន៍កសិកម្មដែលជាសហគ្រាសខ្នាតតូច និងមធ្យមមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្ម។ ជាក់ស្តែង ក្នុងឆ្នាំ ២០១៥ កន្លងមកនេះ ទោះបីជាប្រទេសយើងបានទទួលរងនូវបាតុភូតគ្រោះធម្មជាតិ ពិសេសគ្រោះរាំងស្ងួតដែលបានអូសបន្លាយកាលពីដើមរដូវវស្សារយៈពេលយូរក៏ដោយក៏វិស័យកសិកម្មរបស់យើង មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលក្នុងនោះ យើងទទួលបានផលិតផលស្រូវសរុបទាំងប្រាំងនិងវស្សាក្នុងបរិមាណជាង៩,៣៣លានតោន ក្នុងនោះ ស្រូវវស្សាជាង៧,១៧លានតោន ស្រូវប្រាំងជាង២,១៦លានតោន និងទទួលបានទិន្នផលមធ្យម ៣,០៨៥តោន/ហ.ត(ឆ្នាំមុន៣,០៧៩តោន/ហ.ត) និងមានអតិរេកស្បៀងប្រមាណ៤,៦លានតោនស្រូវ ឬគិតជាអង្ករជាង២,៩៧លានតោន(ឆ្នាំមុនជាង៣,០១៣លានតោន)។ ដោយឡែក ការនាំអង្ករចេញឆ្នាំ ២០១៥សរុបចំនួន ៥៣៨.៣៩៦តោន គឺកើនឡើងចំនួន ៣៩,១% បើប្រៀបធៀបឆ្នាំ២០១៤កន្លងមក និងបាននាំចេញទៅកាន់ប្រទេសចំនួន៦៦ នៅលើសាកលលោក។ គិតត្រឹមខែកុម្ភៈឆ្នាំ ២០១៦នេះ ការនាំអង្ករចេញបានជាង ៩២ ពាន់តោន។ ទាំងអស់នេះគឺបានមកពីការចូលរួមអនុវត្ត និងការវិនិយោគពីកសិករ គ្រួសារកសិករខ្នាតតូច សហគមន៍កសិកម្ម រួមទាំងការខំប្រឹងប្រែងពីអង្គភាពជំនាញពាក់ព័ន្ធនានា និងមន្ទីរកសិកម្មរាជធានី ខេត្ត ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ តាមរយៈការអនុវត្តបច្ចេកវិទ្យា នវានុវត្តន៍ថ្មីៗ និងការអនុវត្តកសិកម្មល្អក្នុងផលិតកម្មកសិកម្ម និងខ្សែចង្វាក់តម្លៃកសិកម្ម។

**អង្គសន្និបាតទាំងមូល ជាទីមេត្រី**

៥. អម្បាញ់មិញនេះ ឯកឧត្តម **គង់ ចាន់** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរាយការណ៍អំពីដំណើរការនៃអង្គសន្និបាតកសិករអស់រយៈពេល ២ ថ្ងៃកន្លងមកនេះ ហើយដែលខ្ញុំកត់សម្គាល់ឃើញថា ប្រធានបទទាំង៧ ដែលយើងជ្រើសរើសយកមកធ្វើការប្រឡងប្រជែងនៅពេលនេះ គឺមានចរិកជាបច្ចុប្បន្នភាពផង មានលក្ខណៈសង្គតិភាពទៅនឹងគោលនយោបាយកែទម្រង់ស៊ីជម្រៅ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ ចំពោះកសិករឆ្នើមទាំង ៣៥ រូប ដែលទទួលបានជ័យលាភីនាពេលនេះ គឺបានបង្ហាញពីស្នាដៃពិតប្រាកដរបស់ខ្លួន ដែលគណៈមេប្រយោគបានធ្វើការចម្រាញ់ជាច្រើនលើក ច្រើនសា តាមរយៈការប្រកួតប្រជែង ការចុះពិនិត្យជាក់ស្តែងដល់មូលដ្ឋាន និងការវាយតម្លៃតាមលក្ខណវិនិច្ឆ័យ ចាំបាច់ដែលបានរៀបចំឡើង



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

តាមប្រធានបទនីមួយៗ។ ឆ្លៀតក្នុងឱកាសដ៏មានអត្ថន័យនេះ ខ្ញុំសូមឱ្យអង្គសន្និបាតទាំងមូល មេត្តាយកចិត្តទុកដាក់អនុវត្តលើចំណុចមួយចំនួនដូចតទៅៈ

**ទី១-** កសិករដែលទទួលបានជ័យលាភីត្រូវបន្តពង្រឹង និងពង្រីកទាំងសមត្ថភាព និងបច្ចេកទេសបន្ថែមទៀត ដើម្បីលើកកម្ពស់និងបង្កើនទាំងបរិមាណ និងគុណភាពផលិតផលកសិកម្ម ការធ្វើអាជីកម្ម និងសេវាកម្មកសិកម្ម តាមតម្រូវការទីផ្សារ សំដៅធានាបាននូវសុវត្ថិភាព សុខុមាលភាពសាធារណៈ និងបរិស្ថាន ព្រមទាំងជួយបញ្ជ្រាបនូវបទពិសោធន៍ និងបច្ចេកទេសច្នៃប្រឌិតដ៏ល្អប្រសើរនេះទៅដល់កសិករជិតខាង និងកសិករផ្សេងៗទៀតឱ្យបានទូលំទូលាយ។ កសិករដែលទទួលបានជ័យលាភី និងកសិករឆ្នើមក្នុងការងារផលិតកម្មកសិកម្ម ត្រូវប្រមូលផ្តុំគ្នាចងក្រងទៅជាសហគមន៍កសិកម្ម ដើម្បីការអនុវត្តបទពិសាធន៍ និងបច្ចេកទេសថ្មីៗដែលបានរកឃើញនេះ ឱ្យមានលក្ខណៈប្រទាក់ក្រឡាគ្នា និងប្រមូលផ្តុំឯកទេសកម្មនៃផលិតកម្មកសិកម្ម សម្រាប់បម្រើតម្រូវការទីផ្សារ និងការនាំចេញ។ ទាំងកសិករ និងសហគមន៍កសិកម្ម ត្រូវចេះរៀបចំផែនការផលិតកម្ម និងអាជីវកម្ម ព្រមទាំងត្រូវកត់ត្រាចំណូល ចំណាយ ឱ្យបានត្រឹមត្រូវច្បាស់លាស់ ដើម្បីពង្រឹង និងពង្រីកផលិតកម្ម អាជីវកម្ម និងសេវាកម្មរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត ត្រូវចេះពង្រីកមុខរបរផលិតកម្ម និងអាជីវកម្មកសិកម្មរបស់ខ្លួន ដោយមិនត្រូវពឹងផ្អែកទៅលើមុខរបរតែមួយមុខនោះឡើយ ពោលគឺត្រូវជំរុញការធ្វើពិពិធកម្មកសិកម្មក្នុងកសិដ្ឋានរបស់ខ្លួនឱ្យមានសកម្មភាពរស់រវើកតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មចម្រុះដើម្បីធានាបាននូវសន្តិសុខស្បៀងក្នុងគ្រួសារ ប្រាក់ចំណូល បង្កើតការងារនៅមូលដ្ឋាន រក្សាចីរភាពបរិស្ថាន និងកាត់បន្ថយការធ្វើចំណាកស្រុកឱ្យបានជាអតិបរមា។

**ទី២-** សហគមន៍កសិកម្មដែលទទួលបានជ័យលាភីនាថ្ងៃនេះ ក៏ត្រូវពង្រឹង និងពង្រីកសមត្ថភាពអាជីវកម្ម និងមុខរបរបន្ថែមទៀត ដើម្បីឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ ដោយអនុវត្តទៅតាមច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងសហគមន៍កសិកម្ម ព្រមទាំងត្រូវចែករំលែក បទពិសោធន៍នៃភាពជោគជ័យ លើការងារដឹកនាំ និងគ្រប់គ្រងរបស់ខ្លួនទៅដល់សហគមន៍កសិកម្មដទៃទៀត តាមរយៈមធ្យោបាយផ្សេងៗ ដែលអាចទៅធ្វើបាន ដើម្បីជួយពង្រឹងសមត្ថភាពលើការដឹកនាំ និង គ្រប់គ្រងសហគមន៍កសិកម្មនៅកម្ពុជាឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីផ្តល់ផលប្រយោជន៍ ដល់ប្រជាកសិករនៅជនបទ។

**ទី៣-** ចំពោះបងប្អូនកសិករ ដែលចូលរួមក្នុងអង្គសន្និបាតនេះ ហើយដែលត្រូវបានមន្ទីរកសិកម្មខេត្តជ្រើសរើសជាកសិករឆ្នើមប្រចាំខេត្តរៀងៗខ្លួននោះ ត្រូវបន្តអនុវត្តនូវគំនិតច្នៃប្រឌិតថ្មីៗបន្ថែមទៀតឱ្យបានកាន់តែប្រសើរឡើង និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់កសិករដទៃទៀត។ ជាមួយនេះចំពោះកសិករដែលមិនទទួលបានជ័យលាភីក្តី ក៏ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីចូលរួមប្រកួតក្នុងសន្និបាតកសិករនាឆ្នាំក្រោយៗទៀត។ សូមបងប្អូនចាត់ទុកថាការប្រឡងប្រជែង គឺមានជាប់ និង







*សកម្មភាពផ្ដល់លិខិតសសើរជូនកសិករជ័យលាភី ក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្ដីការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ធ្លាក់ តែវាក៏ជាឱកាសមួយដែលបានផ្ដល់នូវបទពិសោធន៍ដ៏ល្អសម្រាប់ការប្រកួតនៅពេលក្រោយទៀត ហើយបងប្អូនមិនត្រូវនឿយណាយក្នុងការប្រកួតប្រជែងឡើយ ដោយតោងគិតថាបងប្អូនជាកសិករឆ្នើមដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចម្រាញ់បានពីក្នុងចំណោមកសិករ រាប់លាននាក់ ក្នុងទូទាំងប្រទេសទាំងមូល។

**ទី៤-** មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវខិតខំចងក្រងប្រវត្តិរបស់កសិករគំរូ និងសហគមន៍កសិកម្មគំរូ ដែលទទួលបានជោគជ័យក្នុងការអនុវត្តបច្ចេកទេស និងមានជំនាញក្នុងប្រព័ន្ធផលិតកម្មកសិកម្ម និងអាជីវកម្មកសិកម្មនៅក្នុងតំបន់គោលដៅរបស់ខ្លួន ដោយត្រូវរៀបចំជាទិន្នន័យគ្រឹះដើម្បីប្រមូលផ្ដុំចងក្រងបទពិសោធន៍ទាំងនោះសម្រាប់ផ្សព្វផ្សាយដល់កសិករ និងសហគមន៍កសិកម្មផ្សេងៗទៀតឱ្យបានទូលំទូលាយ ព្រមទាំងត្រូវសហការ ជាមួយដៃគូអភិវឌ្ឍន៍កម្មវិធី គម្រោងនានា វិស័យឯកជន រួមទាំងអង្គការជាតិ-អន្តរជាតិនានា រៀបចំវេទិកាជួបជុំ និងពិព័រណ៍ផលិតផល និងសេវាកសិកម្មរបស់កសិករ និង សហគមន៍កសិកម្ម ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ និង រកទីផ្សារសម្រាប់ពួកគាត់ក្នុងគោលបំណង បង្កើនផលិតភាពពិពិធភាវូបនីយកម្ម និង ពាណិជ្ជូបនីយកម្មកសិកម្ម។

**ទី៥-** ត្រូវខិតខំបន្តផ្សព្វផ្សាយគោលគំនិត ស្ដីពីសហគមន៍កសិកម្មដល់ប្រជាកសិករ ដើម្បីជំរុញលើកទឹកចិត្ត ក្នុងការចងក្រង ជាសហគមន៍កសិកម្ម តាមរយៈការរៀបចំជាយន្តការមួយជួយដោះស្រាយបញ្ហាប្រឈម ដែលកសិករជួបប្រទះក្នុងការងារកសិកម្មដូចជាកង្វះខាតបច្ចេកទេសកសិកម្ម ខ្វះខាតធាតុចូលកសិកម្មខ្វះខាតដើមទុនធ្វើកសិកម្ម និងបញ្ហាទីផ្សារ ។ល។ សំដៅបង្កើនប្រាក់ចំណូលពីការងារកសិកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករនៅជនបទ និងកាត់បន្ថយភាពក្រីក្រ។

**ទី៦-** ចំពោះមន្ទីរកសិកម្មរាជធានី ខេត្តណាដែលមិនទាន់បានបង្កើតយន្តការគាំទ្រ និងសម្របម្រួលដល់ការងារអភិវឌ្ឍសហគមន៍កសិកម្មត្រូវខិតខំបង្កើត ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មឱ្យបានឆាប់ដើម្បីអនុវត្តប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ









*សកម្មភាពផ្តល់រង្វាន់ជូនកសិករជ័យលាភី ក្នុងពិធីបិទសន្និបាតកសិករលើកទី៧ ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

លេខ២២០ ប្រក.កសក.ប ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត ដើម្បីជំរុញការងារអភិវឌ្ឍន៍សហគមន៍កសិកម្មឱ្យបានកាន់តែប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។ ត្រូវពង្រឹងនិងពង្រីកសេវាគាំទ្រ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ និងសហគមន៍កសិកម្ម តាមគ្រប់មធ្យោបាយផ្សព្វផ្សាយ ដូចជាការបញ្ជ្រាបនូវបច្ចេកវិទ្យានវានុវត្តន៍ថ្មីៗ និងការអនុវត្តកសិកម្មល្អជាដើម ព្រមទាំងត្រូវជំរុញ និងពន្លឿនការរៀបចំនីតិវិធី និង ការអនុវត្តនូវអនុក្រឹត្យ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យាដើម្បីពង្រឹងការទទួលខុសត្រូវ និងភាពជឿទុកចិត្តគ្នា រវាងភាគីអ្នកផលិត និងភាគីអ្នកទិញ ដោយឈរលើគោលការណ៍ និងយុត្តិធម៌ក្នុងអាជីវកម្ម ផលិតកម្មកសិកម្ម។ ត្រូវជំរុញ និងពង្រឹងការត្រួតពិនិត្យអ្នកចែកចាយ លក់ដូរសម្ភារកសិកម្ម និងអ្នកផ្តល់សេវាគាំទ្រកសិកម្ម ធានាឱ្យមានភាពស្មោះត្រង់ និង មានសីលធម៌ក្នុងមុខរបររបស់ខ្លួន ដើម្បីធានាបានគុណភាពសម្ភារកសិកម្ម និងសុខុមាលភាពសាធារណៈ។

**ទី៧-** ដោយឡែក ការរៀបចំសន្និបាតកសិករឆ្នាំនេះ ក៏បានរកឃើញនូវបទពិសោធន៍ថ្មីៗបន្ថែមទៀត ដែលទុកជាមេរៀនសម្រាប់ធ្វើការវាយតម្លៃទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលយើងទាំងអស់គ្នាត្រូវធ្វើការពិចារណា យកមកឆ្លុះបញ្ចាំង ដើម្បីធ្វើបច្ចុប្បន្នភាពឱ្យបានទាន់ពេលវេលាតាមការវិវត្តន៍ នៃសភាពការណ៍ក្នុងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ក៏ត្រូវពិនិត្យមើលផងដែរក្នុងការប្រឡងប្រជែងនេះ ថាតើនៅមានចំណុចខ្សោយអ្វីខ្លះទៀតដែលមិនបានលើកយកមកបង្ហាញដើម្បីឆ្លុះបញ្ចាំង ធ្វើការកែលម្អ ឱ្យបានគ្រប់ជ្រុងជ្រោយ។ និយាយរួម ការរៀបចំសន្និបាតនេះ ក៏ត្រូវផ្តោតផងដែរ ទៅលើគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិឱ្យបានល្អប្រសើរ។

**ទី៨-** នៅក្នុងរដូវប្រាំងនេះ ខ្ញុំកត់សម្គាល់ឃើញថាមានភ្លើងឆេះព្រៃបានកើតឡើងជាហូរហែនៅតាមខេត្តមួយចំនួនដែលបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរដល់ការបាត់បង់ធនធានព្រៃឈើ និងព្រៃលិចទឹកនាំឱ្យមានវិនាសកម្មនិងការខាតបង់ដល់







*សកម្មភាពថតរូបអនុស្សាវរីយ៍*

សេដ្ឋកិច្ចជនបទ សេដ្ឋកិច្ចជាតិ ធនធានធម្មជាតិ និងបរិស្ថាន។ តាមរយៈអង្គវេទិកានេះខ្ញុំសូមអំពាវនាវដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ អង្គភាពជំនាញក្រោមឱវាទ អាជ្ញាធរថ្នាក់ក្រោមជាតិ ពិសេសបងប្អូនកសិករដែលអញ្ជើញមកពីគ្រប់ខេត្ត និងរាជធានី មេត្តាជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់រូបភាពទៅដល់បងប្អូនកសិករទូទាំងប្រទេស ដើម្បីចូលរួមសហការទប់ស្កាត់ភ្លើងឆេះព្រៃនេះឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ សូមបងប្អូនកសិករទាំងអស់មេត្តារាយការណ៍ និងផ្ដល់ព័ត៌មានឱ្យបានទាន់ពេលវេលា ដើម្បីចូលរួមទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ព្រៃលិចទឹក ការបំផ្លេចបំផ្លាញធនធានធម្មជាតិ រួមទាំងការលួចដឹកជញ្ជូន ផលអនុផលព្រៃឈើ សត្វ ផលិតផលសត្វ និងសម្ភារកសិកម្មផ្សេងៗទៀតដោយខុសច្បាប់នៅតាមច្រកព្រំដែន និងច្រករបៀងនានាផងដែរ។

### អង្គពិធីទាំងមូលជាទីមេត្រី

៦. ជាថ្មីម្ដងទៀត ខ្ញុំសង្ឃឹមថា ដៃគូពាក់ព័ន្ធទាំងអស់នឹងចូលរួមសហការជាបន្តសម្រាប់ឆ្នាំក្រោយៗទៀត ក្នុងន័យធ្វើយ៉ាងណាឱ្យការរៀបចំសន្និបាតកសិករនេះកាន់តែមានប្រសិទ្ធភាព និងធ្វើការកែលម្អនូវចំណុចខ្វះខាតឱ្យបានល្អប្រសើរជាបន្តទៀត។ ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរដោយស្មោះចំពោះគណៈកម្មាការរៀបចំសន្និបាតកសិករទូទាំងប្រទេសលើកទី៧នេះ ដែលមានឯកឧត្តមរដ្ឋលេខាធិការ **ទី សុគន្ធ** ជាប្រធានគណៈកម្មការ និង សហការីដែលបានបំពេញកាតព្វកិច្ចក្នុងការរៀបចំសន្និបាតនេះសម្រេចបានលទ្ធផលជាផ្លែផ្កាប្រកបដោយមោទកភាព។ ជាមួយនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់លោកបណ្ឌិតBang Jin-Ki នាយកអង្គការ KOPIA-កូរ៉េ ដែលបានឧបត្ថម្ភជារង្វាន់លើកទឹកចិត្តដល់កសិករជ័យលាភី។

៧. ជាទីបញ្ចប់ ជាមួយនឹងការប្រកាស បិទសន្និបាតកសិករទូទាំងប្រទេសលើកទី៧ ឆ្នាំ២០១៦នេះ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមថ្លែងអំណរគុណសាជាថ្មី និង សូមប្រសិទ្ធពរជ័យបវរប្រសើរ ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិក សមាជិកាទាំងអស់ ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ នាពេលខាងមុខនេះ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន សិរីសួស្ដី វិបុលសុខគ្រប់ប្រការ និងសម្រេចបានជោគជ័យក្នុងភារកិច្ចថ្មីៗបន្តទៀត កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# ចំណាប់អារម្មណ៍
# ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះសួរសុខទុក្ខកងវរៈសេនាតូចការពារព្រំដែនលេខ៣០៣

ខេត្តកោះកុង ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦

**សូមគោរព:**

- ឯកឧត្តម ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈប្រតិភូអមដំណើរ
- ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកោះកុង
- ឯកឧត្តមមេបញ្ជាការយោធភូមិភាគទី៣
- ឯកឧត្តម លោក លោកស្រី នាយទាហាន និងពលទាហានគ្រប់លំដាប់ថ្នាក់ជាទីនឹករលឹក !



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីចុះសួរសុខទុក្ខ កងវរៈសេនាតូចការពារព្រំដែនលេខ៣០៣*

១. ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមសាកសួរសុខទុក្ខ ឯកឧត្តម លោក លោកស្រី មេបញ្ជាការ មេបញ្ជាការរង នាយទាហាន ពលទាហាន និងក្រុមគ្រួសារកងទ័ពទាំងអស់នៅក្នុងកងវរៈសេនាតូចការពារព្រំដែនគោក លេខ៣០៣ នាពេលនេះ ដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ១៥ សសរ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការរៀបចំចងក្រងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ពជាមួយស្ថាប័ន អង្គការសង្គមស៊ីវិល។ ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ ឯកឧត្តម លោក លោកស្រី នាយទាហាន ពលទាហានគ្រប់លំដាប់ថ្នាក់ ដែលបានអញ្ជើញចូលរួម យ៉ាងកុះករក្នុងព្រឹត្តិការណ៍ដ៏មានអត្ថន័យនេះ។

២. ជាមួយនេះ តាមរយៈរូបខ្ញុំផ្ទាល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** សូមជម្រាបសួរសុខទុក្ខ និងសេចក្តីនឹករលឹកដ៏ជ្រាលជ្រៅ ជូនចំពោះនាយទាហាន នាយទាហានរង ពលទាហាន និងក្រុមគ្រួសារកងទ័ពនៅក្នុងកងវរៈសេនាតូចការពារព្រំដែនគោកលេខ៣០៣ ទាំងអស់ដែលមានវត្តមាននៅទីនេះ និងសូមជូនពរបវរប្រសើរ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

៣. យើងទាំងអស់គ្នាបានជ្រាបរួចហើយថា បន្ទាប់ពីប្រទេសជាតិយើងបានឆ្លងកាត់នូវទុក្ខវេទនា វិនាសអន្តរាយ មហាសោកស្តាយ ដែលមិនអាចបំភ្លេចបាន ដោយសាររបបប្រល័យពូជសាសន៍ និងសង្គ្រាមដ៏ជូរចត់រាប់ទសវត្សកន្លងមកនេះ យើងទាំងអស់គ្នាកំពុងស្ថិតនៅក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដ៏ឆ្នើម និងឈ្លាសវៃបំផុត បានបង្ហាញឱ្យសាធារណៈមតិជាតិ និងអន្តរជាតិបានឃើញយ៉ាងប្រត្យក្សថា កម្ពុជាបានបើកនូវទំព័រថ្មីមួយទៀតដែលកំពុងដើរតាមមាគ៌ាប្រជាធិបតេយ្យ អហឹង្សា គោរពនូវសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់គ្នាទៅវិញទៅមក ហើយព្រួតដៃគ្នាដើម្បីអភិវឌ្ឍប្រទេសជាតិមាតុភូមិ ពង្រឹងសន្តិសុខ និងស្ថេរភាពនយោបាយដែលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការប្រកបរបរចិញ្ចឹម



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងពិធីចុះសួរសុខទុក្ខ កងវរៈសេនាតូចការពារព្រំដែនលេខ៣០៣*

ជីវិតប្រចាំថ្ងៃ និងការរស់នៅដោយសុខដុមរមនារបស់បងប្អូនប្រជាជនយើង។

៤. ឆ្លៀតក្នុងឱកាសដ៏មានអត្ថន័យនេះ ខ្ញុំសូមអនុញ្ញាតរំលឹកជូនថា សម្តេចតេជោនាយករដ្ឋមន្ត្រីបានពុះពារគ្រប់ឧបសគ្គដើម្បីស្ថាបនាកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ស្តីពីដំណោះស្រាយនយោបាយរួមនៅកម្ពុជារួមទាំងគោលនយោបាយ ឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាលផងនោះ កងយោធពលខេមរភូមិន្ទ ត្រូវបានបង្កើតឡើងលើមូលដ្ឋាន នៃការបង្រួបបង្រួម កងកម្លាំងប្រដាប់អាវុធនៃភាគីអនុវត្តកិច្ចព្រមព្រៀង។ ជាប្រវត្តិសាស្ត្រ កម្ពុជាបានស្ថិតក្នុងស្ថានភាពមិនមានការបែងចែកទឹកដីគ្រប់គ្រងដោយនិន្នាការផ្សេងៗគ្នា។ តួនាទីរបស់កងយោធពលខេមរភូមិន្ទនៅពេលនេះ មិនត្រឹមតែការពារទឹកដីកម្ពុជា អធិបតេយ្យភាពថ្លៃថ្លា អារ្យធម៌អង្គរដ៏បវររបស់យើងក៏ដូចជាការចូលរួមបង្ក្រាបនូវរាល់អំពើភេរវកម្ម និងសកម្មភាពបង្កអសន្តិសុខផ្សេងៗប៉ុណ្ណោះទេ ក៏ប៉ុន្តែកងយោធពលខេមរភូមិន្ទនៅមានកាតព្វកិច្ចដ៏ចម្បងក្នុងការធានាការពារឱ្យបាននូវសុវត្ថិភាព ស្ថេរភាពខាងនយោបាយ ការពាររដ្ឋធម្មនុញ្ញ និងរាជរដ្ឋាភិបាលបច្ចុប្បន្នដែលប្រសូតចេញដោយសុទ្ធសាធ ពីឆន្ទៈរបស់ប្រជាជនកម្ពុជាទូទាំងប្រទេស។

៥. ក្រៅពីភារកិច្ចស្នូលដូចបានរៀបរាប់ខាងលើ ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរដោយស្មោះចំពោះកងយោធពលខេមរភូមិន្ទដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិ ជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនគ្រប់ច្រកល្ហក ដើម្បីជួយកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាល ជាអាទិ៍ ការចូលរួមទប់ស្កាត់បានជាមូលដ្ឋាននូវរាល់បទល្មើសអនាធិបតេយ្យនានាលើវិស័យព្រៃឈើ ជលផល ការអភិរក្សធនធានធម្មជាតិ អំពើរត់ពន្ធខុសច្បាប់ផ្សេងៗ ជាពិសេសទៅទៀត បានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងការជួយដោះមីន ដើម្បីរំដោះដីស្រែជូនប្រជាជន ជួយសង្គ្រោះប្រជាជនពីគ្រោះមហន្តរាយផ្សេងៗដូចជា គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ជំរុញការងារបង្កបង្កើនផលរបស់ប្រជាកសិករ ដែលជួបការលំបាកលំបិនឱ្យទទួលបានផ្លែផ្កាប្រកបដោយមោទកៈភាព។

៦. ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូនថា គោលនយោបាយកសិកម្ម របស់រាជរដ្ឋាភិបាល គឺផ្តោតទៅលើការលើកស្ទួយតួនាទីរបស់ផ្នែកកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចផ្តល់នូវថាមពលបន្ថែម ដល់កំណើនសេដ្ឋកិច្ច និងអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។ នៅក្នុងទិសដៅនេះ រាជរដ្ឋាភិបាល និងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចជាតិ បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំងធានាសន្តិសុខស្បៀង សម្រាប់ប្រជាពលរដ្ឋទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញកសិផល។ អនុលោមតាមយុទ្ធសាស្ត្រនេះ និងក្នុងកំឡុងទសវត្សរ៍ចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាយើងបានបោះជំហានទៅមុខយ៉ាងច្រើន ក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ តាមការអង្កេតចុងក្រោយក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ អត្រានៃភាពក្រីក្របានធ្លាក់ចុះយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់។ គួររលឹកផងដែរថា នៅឆ្នាំ ១៩៩៤ អត្រានៃភាពក្រីក្រមានប្រមាណ៤៧%។ បច្ចុប្បន្ននេះអត្រានៃភាពក្រីក្របានធ្លាក់មកនៅ១៨% នៅឆ្នាំ២០១៤ មានន័យថា អត្រានៃភាពក្រីក្របានធ្លាក់ចុះប្រមាណជាជាង១% ក្នុងមួយឆ្នាំស្របតាមការរំពឹងទុករបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណា យើងទទួលស្គាល់ថា តំបន់ខ្លះនៅមានការខ្វះស្បៀងនៅឡើយក្នុងកម្រិតសហគមន៍ និងកម្រិតគ្រួសារ



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រគល់អំណោយក្នុងពិធីចុះសួរសុខទុក្ខកងវរៈសេនាតូចការពារព្រំដែនលេខ៣០៣*

ដោយសារការដាំដុះរបស់ប្រជាកសិករនៅពឹងផ្អែកលើធម្មជាតិច្រើននៅឡើយ ការប្រើឧបករណ៍ ប្រើគោ ក្របីជាកម្លាំងអូសទាញ ប្រើប្រាស់ពូជស្រូវប្រពៃណី និងការផ្សព្វផ្សាយបច្ចេកទេសពុំទាន់ត្រូវបានធានា។ ជារួមសមិទ្ធផលទាំងអស់នេះ គឺជាផ្លែផ្កានៃសន្តិភាព និងនយោបាយកែទម្រង់របស់រដ្ឋ ព្រមទាំងស្មារតីប្រឹងប្រែងរបស់ប្រជាជននិងកងទ័ព។ ម្យ៉ាងទៀត កសិកម្មជាវិស័យយុទ្ធសាស្ត្រដ៏សំខាន់នៃរបរចិញ្ចឹមជីវិតរបស់ប្រជាជនក្រីក្រ ហើយជំហាននៃការរីកចម្រើនមិនទាន់ស្មើគ្នា មានឆ្នាំខ្លះផលិតកម្មបានធ្លាក់ចុះដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ធ្ងន់ធ្ងរជាដើម។

**អង្គពិធីទាំងមូលជាទីមេត្រី**

៧. នៅក្នុងដំណើរចុះសាកសួរសុខទុក្ខកងទ័ព និងក្រុមគ្រួសារកងទ័ពកន្លងមករហូតដល់ចុងឆ្នាំ២០១៥ នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជួយកសាងផ្លូវចាក់បេតុង គិលានដ្ឋាន សាលារៀន ផ្តល់សម្ភារ និងថវិកាសរុបចំនួន ៣៣៧,២៥៤,១០០ រៀល (បីរយសាមសិបប្រាំពីរលាន ពីររយហាសិបបួនពាន់មួយរយរៀលគត់) និងប្រាក់ដុល្លារអាមេរិកចំនួន៥៣៥,២៤០ដុល្លារអាមេរិក(ប្រាំរយសាមសិបប្រាំពាន់ពីររយសែសិបដុល្លារអាមេរិក)។ នេះសបញ្ជាក់ឱ្យឃើញថាសមរភូមិក្រោយតែងតែយកចិត្តទុកដាក់ជួយឧបត្ថម្ភសមរភូមិមុខជានិច្ចទាំងសម្ភារ និងថវិកាជួយគាំទ្រលើកទឹកចិត្តដល់កងកម្លាំងប្រដាប់អាវុធរបស់យើងដែលកំពុងឈរជើងប្រចាំការការពារបូរណភាពទឹកដីយ៉ាងអង់អាចក្លាហាន នៅក្នុងភូមិសាស្ត្រទទួលខុសត្រូវជាពិសេស នៅព្រំប្រទល់ជាមួយប្រទេសថៃឱ្យកាន់តែមានកម្លាំងចិត្ត និងភាពកក់ក្តៅថែមទៀត។

៨. ដើម្បីរួមចំណែកជួយជំរុញទិសដៅរបស់រាជរដ្ឋាភិបាលឱ្យទទួលបានជោគជ័យប្រកបដោយក្តីសង្ឃឹម និង សុទិដ្ឋិនិយមនោះ ជាពិសេស ដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាកសិករក៏ដូចជាបងប្អូនកងទ័ពផង ខ្ញុំសូមឆ្លៀតយកឱកាសដ៏មានសារៈសំខាន់នេះ លើកឡើងជាទស្សនៈមួយចំនួនដើម្បីធ្វើការពិចារណាដូចតទៅ៖

**ទី១**- កន្លងមករាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ឱ្យកងយោធពលខេមរភូមិន្ទ អនុវត្តការដាំកូនឈើចូលរួមរក្សា និងការពារធនធានធម្មជាតិឱ្យបានគង់វង្ស ដើម្បីជាផលប្រយោជន៍យូរអង្វែង សម្រាប់ប្រទេសជាតិមាតុភូមិយើង និងសូមអំពាវនាឱ្យបន្តនូវប្រពៃណីដ៏ប្រសើរនេះតទៅទៀត។ សូមយកចិត្តទុកដាក់អនុវត្តនូវបទបញ្ជាក៏ដូចជាសេចក្តីសម្រេចផ្សេងៗរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម ជាពិសេសបទបញ្ជាលេខ ០១ ប.ប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ ដើម្បីបង្ក្រាបឱ្យទាន់ពេលវេលា នូវបទល្មើស និងត្រៀមជួយប្រជាពលរដ្ឋពេលជួបគ្រោះមហន្តរាយផ្សេងៗជាយថាហេតុ។

**ទី២** ពាក្យចាស់បានពោលថា " **ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ** " បានន័យថា កងទ័ពនិងកសិកររួមជាមួយនឹងមន្ត្រីកសិកម្មត្រូវសហការគ្នាជាលក្ខណៈត្រីកោណធ្វើការផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និងបណ្តាញព័ត៌មានផ្សេងៗស្តីពីវិស័យកសិកម្មគ្រប់ផ្នែក ដោយបង្កើតឡើងនូវគំនិតផ្តួចផ្តើមថ្មីៗ ការផ្សព្វផ្សាយបច្ចេកទេសថ្មីដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុ ការធានាអនុវត្តបច្ចេកទេសផលិតកម្ម ការអនុវត្តកសិកម្មសមស្របឱ្យបានល្អប្រសើរ ដើម្បីបង្កើននូវផលិតភាពកសិកម្មតាមរយៈការធ្វើកសិកម្មចម្រុះ និង ផលិតស្បៀងប្រកបដោយគុណភាព និងសុវត្ថិភាព។

ទី៣ សូមបន្តចូលរួមក្នុងការស្ដារ និង កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ទំនប់ទឹក ប្រឡាយ បោសសម្អាតមីន ដើម្បីរួមចំណែកបញ្ចៀសគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជនផង និង ការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋយើងផង។ ស្ថាប័នទាំងពីរ ដែលបានរៀបចំជាគណៈកម្មការរួចហើយ ត្រូវយកចិត្តទុកដាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីអនុវត្តនូវអនុសាសន៍របស់ **សម្ដេចនាយករដ្ឋមន្ត្រី** ឱ្យទទួលបានជោគជ័យប្រកបដោយផ្លែផ្កា និងមោទកៈភាពនិងប្រែក្លាយចំណងសម័ន្ធមេត្រីភាពនេះឱ្យក្លាយជាគំរូភាពតាមការរំពឹងទុក និង ក្លាយទៅជាវប្បធម៌ សម្រាប់ជំនាន់ក្រោយៗទៀត។

ទី៤ នៅក្នុងរដូវប្រាំងនេះ ខ្ញុំកត់សម្គាល់ឃើញថា មានភ្លើងឆេះព្រៃ បានកើតឡើងជាហូរហែ នៅតាមខេត្តមួយចំនួនដែលបង្កឱ្យមានបញ្ហាដ៏ធ្ងន់ធ្ងរដល់ការបាត់បង់ធនធានព្រៃឈើ និងព្រៃលិចទឹកនាំឱ្យមានវិនាសកម្ម និងការខាតបង់ដល់សេដ្ឋកិច្ចជនបទ សេដ្ឋកិច្ចជាតិ ធនធានធម្មជាតិ និងបរិស្ថាន។ ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ អង្គភាពជំនាញក្រោមឱវាទ អាជ្ញាធរថ្នាក់ក្រោមជាតិ ពិសេសបងប្អូនកងទ័ពទាំងអស់ មេត្តាជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់រូបភាពទៅដល់បងប្អូនកសិករទូទាំងប្រទេស ដើម្បីចូលរួមសហការទប់ស្កាត់ភ្លើងឆេះព្រៃនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ សូមបងប្អូនគ្រួសារកងទ័ពទាំងអស់មេត្តារាយការណ៍ និងផ្ដល់ព័ត៌មានឱ្យបានទាន់ពេលវេលាដល់សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចូលរួមទប់ស្កាត់ ការកាប់បំផ្លាញព្រៃឈើ ព្រៃលិចទឹក ការបំផ្លេចបំផ្លាញធនធានធម្មជាតិ រួមទាំងការលួចដឹកជញ្ជូនផលអនុផលព្រៃឈើ សត្វ ផលិតផលសត្វ និងសម្ភារកសិកម្មផ្សេងៗទៀតដោយខុសច្បាប់នៅតាមច្រកព្រំដែន និងច្រករបៀងនានាផងដែរ។

**អង្គពិធីទាំងមូលជាទីមេត្រី**

៩. ជាថ្មីម្ដងទៀត ខ្ញុំសូមកោតសរសើរ ចំពោះថ្នាក់ដឹកនាំនៃកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ ដែលកន្លងមកបានយកចិត្តទុកដាក់ខ្ពស់ចំពោះដំណើរការហ្វឹកហ្វឺនអប់រំនិងបំប៉នគុណភាព សមត្ថភាព និងសីលធម៌ ដល់កងកម្លាំងយោធាមិនមែន ក្នុងទិសដៅឧត្ដមភាពយោធាទេ តែក្នុងទិសដៅលើកកម្ពស់ កងកម្លាំងប្រដាប់អាវុធ ឱ្យក្លាយជាកម្លាំងមួយដ៏ស្អាតស្អំ និងស្មោះត្រង់ចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ និងទៅជាអ្នកការពារប្រជាជន ការពារច្បាប់ និងសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ជាពិសេសបានសហការយ៉ាងពេញទំហឹងក្នុងបេសកកម្មទប់ស្កាត់នូវបទល្មើសផ្សេងៗក្នុងវិស័យកសិកម្ម ក៏ដូចជាជួយជំរុញការងារបង្កបង្កើនផលរបស់ប្រជាកសិករយើង ស័ក្តិសមស្របនឹងពាក្យថា " **ទីណាមានការលំបាក ទីនោះមានមុខកងទ័ព** "។

១០. ក្នុងនាមដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមសម្ដែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលសម្រេចបានក្នុងរយៈពេលកន្លងមករបស់អង្គភាពកងវរៈសេនាតូចការពារព្រំដែនគោកលេខ ៣០៣ ដែលបានបំពេញបេសកកម្មដ៏ឧត្ដុងឧត្ដមក្នុងការការពារអធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយការប្ដេជ្ញាចិត្តខ្ពស់ ឆន្ទៈមោះមុត វិន័យថ្លៃថ្នូរ ស្មារតីស្នេហាជាតិ និងការតស៊ូអត់ធ្មត់អង់អាចក្លាហាន ដោយឈរជើងយ៉ាងរឹងមាំ ត្រៀមការពារទឹកដីយើង ជាពិសេសតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។

១១. ជាទីបញ្ចប់ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមថ្លែងអំណរគុណសាជាថ្មី និងសូមប្រសិទ្ធពរជ័យ បវរប្រសើរ ជូនឯកឧត្ដម លោក លោកស្រី នាយទាហាន នាយទាហានរង ពលទាហាន និងក្រុមគ្រួសារកងទ័ពនៅក្នុងកងវរៈសេនាតូចការពារព្រំដែនគោកលេខ ៣០៣ ទាំងអស់ ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ នាពេលខាងមុខនេះ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន សិរីសួស្ដី វិបុលសុខគ្រប់ប្រការ និងសម្រេចបានជោគជ័យក្នុងភារកិច្ចថ្មីៗបន្តទៀត កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**របាយការណ៍**
**ស្ដីពី**
**សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត**

## I- សភាពការណ៍រួម

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្នុងការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ក្នុងត្រីមាសទី១ឆ្នាំ២០១៦នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្រោមកិច្ចការសហការយ៉ាងជិតស្និទ្ធ ជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការជំរុញ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងដែលមកដល់ពេលនេះគឺ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបានចំនួន៤៨៩.៤៥៥ហ.ត ស្មើនឹង ១១៧,២៨% នៃផែនការ៤១៧.៣២៥ហ.ត។ ចំពោះមុខ ក្រសួងនៅតែបន្តចាត់វិធានការជំរុញការអប់រំណែនាំ និងផ្សព្វផ្សាយដល់ប្រជាកសិករឲ្យធ្វើកសិកម្មចម្រុះបន្ថែមទៀត នៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងថែទាំសុខភាពសត្វដើម្បីការពារជំងឺសត្វដែលអាចកើតឡើងជាយថាហេតុនៅក្នុងរដូវប្រាំងនេះ ព្រមទាំងសហការទប់ស្កាត់បទល្មើសចលនាសត្វផងដែរ។

សកម្មភាពគួរកត់សម្គាល់មួយទៀត គឺមន្ត្រីជំនាញរដ្ឋបាលព្រៃឈើបានសហការជាមួយគណៈកម្មការជាតិចូលរួមទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើតាមស្មារតីនៃសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦។ ដោយឡែក អធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ក្រោមកិច្ចសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិទាំង២៥ខេត្ត-រាជធានី បានចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើព្រមៗគ្នាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ល្បឿនការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៥-២០១៦

ផ្ទៃដីអនុវត្តបានសរុបចំនួន៤៨៩.៤៥៥ហិកតា ស្មើនឹង១១៧,២៨ភាគរយ នៃផែនការ៤១៧.៣២៥ហិកតា តិចជាងឆ្នាំមុនចំនួន១.៤៨៤ហិកតា ក្នុងនោះ ការងារប្រមូលផលស្រូវសម្រេចបានចំនួន៤៨៩.៤៥៥ហិកតា តិចជាងឆ្នាំមុនចំនួន១.៤០៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន២.១៦៤.៦០០តោន តិចជាងឆ្នាំមុនចំនួន១៦.២៩៦តោន និងទិន្នផលជាមធ្យមចំនួន៤,៤២២តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន២១គីឡូក្រាមក្នុងមួយហិកតា(ឆ្នាំមុនទទួលបានទិន្នផលគិតជាមធ្យម៤,៤៤៣តោនក្នុងមួយហិកតា)។

១

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 - 217 320

### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៧៨.៩៥៩ហិកតា ស្មើនឹង១៨៤,៩២%នៃផែនការ៤២.៦៩៨ហិកតា លើសឆ្នាំមុនចំនួន៤.០៥៦ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១៣.០២២ហិកតា ស្មើនឹង៦៤,០៥%នៃផែនការ២០.៣៣១ហិកតា តិចជាងឆ្នាំមុនចំនួន១.០៥០ហិកតា។

### ១.៣ ការនាំចេញអង្ករ

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជារយៈពេល៣ខែដើមឆ្នាំ២០១៦នេះ មានបរិមាណចំនួន១៦២.២២០តោន ដែលមានការកើនឡើងចំនួន១២.៧៥៦តោន(+៨,៥%) លើសបរិមាណនាំចេញរយៈពេល៣ខែដើមឆ្នាំ២០១៥ ដែលមានតែ១៤៩.៤៦៤តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែមីនានេះមានចំនួន៦៦.២៧៥តោន ដែលមានការថយចុះ៩.៥៩២តោន(-១៤,៥%) តិចជាងខែមីនា ឆ្នាំ២០១៥ និងបាននាំចេញទៅកាន់ទិសដៅចំនួន៤៧ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១(៣៧.១១៨តោន) ប្រទេសបារាំងឈរលំដាប់ទី២(២០.៩៩៦តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣(១៨.២១២តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៤(៨.៣០៧តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៥(៨.២១០តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៦(៧.៩៥៦តោន) ប្រទេសឆេកឈរលំដាប់ទី៧(៦.៥៧៦តោន) ប្រទេសបែលហ្ស៊ិក ឈរលំដាប់ទី៨(៥.៨៩៧តោន) ប្រទេសហុងគ្រីឈរលំដាប់ទី៩(៥.៨៣៥តោន) និងប្រទេសអ៊ីតាលីឈរលំដាប់ទី១០(៥.៥១៧តោន) ។

## ២ ផ្នែកកៅស៊ូ

សម្រាប់ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.១២៩ដុល្លារក្នុងមួយតោន។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ ដោយគិតតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូដូចខាងក្រោមៈ

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង១.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ៥០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី១.០០០តែទាបជាង២.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ១៥០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី២.០០០តែទាបជាង៣.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ២០០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី៣.០០០តែទាបជាង៤.០០០ដុល្លារអាមេរិកក្នុង១តោន
- ជាប់អាករនាំចេញ ៣០០ដុល្លារអាមេរិកក្នុង១តោន បើតម្លៃគិតអាករនាំចេញចាប់ពី៤.០០០ដុល្លារអាមេរិកក្នុង១តោនឡើងទៅ។

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥០៨ | ៧៥៧ | ១៥៣ | ១៥០ |
| | **សរុប I** | **៥០៨** | **៧៥៧** | **១៥៣** | **១៥០** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨ | ១៦.០២៨ | ៤.៩៥៤ | ៣.១៥១ |
| ២ | ក្រុមហ៊ុន ស៊ីហ្សាប៉េប៊ើលីមីធីត (រតនគិរី) | ៧៩ | ២.៤៩៨ | ៣២៦ | - |

៣

| | | | | | |
|---|---|---|---|---|---|
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២.១០១ | ៣២០ | ៣០៨ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.១១១ | ៥.១២១ | ១.២៧៤ | ៩៧១ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៩ | ៨.៦៦១ | ១.០៣៦ | ៥៦៦ |
| ៦ | ក្រុមហ៊ុន ស្វីហ្សវីសសស់ (ស្នួល) | ១.៧៤៥ | ៤.៣៦៥ | ៦៣៧ | ៥៨២ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប(ពាមជាំង,មាសហៅក) | ១.៨៨២ | ៣.៣៩០ | ១៧៦ | - |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.៣២៧ | ៥.៩២៤ | ២២៨ | - |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦ | ៥.៧៣១ | ១.៥៧១ | ៦៩៨ |
| សរុប II | | ២៨.២៧៧ | ៥៣.៨១៩ | ១០.៥២២ | ៦.២៧៦ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៥.៧៣៥ | ១៨៤.២៥២ | ៣.២៨៤ | ៣.២៨២ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៦.៤៩៦ | ១៤៩.៨៥៣ | ១៩.៣៥០ | ១៧.៨៥០ |
| សរុប III | | ៨២.២៣១ | ៣៣៤.១០៥ | ២២.៦៣៤ | ២១.១៣២ |
| សរុប I+II+III | | ១១១.០១៦ | ៣៨៨.៦៨១ | ៣៣.៣០៩ | ២៧.៥៥៨ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍អន្តរជាតិលើកទី១៤ជាមួយ International Rubber Association (IRA) ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់ចំពោះកៅស៊ូ TSR(Technically Specified Rubber)
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន៣០ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកៃច្នៃរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង និងកៅស៊ូសន្លឹក
- វាស់ទំហំដើមកៅស៊ូសម្រាប់បើកមុខចៀរថ្មី និងរៀបចំសម្ភារៈបំពាក់ដើមបានចំនួន៨.៦៨៦ដើម នៅលើចម្ការដាំឆ្នាំ២០០៩
- ត្រួតពិនិត្យទិន្នន័យចម្ការពិសោធន៍ IRAE09 និង IRAE10 សម្រាប់សរសេរ Paper ដើម្បីចូលរួម IRRDB 2016
- វាស់ទំហំដើមចម្ការពិសោធន៍ដីលើកៅស៊ូផ្តល់ផលចម្ការពិសោធន៍ CM-2005, IC2005, CM-2006
- បន្តបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូ និងដឹកនាំនិស្សិតសរសេរសារណាបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មកំពង់ចាម និងសាលាជាតិកសិកម្មព្រែកលៀប។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៣.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត រៀបចំឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។
- **ការងារឡជីវឧស្ម័ន៖** ដោយមានការអភិវឌ្ឍផ្នែកចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តន៍

៣៤

យ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្ដាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន៣៧១ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបានចំនួន២៥០ឡ។

- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** បន្តធ្វើសួនដំណាំចំណីសត្វ ការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ នៅតាមបណ្តាខេត្តមួយចំនួនក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT។

## ៣.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖**

ខេត្ត-រាជធានីចំនួន១៧ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន១៥.៥០៧លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ ក្រុមអន្តរាគមន៍របស់អង្គភាពជំនាញបានធ្វើការឃាត់ចាប់បទល្មើសដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វបានចំនួន៥៩គ្រឿង ស្មើនឹង១៣ករណី និងរឹបអូសផលិតផលខូចគុណភាពបានចំនួន១២៧,៦គ.ក្រ ព្រមទាំងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន៧លាន៤សែនរៀល ដោយបានធ្វើការណែនាំឲ្យមានលិខិតបញ្ជាក់អនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រឹមត្រូវ នៅពេលដឹកជញ្ជូនលើកក្រោយៗទៀត ដើម្បីការពារការឆ្លងរាលដាលនៃជំងឺឆ្លងសត្វផ្សេងៗ មកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានជាប្រចាំឱ្យស្របតាមលក្ខណៈបច្ចេកទេសព្រមទាំងបន្តផ្សព្វផ្សាយច្បាប់ ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។
- ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន១៤២កន្លែង ដូចមានតារាងខាងក្រោម៖

| ល.រ | ឈ្មោះខេត្ត-ក្រុង | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាដ | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១១ | | | | | |
| ២ | កណ្ដាល | ២២ | | ១.០១៥ | ០ | ៨.០៧៥ | ១៦៤.៥០០ |
| ៣ | កំពង់ស្ពឺ | ១១ | | ១.៩៧៣ | ០ | ៨.៥៣០ | |
| ៤ | ព្រៃវែង | ១២ | | ៨៧៦ | ៨ | ៩.០៨៩ | |
| ៥ | ស្វាយរៀង | ០៨ | | ៤៧២ | ០ | ៤.៦៣៥ | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ០៦ | | ២២៤ | ១១ | ១.៧៩៤ | |
| ៨ | បាត់ដំបង | ១៤ | | ២.៥៩០ | ៩៤ | ១១.៤៦៤ | |
| ៩ | បន្ទាយមានជ័យ | ១០ | | ៥៣៣ | | ៣.១៥៣ | ២.៩៥០ |
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | | | | |
| ១២ | ព្រះសីហនុ | ៣ | | ២២១ | ១៤ | ២.៤៨០ | ៣៤.៥០០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | កែប | ១ | | | | | |
| ១៤ | កំពត | ៥ | | ៧៦៨ | ០ | ៦.៦១៣ | ២.៩៤០ |
| ១៥ | កោះកុង | ៣ | | ៣៧ | ២៣ | ២.៦៣៩ | ៥.៥៣២ |
| ១៦ | ក្រចេះ | ៥ | | ៤៨៦ | ១៩ | ២.៨៣២ | |
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | ១៧៧ | ១០៥ | ៩៨៧ | |
| ១៩ | មណ្ឌលគិរី | ២ | | | | | |
| ២០ | ប៉ៃលិន | ១ | | ៧៥ | | ៧០០ | |
| ២១ | ឧត្តរមានជ័យ | ១ | | ៧១០ | | ៤.៣៥៩ | ៣.៩០០ |
| ២២ | តាកែវ | ០ | ១៨ | ១.២៣៨ | ០ | ៩.៥២៥ | |
| ២៣ | កំពង់ចាម | ០ | | ៥៣២ | | ៣.៨២៣ | |
| ២៤ | ត្បូងឃ្មុំ | ០ | | ១.២០០ | ២៤ | ៦.៣២៩ | |
| ២៥ | ព្រះវិហារ | ០ | | | | | |
| | សរុប | ១៤២ | ១៨ | ១៣.៨៧៧ | ២៩៨ | ៩០.២៦៥ | ២១៤.៣២២ |

**៣.៣ ការងារស្រាវជ្រាវ៖**

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្ដាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្ដែងក្នុងត្រីមាសទី១ ឆ្នាំ២០១៦នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន១.៨៤៥វត្ថុវិភាគ។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១៦០ក្បាល ក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣២ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤៨ក្បាល គោកំផែងសែន៤៣ក្បាល គោកើតថ្មីចំនួន១ក្បាល និងគោងាប់ចំនួន៣ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិន មានជ្រូកសរុប១៨៨ក្បាល ក្នុងនោះជ្រូកបាចំនួន៤ក្បាល ជ្រូកមេ៥៧ក្បាល កូនជ្រូក៩០ក្បាល មេជ្រូកត្រៀមលក់ចំនួន ៤៥ក្បាល កូនជ្រូកលក់១០០ក្បាល កូនជ្រូកងាប់ចំនួន២៥ក្បាល ជ្រូកថែមថ្មីចំនួន៤៣ក្បាល និងជ្រូកបម្រុងចំនួន១៤ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៣.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្ដី បន្តរៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្ដាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើ

- ចុះពិនិត្យផ្ទៀងផ្ទាត់ប្រភេទព្រៃដើម្បីកសាងផែនទីកាបូនព្រៃឈើនៅខេត្តពោធិ៍សាត់ បាត់ដំបង មណ្ឌលគិរី រតនគិរី និងខេត្តកោះកុង ចំនួន១២០ចំណុច

- សម្របសម្រួលនិងរៀបចំកិច្ចប្រជុំលើកទី៣ ប្រចាំឆ្នាំ២០១៥ របស់គណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើជាតិដែលគាំទ្រពីអង្គការដៃគូរួមមាន JICA, NTFP-EP, RECOFTC, NGO Forum, MB, DPA, Harvest, WCS, SCW, ADB, UNDP Winrock WWF។

### ៤.២ ការងារអភិរក្សសត្វព្រៃ

- តំបន់អភិរក្សជីវចម្រុះវ៉ុនសៃ-សៀមប៉ាង អាងត្រពាំងថ្ម តំបន់អភិរក្សសត្វខ្សឺប និងព្រៃការពារសីមា បានទទួលភ្ញៀវទេសចរណ៍បរទេសមកទស្សនាចំនួន៥០៧នាក់

- ធ្វើការអង្កេតកត់ត្រាសត្វស្លាបប្រចាំខែនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤ (អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដោយបានរកឃើញសត្វស្លាបចំនួន២០៦ប្រភេទ ប្រហែល៧២.២២០ក្បាល

- ចុះប្រមូលទិន្នន័យ ប្រមូលសំណាកជំងឺសត្វកណ្ដុរដែលស្ថិតនៅភូមិអូរចារ ឃុំស្រែព្រះ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ជាលទ្ធផលប្រមូលបានសំណាកសរុបចំនួន៥១០សំណាក ពីសត្វកណ្ដុរចំនួន៥៣ក្បាល

- ចុះប្រមូលសំណាកសរុបចំនួន១.៣៨៣សំណាក ទៅលើសត្វប្រចៀវ-ជ្រូងចំនួន៤៦១ក្បាល ដើម្បីធ្វើការពិនិត្យទៅលើការបន្តពូជ ការយកឈាម លាមក ទឹកមាត់ ទឹកនោម វាស់ប្រវែងស្លាប និងវិភាគរកមេរោគ។ ម្យ៉ាងវិញទៀតក្រុមការងារបានធ្វើជំរឿនសត្វជ្រូងនៅស្រុកកោះធំ ខេត្តកណ្ដាល ដោយរាប់ឃើញប្រហែល៦.០៦២ក្បាល

- ផ្តល់ចំណីឲ្យសត្វត្មាតនៅស្ទឹងត្រែង ក្រចេះ និងតំបន់ព្រៃការពារសៀមប៉ាង ដោយរាប់ឃើញត្មាតសរុបចំនួនប្រមាណ៨០ក្បាល

- ធ្វើការការពារសម្បុកសត្វត្រដក់តូចចំនួន១១សម្បុក សត្វត្មាតចំនួន១០សម្បុក រំពេទន្លេចំនួន៧សម្បុក ក្រយ៉ងចង្កំក ស ចំនួន៣៦សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងសៀមប៉ាង។ ការពារសម្បុកសត្វដើម្បីធានាសុវត្ថិភាពពងកូន ពីព្រោះសម្បុកសត្វទាំងនេះងាយរងគ្រោះដោយសារការប្រមូលរបស់មនុស្ស និងការបំផ្លាញរបស់សត្វព្រៃ ហើយប្រភេទសត្វទាំងនេះជាប្រភេទសត្វជិតផុតពូជ

- បានរៀបចំផែនការសកម្មភាពអភិរក្សខ្លាធំនៅកម្ពុជា ២០១៦-២០២៦ រួចរាល់ជាស្ថាពរ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបន្ដាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺៈ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន២៦៨ក្បាល សត្វកើតថ្មីចំនួន២០ក្បាល ព្យាបាលសត្វចំនួន១៩៨ក្បាល ដោះលែងចូលព្រៃធម្មជាតិវិញចំនួន១៤០ក្បាល ជួសជុលផ្លូវចំនួន៣៩.៩៤០ម$^{2}$ ជួសជុលទ្រុងសត្វចំនួន៣៤៥ម$^{2}$ សាងសង់ទ្រុងនិងសំណង់ផ្សេងៗចំនួន១.៩០០ និងកាប់ឆ្ការអនាម័យព្រៃចំនួន១៦.៤៥៣ម$^{2}$

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្ដាមចំនួន៥៥.៣០៩ក្បាល និងនាំចេញកូនស្វាក្ដាមជំទង់ចំនួន១.៤០៩ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ បានធ្វើការឈូសឆាយដីទំហំ៤២ហិកតា និងបណ្ដុះកូនឈើបានចំនួន១០០.០០០ដើម

- ស្ថានីយផ្សព្វផ្សាយ និងស្ដារទីជម្រាលក្បាលឆាយខេត្តព្រះសីហនុ បានធ្វើការឈូសឆាយដីទំហំ១២៩ហិកតា និងបណ្ដុះកូនឈើបានចំនួន១០០.០០០ដើម

- ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើយុនរាម ខេត្តសៀមរាប បានឈូសឆាយដីទំហំ១០ហិកតា និងបណ្ដុះកូនឈើបានចំនួន១៥០.០០០ដើម

- ស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចម្ការឈើទូទាំងប្រទេស ដែលមានផ្ទៃដីសរុបទំហំ២.១៩៣ហិកតា បាន និងកំពុងពង្រឹងការយាមល្បាតដើម្បីទប់ស្កាត់ការកាប់រុករាន ទន្ទ្រាន ហ៊ុមព័ទ្ធ កាន់កាប់ដីព្រៃឈើ និងទប់ស្កាត់ភ្លើងឆេះព្រៃ

- បណ្ដុះកូនឈើគ្រប់ប្រភេទបានចំនួន៣៥៤.១៩១ដើម និងចែកជូនប្រជាពលរដ្ឋដាំបានចំនួន៥៨.៤៧៩ដើម

៦

- ក្រុមហ៊ុន ស៊ីងបាយអូថេក ជាដៃគូសហការដាំឈើជាមួយរដ្ឋបាលព្រៃឈើនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើបឹងចារ បានធ្វើការឈូសឆាយសម្អាតដីចំនួន២៥០ហិកតា

- ចុះប្រមូលសំណាកដើមប្រេងខ្យល់នៅតាមបណ្តាឡូត៍គំរូនៅតាមខេត្តមួយចំនួននៅតំបន់ឆ្នេរដូចជា ខេត្តតាកែវ កំពត ព្រះសីហនុ និងខេត្តកំពង់ស្ពឺ។ ជាលទ្ធផល បានប្រមូលសំណាកសត្វល្អិត L.invasa ចំនួន ១០សំណាកពីចម្ការប្រេងខ្យល់ក្នុងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ហើយបានរក្សាទុកក្នុងថង់ប្លាស្ទិច

- លោកស្រី Madaline មកពីសាកលវិទ្យាល័យ SUNSHINE COAST នៃប្រទេសអូស្ត្រាលី មកធ្វើការបណ្តុះបណ្តាលស្តីពីការវិភាគនិងការកំណត់អត្តសញ្ញាណ និងវិធីសាស្ត្រប្រមូលប្រភេទសត្វល្អិតផ្សេងៗដែលមានវត្តមាននៅក្នុងចម្ការប្រេងខ្យល់ និងការដុះតាមផ្លូវជាតិសំខាន់ៗ និងដំឡើងម៉ាស៊ីន Microscope ដែលអាចថតសត្វល្អិតជាមួយក្រុមការងាររបស់នាយកដ្ឋានអភិវឌ្ឍចម្ការព្រៃដាំ និងព្រៃឯកជន។ ក្រៅពីការបណ្តុះបណ្តាលនៅក្នុងនាយកដ្ឋាន ក្រុមការងារក៏បានចុះអនុវត្តផ្ទាល់ក្នុងការប្រមូលផលសំណាកសត្វល្អិត L.invasa និងសត្វល្អិតផ្សេងៗដែលមានវត្តមាននៅលើដើមប្រេង-ខ្យល់នៅតាមផ្លូវជាតិលេខ១ ពីភ្នំពេញទៅខេត្តស្វាយរៀង។ ជាលទ្ធផល ក្រុមការងារបានប្រមូលសំណាកសត្វល្អិត L.invasa ចំនួន១៩សំណាក(ពងនិងសត្វល្អិតដង្កូវនៅលើស្លឹក)។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តជូនក្រុមហ៊ុន និងអតិថិជនសរុបចំនួន៣៩គ្រឿង

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ជូនក្រុមហ៊ុនចំនួន៥ និងអតិថិជន៣នាក់ ដែលមានឈើហ៊ីបមូលចំនួន៦.៨៥៨ម³ ឈើអារចំនួន១.០០៤ម³ ឈើជ្រុងចំនួន១៤២ម³ កូនឈើចំនួន៩២.៧២៥ដើម អុសចម្រុះចំនួន២៨.៤៥៣ស្ទែរ ជ័រទឹកចំនួន៧០៥តោន ពកបេងចំនួន៥៥៨គ.ក្រ និងផ្តៅចំនួន២,៥តោន

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន១ក្រុមហ៊ុន គឺក្រុមហ៊ុនGREEN ISLAND AGRICULTURAL DEVELOPMENT(CAMBODIA)Co.,LTD នៅខេត្តក្រចេះ

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាចំនួន២ក្រុមហ៊ុន ដែលមានរានទេវតាចំនួន១.៥៥០គ្រឿង ស្មើនឹងចំនួន៥៦ម³ និងអនុផលព្រៃឈើ(ជ័រទឹក)ចំនួន១៥៩តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលចំនួន២ក្រុមហ៊ុន ដែលមានបរិមាណឈើ TALIWOOD និង CHANFUTA ចំនួន៤៤៤ម³

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ៦.៨២៧.២១៨.១២១រៀល និងចំណូលពីសេវាសាធារណៈចំនួន៩១៤.១១៩.៣០២រៀល និង៤៩.៦៦១,០៣ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន៣៩១ករណី ដោយបញ្ជូនទៅតុលាការចំនួន២៩៩ករណី និងពិន័យអន្តរការណ៍ចំនួន៩២ករណី

- ឃាត់ខ្លួនជនជាប់ចោទបានចំនួន៦នាក់ និងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៦.១៣៦ម³ ឈើអារចំនួន៣.៩៣៧ម³ ឈើក្រាក់គ្រញូងចំនួន១៣ម³ និង៥២៥គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៤២៦ក្បាល និង៧៦១គ.ក្រ អនុផលព្រៃឈើ ព្រមទាំងសម្ភារៈផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៥៥៩ហិកតា ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងដកហូតរណារយន្តចំនួន៣០គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

៧

- ស្រង់ព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលបានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន២៣៦ករណី ដែលការចុះផ្សាយនេះឆ្លុះបញ្ចាំងពីចំណុចវិជ្ជមានផង និងអវិជ្ជមានផងដែរ និងបានផ្ញើជូនខណ្ឌរដ្ឋបាលព្រៃឈើធ្វើការបំភ្លឺមានចំនួន៦៦ករណី

- សហការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ។ ដោយឡែក ក្រុមការងារទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើនៃអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤បានខិតខំចុះល្បាត រុករកបទល្មើសព្រៃឈើនៅតាមខេត្ត-រាជធានីយ៉ាងសកម្ម ក្រោមកិច្ចសហការជាមួយកងកម្លាំងប្រដាប់អាវុធតាមបណ្តាខេត្តនីមួយៗ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ជាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន១.០៥០តោន ស្មើនឹង៨,៧៥% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២៣៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ សរុបចំនួន៦៨.០០០តោន ស្មើនឹង១៩,៧៧% នៃផែនការ៣៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១៧.២៥០តោន

- នេសាទគ្រួសារតាមវាលស្រែ សរុបចំនួន១៨.០០០តោន ស្មើនឹង១២,៥០% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៥.១៥៥តោន

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តសរុបចំនួន២៣. ៨៥០តោន ស្មើនឹង២០,២១% នៃផែនការ១១០.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា សរុបចំនួន២៥.៥៥០តោន ស្មើនឹង១៤,៧៩% នៃផែនការ១៧២.៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២០តោន

- ការចិញ្ចឹមក្រពើ សរុបចំនួន១៧.៣៥០ក្បាល ស្មើនឹង១០,៩៩% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២.៣៥០ក្បាល

- ការភ្ញាស់កូនត្រីពូជ សរុបចំនួន៣២.០០០.០០០កូន ស្មើនឹង១៧,៧៨% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន៥.០០០.០០០កូន

- បន្តធ្វើការសិក្សាស្រាវជ្រាវដោយអនុវត្តបច្ចេកទេសសមស្របអំពីទិដ្ឋភាព និងស្ថានភាពនៃការចិញ្ចឹមត្រីរស់និងត្រីឆ្តោ។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ សរុបចំនួន១៧.២០០តោន ស្មើនឹង២០,៩៨% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៣០០តោន

- ផលនេសាទសមុទ្រ សរុបចំនួន២.៥២៥តោន ស្មើនឹង៣១,៥៦% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន២២៥តោន

- ការផលិតទឹកត្រី សរុបចំនួន១០.០០០.០០០លីត្រ ស្មើនឹង២១% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៣,៥០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ សរុបចំនួន២.៥៨០តោន ស្មើនឹង១៧,២០% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន២៧០តោន

៨

- ផលនេសាទកែច្នៃ សរុបចំនួន១.៥២០តោន ស្មើនឹង៣០,៤០% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន១៣០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន៧៥៨ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន៧៣៤ករណី និងសមុទ្រចំនួន២៤ករណី បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៦៩ករណី ក្នុងនោះ បទល្មើសសមុទ្រចំនួន២៤ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុង និងសាច់អួនប្រវែង១៨៤.៤៣៧ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន៣១.២៥៨មាត់ បង្គោល/ចម្រឹងចំនួន១១៧.០៦៥ដើម ឧបករណ៍ឆក់ត្រីចំនួន១០១គ្រឿង សម្រាស់ចំនួន៥៨.៨៩០ម៉ែត្រក្រឡា របាំងព្រួលប្រវែង៩៣២ម៉ែត្រ និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៣២.២៤២គ.ក្រ

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន២២វគ្គ ដោយមានអ្នកចូលរួមចំនួន១.៥៦៣នាក់ ក្នុងនោះស្ត្រីចំនួន២៨៥នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងការចាត់វិធានការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពខេត្ត។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ សរុបចំនួន៥៣៥.៩៣០.០០០រៀល ស្មើ១៧,៨៦% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន៣២៣.៧៣៨.៥០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បន្តអភិរក្សលើដំណាំចំនួន៣៣ប្រភេទ ដែលក្នុងនោះរួមមាន ស្រូវចំនួន៦.៦៤៥បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន៣២ប្រភេទមាន១.២៥៥បញ្ជីក/សំណាក សរុបទាំងអស់ចំនួន៧.៩០០បញ្ជីក/សំណាក

- ធ្វើពិសោធន៍ជ្រើសរើសស្រឡាយស្រូវនិងដំណាំផ្សេងៗចំនួន៦៨៣ស្រឡាយ ដើម្បីជ្រើសរើស៖ ១-ស្រឡាយស្រូវដែលមានអាយុកាលខ្លីជាង១០០ថ្ងៃ ២-ស្រឡាយស្រូវធន់ទ្រាំនឹងរាំងស្ងួត ៣-ស្រឡាយស្រូវធន់ទ្រាំនឹងទឹកជំនន់ ៤-ស្រឡាយស្រូវធន់ទ្រាំនឹងមមាចត្នោត ៥-ស្រឡាយស្រូវដែលមានតម្រូវការទឹកតិច ៦-ស្រឡាយស្រូវក្រអូប ៧-ស្រឡាយ-ស្រូវមានទិន្នផលខ្ពស់ និង៨-ស្រឡាយពោត សណ្តែក ល្ង ប៉េងប៉ោះ ឪឡឹក ម្ទេស មានទិន្នផលនិងគុណភាពល្អ

- ពិពិធកម្មដំណាំៈ បានធ្វើពិសោធន៍ចំនួន៥០ប្រភេទនៅ២២៦កន្លែង ស្វែងរកប្រភេទដំណាំ និងការប្រើប្រាស់ជីសមស្របសម្រាប់ធ្វើការដាំដុះក្នុងរដូវប្រាំងក្រោយពីដាំដុះដំណាំស្រូវរដូវវស្សារួច

- ការងារស្រាវជ្រាវបង្កើនផលិតភាពកសិកម្មៈ បានធ្វើពិសោធន៍ចំនួន២១ប្រភេទ នៅ២៧កន្លែង ដោយបានចុះកំណត់ទីតាំងពិសោធន៍ រៀបចំប្លង់ រៀបចំដីពិសោធន៍ ដាំដុះដំណាំពិសោធន៍ តាមដាន ស្រង់ទិន្នន័យ ប្រមូលសំណាកពិសោធន៍ និងបន្តដំណើរការពិសោធន៍នានា។ វាយតម្លៃម៉ាស៊ីនដាំគ្រាប់ធញ្ញជាតិបំពាក់ជាមួយត្រាក់ទ័រ វិភាគសំណាកដីចំនួន៦១សំណាក និងសំណាកទឹក១៣សំណាក ព្រមទាំងភ្ជួរបំបែកស្រទាប់បាតនង្គ័លរបស់ដីស្រែពិសោធន៍ចំនួន៣០ហិកតា

- ផ្តល់បទសម្ភាសន៍ក្នុងកម្មវិធីដៃគូកសិករ របស់វិទ្យុអេហ្វអឹម១០២ នៃមណ្ឌលព័ត៌មានស្ត្រី ក្រោមប្រធានបទពូជធន់ ដោយមានការចូលរួមសាកសួរតាមទូរស័ព្ទពីអ្នកស្តាប់ បានចំនួន០១លើក

- ដឹកនាំនិស្សិតស្រាវជ្រាវនិងសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានចំនួន១០នាក់ មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មព្រែកលៀប

- បើកវគ្គបណ្តុះបណ្តាលចំនួន០១វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន២៥នាក់

៩ L

- ចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងក្រៅប្រទេសចំនួន០៤លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីចូលរួមចំនួន០៧នាក់ ហើយមន្ត្រី និងនិយោជិត សរុបចំនួន៥រូបបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិតក្រៅប្រទេស

- ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦នេះ មានអ្នកចូលរួមសរុបចំនួន១១៣.១៥៣នាក់ គិតជាមធ្យមប្រមាណ១.៨៨៥នាក់ក្នុងមួយថ្ងៃ។

## ៧ ផ្នែកកសិ-ឧស្សាហកម្ម

- លើកគម្រោងទម្រង់ P3 និង P4 សម្រាប់ឆ្នាំ២០១៦ គម្រោងផែនការវជ្ជទេយ្យបុរេប្រទានឆ្នាំ២០១៦ គម្រោងផែនការលទ្ធកម្មសម្រាប់ឆ្នាំ២០១៦ និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ឆ្នាំ២០១៧-២០១៩

- កំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម

- សហការរៀបចំអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសហ្វីលីពីន និងក្រុមការងារសម្រាប់កិច្ចសហប្រតិបត្តិការលើការណ្ដុះបណ្ដាលស្ដីពីអនាម័យ និងភូតគាមអនាម័យ ជាមួយប្រទេសឥណ្ឌូនេស៊ី

- ចូលរួមសន្និសីទកសិធុរកិច្ច និងម្ហូបអាហារនៅអាស៊ី ការពង្រឹងភាពជាដៃគូរវាងឯកជន-សាធារណៈសម្រាប់ការប្រកួតប្រជែង កសិធុរកិច្ចប្រកបដោយនិរន្តរភាព នៅទីក្រុង Bandung ប្រទេសឥណ្ឌូនេស៊ី

- ចូលរួមប្រជុំស្ដីពីផែនការគម្រោងជាតិកសាងសមត្ថភាពក្នុងឧស្សាហកម្មចំណីអាហារនៃបណ្ដាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចនៃអាស៊ាននៅប្រទេសជប៉ុន។

## ៨ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន១.០៨១ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន៩៦២ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៣៣៩ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន២.៣៩៣ច្បាប់ ចេញប្រកាស សេចក្ដីសម្រេច និងសារាចរ សរុបចំនួន២៥៨ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន១៣១ច្បាប់ និងផ្ដល់ទិដ្ឋាការបេសកកម្មមន្ត្រីមន្ទីរកសិកម្មរាជធានី ខេត្តចំនួន២៥៦ច្បាប់ សរុបមនុស្ស១៦៧នាក់

- គណៈប្រតិភូក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននាំយកគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់ចុះសួរសុខទុក្ខ កងវរសេនាតូចការពារព្រំដែនលេខ៣០១ ប្រចាំខេត្តតាកែវ លេខ៣០២ ប្រចាំខេត្តកំពត និងលេខ៣០៣ ប្រចាំខេត្តកោះកុង ដើម្បីផ្សារភ្ជាប់ការចងសម្ព័ន្ធមេត្រីភាពរវាងសមរភូមិក្រោយ និងសមរភូមិមុខ

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៥៥៩នាក់ នារីចំនួន១.៣៨៣នាក់ ស្មើនឹង២១%រួមមាន៖
  + អង្គភាពថ្នាក់កណ្ដាលចំនួន៤.០២០នាក់ ក្នុងនោះនារីចំនួន៨១៣នាក់ ស្មើនឹង២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៣៩នាក់ ក្នុងនោះនារីចំនួន៥៧០នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន១៨នាក់ ក្នុងនោះសុំលាឈប់ពីការងារចំនួន៥នាក់ បោះបង់ការងារចំនួន១នាក់ និងមរណភាពចំនួន១២នាក់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន១៩នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន១៣នាក់ ច្បាប់ព្យាបាលជំងឺចំនួន៣នាក់ និងច្បាប់សម្រាកមាតុភាពចំនួន៣នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការសរុបចំនួន១៦នាក់ ក្នុងនោះ ផ្ទេរចេញក្រៅក្រសួងចំនួន១នាក់ ផ្ទេរចូលក្នុងក្រសួងចំនួន៣នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន១២នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៩២នាក់ និងចូលធ្វើការងារវិញចំនួន២៣នាក់

១១

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៤៣នាក់ និងក្នុងប្រទេសចំនួន២៦នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន១.០២៣នាក់ (ស្ត្រី៣៥៦នាក់) ក្នុងនោះមាននិស្សិតថ្នាក់បរិញ្ញា និងថ្នាក់បរិញ្ញារង ដោយបង្រៀនលើមុខជំនាញចំនួន៩(កសិកម្ម ជលផល វេជ្ជសាស្ត្រសត្វ ព្រៃឈើ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ វិស្វកម្មកសិកម្ម កសិឧស្សាហកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម)។ សាលាបានសហការជាមួយក្រុមហ៊ុនចិន សិក្សាកែលម្អកន្លែងពិសោធន៍ដើម្បីកាត់បន្ថយឧស្ម័នពុល។ កំពុងបន្តសាងសង់ផ្ទះកញ្ចក់ពិសោធន៍ចំនួន៣ សម្រាប់ការដាំដំណាំនិងបន្លែពិសោធន៍នៅក្នុងបរិវេណសាលាជាតិកសិកម្មព្រែកលៀប និងបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន (Japonica seeds) ព្រមទាំងពូជបន្លែពីជប៉ុន។ បានដឹកនាំនិស្សិតសាកវប្បកម្ម វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រជលផល វិទ្យាសាស្ត្រព្រៃឈើ ចុះទស្សនកិច្ចសិក្សាតាមខេត្តចំនួន៤ និងសហការជាមួយសុរិយោដីខេត្ត ស្រុក ឃុំ ដើម្បីវាស់វែងដីរបស់សាលាជាតិកសិកម្មព្រែកលៀប នៅស្រុកថ្គង ខេត្តកំពង់ស្ពឺ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៩០៨នាក់(ស្ត្រី៣៧០នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៥៩នាក់ (ស្ត្រី៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន៤៥៥នាក់(ស្ត្រី១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន១២៥នាក់(ស្ត្រី៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន៤៩នាក់ (ស្ត្រី១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន៣៨នាក់(ស្ត្រី១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន១១នាក់ (ស្ត្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

បញ្ជូននិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ និងនិស្សិតថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មឆ្នាំទី២ ទាំង៥ជំនាញឲ្យចុះទំនាក់ទំនងធ្វើកម្មសិក្សា ចងក្រងសារណាបទបញ្ចប់ការសិក្សានៅតាមមូលដ្ឋាន តាមមន្ទីរ ស្ថាប័នរដ្ឋ និងតាមបណ្តាអង្គការនានា ព្រមទាំងចុះធ្វើការពិសោធន៍ស្រាវជ្រាវលើទីវាលតាមមុខជំនាញនីមួយៗផងដែរ។ សាលាបានលើកគម្រោងស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទចំនួន១១គម្រោង និងបន្តលើកគម្រោងស្នើសុំថវិកាគាំទ្រពីអង្គការ DTRA ក្នុងការពង្រឹងការងារផលិតកម្មសត្វនិងវេជ្ជសាស្ត្រសត្វ ព្រមទាំងចាប់ផ្តើមពិសោធន៍លើការចិញ្ចឹមដង្កូវនាងព្រៃនៅក្នុងមន្ទីរពិសោធន៍សាលាជាតិកសិកម្មកំពង់ចាម។ បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីកៀរគររកជំនួយ ក្នុងនោះកំពុងសហការ ជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន១រូបទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន និងបញ្ជូននិស្សិតដែលបញ្ចប់ការសិក្សាទៅបន្តការសិក្សានៅឆ្នាំ២០១៦ ទំនាក់ទំនងជាមួយអង្គការ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់មន្ត្រីទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ។ សហការជាមួយសាកលវិទ្យាល័យ SHIN JU ប្រទេសជប៉ុនក្នុងការផ្តល់ពូជដង្កូវនាងព្រៃ ជួយបណ្តុះបណ្តាលនិងរៀបចំមន្ទីរពិសោធន៍បាណកសត្វ និងសហការជាមួយ DTRA (Defence Threat Reduction Agency) ដើម្បីបើកវគ្គអំពីអេពីឌេមីសាស្ត្រសត្វដល់និស្សិត និងមន្ត្រីជំនាញ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន៣.៩២៤នាក់(ស្រី១.១៨៧នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តម ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានសហការជាមួយ International Society of Enviromental and Rural Development (ISERD) ធ្វើសន្និសីទវិទ្យាសាស្ត្រអន្តរជាតិស្តីពីបរិស្ថាននិងអភិវឌ្ឍន៍ជនបទ និងសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិកូរ៉េ KOPIA ធ្វើសិក្ខាសាលាស្តីពីបច្ចេកទេសផលិតពូជដំឡូងបារាំង ជូនដល់និស្សិតនិងសាស្ត្រាចារ្យមហាវិទ្យាល័យពាក់ព័ន្ធ។ សាកលវិទ្យាល័យបានធ្វើពិធីប្រកាសដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាថ្មីរបស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ និងកសិឧស្សាហកម្ម និងបានសម្ពោធដាក់ឱ្យប្រើប្រាស់នូវមន្ទីរពិសោធន៍អតិសុខុមសាស្ត្រថ្មីមួយខ្នងមានពីរជាន់។ ក្រោមជំនួយរបស់ USAID សាកលវិទ្យាល័យបានចាប់ផ្តើមអនុវត្តន៍គម្រោងថ្មី ស្តីពីការបង្កើតឧបករណ៍កសិកម្មធុនតូចសមស្របសម្រាប់កសិករកម្ពុជា ដោយសហការជាមួយសាកលវិទ្យាល័យ North Carolina Agricultural and Technical State University និង University of Illinois និងបានរៀបចំធ្វើគម្រោងថ្មីមួយទៀតដើម្បីបង្កើត Center for Excellence on Sustainable Agriculture and Nutrition នៅក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដោយសហការជាមួយសាកលវិទ្យាល័យ Kansas State University នៅសហរដ្ឋអាមេរិក។ ដោយឡែក សាកលវិទ្យាល័យបានទទួលនិស្សិតបរទេសមកធ្វើកម្មសិក្សាចំនួន១៤នាក់ ក្នុងនោះមកពីសាកលវិទ្យាល័យ Kon Kuk ប្រទេសកូរ៉េ ជំនាញបសុពេទ្យ ១០នាក់ និងមកពីសាកលវិទ្យាល័យកូឡាលំពួរ ប្រទេសម៉ាឡេស៊ីចំនួន៤នាក់ ជំនាញព័ត៌មានវិទ្យា ព្រមទាំងបានសហការជាមួយនាយកដ្ឋានឧត្តមសិក្សា និងអង្គការSEARCA បានធ្វើសិក្ខាសាលាមួយស្តីពីភាពជាអ្នកដឹកនាំក្នុងឧត្តមសិក្សាកសិកម្មកម្ពុជា (LEAP Cambodia) ជូនដល់មន្ត្រីថ្នាក់ដឹកនាំនៃគ្រឹះស្ថានឧត្តមសិក្សានានា ដែលមានកម្មវិធីបណ្តុះបណ្តាលជំនាញកសិកម្មផងដែរ។ សហការជាមួយសាកលវិទ្យាល័យកាលីហ្វនីញ៉ាដេវីស បើកសន្និសីទវិទ្យាសាស្ត្រស្តីពីវិទ្យាសាស្ត្រសាកវប្បកម្មជូនដល់សាស្ត្រាចារ្យនិងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសហការយ៉ាងល្អជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម ក្នុងការប្រារព្ធធ្វើកម្មវិធីបរិច្ចាកឈាមដោយស្ម័គ្រចិត្ត ទទួលបានឈាមជាង៣០០ថ្លោក ។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងបានបញ្ចប់ជាស្ថាពរ ដោយសម្រេចបានលើសផែនការចំនួន ៧២.១២៦ហិកតា ស្មើនឹង១៧,២៨% នៃផែនការ ៤១៧.៣២៥ហ.ត។ រីឯការប្រមូលផលស្រូវរដូវប្រាំងសម្រេចបានចំនួន៤៨៩.៤៥៥ហ.ត ស្មើនឹង១០០%នៃផ្ទៃដីអនុវត្តបាន។ ចំពោះទិន្នផលស្រូវរដូវប្រាំងគឺទទួលបានតិចជាងឆ្នាំមុនចំនួន២១គ.ក្រ/ហ.ត។ បច្ចុប្បន្នប្រជាកសិករបានប្រមូលផលស្រូវរដូវប្រាំងចប់ជាស្ថាពរហើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែបន្តចាត់វិធានការជំរុញការអប់រំ ណែនាំនិងផ្សព្វផ្សាយដល់ប្រជាកសិករឲ្យធ្វើកសិកម្មចម្រុះបន្ថែមទៀតនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងថែទាំសុខភាពសត្វ ដើម្បីការពារជំងឺសត្វដែលអាចកើតឡើងជាយថាហេតុនៅក្នុងរដូវប្រាំងនេះ។ ក្រុមអន្តរាគមន៍របស់ក្រសួង ក៏បានបន្តចុះទប់ស្កាត់បទល្មើសចលនាសត្វយ៉ាងសកម្មផងដែរ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាពិសេស ចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងនៅតែបន្តផ្សព្វផ្សាយការអនុវត្តសារាចរណែនាំបន្ថែមទៀតអំពីការការពារទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងរដូវប្រាំងនេះ។ លើសពីនេះទៀត ការអភិវឌ្ឍន៍ធនធានមនុស្ស ការងារស្រាវជ្រាវផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែលម្អសេវាកម្មសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ(ដីសម្បទានសេដ្ឋកិច្ច សេវាកម្មផ្សេងៗតាមអនុវិស័យនីមួយៗ) កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជីកសិកម្ម-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ ២០១៦នេះ។

## IV- **ទិសដៅអនុវត្តបន្ត**

### **១ ផ្នែកដាំដុះ** :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតចង្រៃជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែន

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុ និងដាំដំណាំរួមផ្សំដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារៈសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្ត រៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បច្ចុប្បន្ននេះ ដោយមានការធ្លាក់ចុះនៃតម្លៃកៅស៊ូនៅលើទីផ្សារដែលធ្វើឲ្យម្ចាស់ច្បារពូជកៅស៊ូសម្រេចចិត្តដកចេញនូវច្បារពូជរបស់ខ្លួន ហើយកសិករមួយចំនួនទៀតបានកាប់ដើមកៅស៊ូចោលនិងដាំដំណាំផ្សេងៗជំនួសវិញ។ ក្រសួងបានជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

### **២ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺផ្តាសាយបក្សី ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនា

សត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល

- បន្តសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការរៀបចំប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ។

**៣ ផ្នែកព្រៃឈើ :**

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធ-សាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ចុះសិក្សាទីតាំងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំរុក្ខទិវា

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល :**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

១៤

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- ចុះសិក្សាទីតាំងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំទិវាមច្ឆជាតិ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ពិនិត្យវាយតម្លៃ លើការងារស្រាវជ្រាវពាក់ព័ន្ធនឹងការចិញ្ចឹមត្រីរ៉ស់ និងត្រីឆ្តោឱ្យបានសមស្របតាមវិធានការបច្ចេកទេសនិងនីតិវិធី

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារៈកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារៈកសិកម្ម

- បន្តពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារៈនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

១៥

- បន្តរៀបចំការធ្វើវិសោធនកម្មច្បាប់ស្ដីពីព្រៃឈើ និងច្បាប់ស្ដីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

- ចូលរួមអនុវត្តអនុក្រឹត្យលេខ៣៤អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងសមត្ថកិច្ចនិងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារនិងអភិរក្សព្រៃឈើនិងជលផល

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្ម មានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណ័កម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននិងនៅក្នុងតំបន់ផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ០២៣ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**



# ដំណាំឪឡឹក

## ១.ការរៀបចំដី

- ភ្ជួរដីជម្រៅ ២តឹកទៅ៣តឹក (២០សង់ទីម៉ែត្រទៅ៣០សង់ទីម៉ែត្រ)
- ភ្ជួររាស់ឱ្យបានម៉ដល្អ ហើយហាលដីពី១០ទៅ១៥ថ្ងៃមុនដាំ



### ផលប្រយោជន៍នៃភ្ជួររាស់ដី៖

- កំចាត់សត្វល្អិតចង្រៃ និងជំងឺនៅក្នុងដី
- ដីធូមានខ្យល់ចេញចូលបានល្អ ឫសដំណាំដុះលូតលាស់លឿន
- អាចរក្សាសំណើមដីបានល្អសម្រាប់ដំណាំលូតលាស់។

### ការលើករងដាំ

ដើម្បីឱ្យកូនឪឡឹកដុះលូតលាស់បានល្អបន្ទាប់ពីដាំហើយ កសិករត្រូវតែចាប់ផ្តើមលើករងឱ្យហើយទើបចាប់ផ្តើមបណ្តុះគ្រាប់ឪឡឹកនៅពេលជាមួយគ្នា។ របៀបធ្វើរងដាំឪឡឹកមានដូចខាងក្រោម៖

- ទទឹងរង ១ម៉ែត្រ
- បណ្តោយរងធ្វើតាមលទ្ធភាពតែមិនគួរលើសពី ២៥ម៉ែត្រទេ។ការលើករងវែងពេកយើងនឹងពិបាកចូលស្រោចទឹក ធ្វើស្មៅ ដាក់ជី បាញ់ថ្នាំនិងប្រមូលផល។
- លើករងនៅរដូវវស្សាកម្ពស់ពី ៣តឹក - ៥តឹក (៣០សង់ទីម៉ែត្រ-៥០សង់ទីម៉ែត្រ)
- ចន្លោះពីគុម្ពមួយទៅគុម្ពមួយទៀតមានប្រវែង ១ម៉ែត្រ
- ចន្លោះពីជួរទៅជួរមួយទៀតមានប្រវែង ៣ ម៉ែត្រ។



- ច្របល់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្ត ១ - ២ គីឡូក្រាមលាយជាមួយជី អិន ប៉េ កា (២០.២០.១៥) ចំនួន១០ក្រាម (១ស្លាបព្រាបាយ) សម្រាប់ឪឡឹក១ដើម ឬជី២០.២០.១៥ ចំនួន៣,៣គីឡូក្រាម សម្រាប់ផ្ទៃដី៥០០ម²។ ជៀសវាងដាក់ជីលាមកសត្វមិនទាន់ពុកផុយពីព្រោះវាបង្ក ឲ្យកូនឪឡឹករលួយ។



**ផលប្រយោជន៍នៃការដាក់ជីទ្រាប់បាតៈ**

- ដាក់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្តទ្រាប់បាត ជួយឱ្យដីធូ ឫសងាយដុះលូតលាស់
- ដាក់ជី អិន ប៉េ កា ទ្រាប់បាតគឺជំរុញកូនបន្លែទើបដាំរួចដុះលូតលាស់ឫសបានច្រើននិងរឹងមាំហើយ ដើម និងស្លឹកដុះបានឆាប់រហ័ស។

- ស្រោចទឹកលើរងដាំឱ្យជោគដល់ខាងក្នុងរងមុនគ្របប្លាស្ទិកឬចំបើង

**ផលប្រយោជន៍នៃការស្រោចទឹកមុនគ្របរងៈ**

- ដីត្រជាក់ កូនឪឡឹកងាយដុះលូតលាស់
- កាត់បន្ថយចំនួនកូនបន្លែសន្លប់ (អន់) ឬងាប់ក្រោយពីដាំហើយ ។



- គ្របរងដាំៈ បន្ទាប់ពីដាក់ជីទ្រាប់បាតនិងស្រោចទឹកតាមរងឱ្យជោគហើយកសិករអាចចាប់ផ្តើមគ្របរងបាន។ មានសម្ភារពីរប្រភេទអាចជ្រើសរើសយកមកគ្របរងដាំដំណាំឪឡឹកគឺៈ




ក. ប្លាស្ទិកគ្របដីនិងរបៀបប្រើ

យើងដំឡើងប្លាស្ទិកគ្របដីតាមរងដាំឪឡឹកនីមួយៗ តាមវិធីខាងក្រោមៈ

- ទាញដុំប្លាស្ទិកតាមបណ្តោយរងដោយយកស្រទាប់ពណ៌សដាក់ខាងលើនិងស្រទាប់ពណ៌ខ្មៅដាក់ខាងក្រោម
- ខ្ទាស់បន្ទះឬស្សីពីលើប្លាស្ទិកជាប់នឹងដីនៅគល់ និងចុងរងឱ្យញឹក។




- ទាញប្លាស្ទីកតាមបណ្តោយរង រួចយកបន្ទះឫស្សីខ្ទាស់តាមគែមរងប្រវែង ៣-៤តឹកសម្រាប់ខ្ទាស់មួយកន្លែង




- ប្រើខ្នាត់វាស់វែងចន្លោះគុម្ព
- ចុងខ្នាត់ចាក់ទំលុះប្លាស្ទីកសម្រាប់ដៅចោះរណ្តៅដាំកូនឪឡឹក
- ប្រវែងខ្នាត់អាស្រ័យតាមប្រភេទដំណាំ។




- ចោះរណ្តៅតាមខ្នាត់បានដៅទុក
- ប្រើកំប៉ុងក្តៅ( ដាក់រងើកភ្លើង )ឬឧបករណ៍ផ្សេងៗទៀតសម្រាប់ចោះរណ្តៅលើប្លាស្ទីក
- កំប៉ុងសម្រាប់ចោះគួរមានមុខកាត់១តឹកកន្លះ។ បើមុខកាត់វាតូចកម្តៅងាយឆ្លូលពីក្រោមប្លាស្ទីកធ្វើឱ្យស្លោកឬងាប់កូនឪឡឹកបន្ទាប់ពីដាំហើយ។

ខ. ការគ្របចំបើងនិងរបៀបប្រើ



គ្របចំបើងកម្រាស់ពី០,៦តឹក ទៅ១តឹក (៦សង់ទីម៉ែត្រទៅ១០សង់ទីម៉ែត្រ)

អត្ថប្រយោជន៍នៃការប្រើចំបើង៖

វាផ្តល់ផលប្រយោជន៍ច្រើននៅរដូវប្រាំង

- រក្សាសំណើមដីបានយូរ
- កាត់បន្ថយការហូរច្រោះដីរងដំណាំ និងជួយដីធូរបន្ទាប់ពីចំបើងរលួយ
- ដីរងមិនហាប់ (ដីនៅធូរ)ធ្វើឱ្យឫសដំណាំងាយដុះបានលឿន
- កាត់បន្ថយការបាត់បង់ជី
- កាត់បន្ថយការដុះស្មៅ

## ២. ការធ្វើរោងបណ្តុះកូនឪឡឹក

ការបណ្តុះកូនឪឡឹកមិនបានត្រឹមត្រូវតាមបច្ចេកទេស នោះកសិករនិងមានការខាតបង់ជាច្រើនដូចជា៖

- ខាតបង់គ្រាប់ដោយសារគ្រាប់មិនដុះ និងមានចំនួនកូនឪឡឹកងាប់ច្រើន
- កសិករត្រូវការពេលវេលាថៃទាំច្រើន និងចំណាយទិញជីច្រើនសម្រាប់បប៉ុនឪឡឹកបន្ទាប់ពីដាំហើយ
- កសិករនិងមិនអាចប្រមូលផលឬប្រមូលផលបានតិចដោយសារកូនឪឡឹកក្រិនឬមានជំងឺ
- កូនឪឡឹកមានសុខភាពខ្សោយ ងាយរងការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺ នៅក្រោយពេលដាំហើយ

ដើម្បីទទួលបានទិន្នផលខ្ពស់ ត្រូវដាំតែកូនឪឡឹកណាដែលមានសុខភាពល្អហើយថ្លោស។ វិធីផលិតកូនឪឡឹកបានល្អ៖

- ត្រូវសង់រោងនៅកន្លែងណាដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និងមិននៅក្បែរដើមឈើ
- ដំបូលត្រូវមានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់មកកូនបន្លែ។ ជៀសវាងធ្វើដំបូលរានកូនបន្លែពីស្លឹកដូង គង់ពណ៌ខៀវ ឬពីសម្ភារផ្សេងទៀតដែលមិនអាចឱ្យពន្លឺចូលរួច ពីព្រោះវានិងធ្វើឱ្យគ្រាប់បន្លែដុះយឺត ដើមកូនឪឡឹកទន់ ឬងាយរលួយគល់កូនឪឡឹក ។
- ដំបូលរោងបណ្តុះកូនមានកម្ពស់ពី២ ម៉ែត្រ ទៅ២ម៉ែត្រកន្លះ ដែលមានដំបូលគ្របសំណាញ់កាត់ពន្លឺនៅរដូវប្រាំង និងដំបូលប្លាស្ទីកពណ៌សនៅរដូវវស្សា
- រានបណ្តុះគួរមានកម្ពស់កន្លះម៉ែត្រ (០,៥ម)ពីដី ហើយរាននេះអាចធ្វើពីឬស្សី ក្តារ និងសម្ភារដំទៃទៀតក៏បាន។ តែមិនត្រូវក្រាលដី បាវក្រចៅ ឬ សម្ភារដែលជក់ទឹកទ្រាប់ពីក្រោមថាសបណ្តុះ ឬកន្ទោងបណ្តុះទេ វាអាចនាំមកជាមួយនូវជំងឺ និងធ្វើឱ្យឫសចាក់ចុះហួសកន្ទោងបណ្តុះ។
- គ្របសំណាញ់សត្វល្អិតពណ៌ស។



រានបណ្ដុះកូនបន្លែសម្រាប់រដូវប្រាំង



រានបណ្ដុះកូនបន្លែសម្រាប់រដូវវស្សា

**ផលប្រយោជន៍នៃការធ្វើរានបណ្ដុះ៖**

- ការពារកូនដំណាំ បានពីការឆ្លងជំងឺ និងសត្វល្អិតចង្រៃ
- បញ្ចៀសការរលួយកូននៅរដូវវស្សា និងក្រិននៅរដូវក្ដៅ
- កាត់បន្ថយការឆ្លងជំងឺហូរតាមដីមកកូនឪឡឹក

## ៤. ការបណ្ដុះគ្រាប់

### ការរៀបចំដីបណ្ដុះ

យកដីមានជីជាតិ ១ភាគលាយជាមួយជីលាមកគោស្ងួត ឬ ជីកំប៉ុស្ដិ៍ ២ភាគ និងផេះអង្កាមពី ២ ទៅ ៣ ភាគ អាស្រ័យតាមប្រភេទដី (ផេះអង្កាមត្រូវត្រាំទឹករយៈពេល ពី២ ទៅ ៣យប់)។ យកល្បាយដែលបានលាយច្របល់ហើយទៅលីងឬចំហុយរហូតក្ដៅសព្វ តែត្រូវឱ្យដីនោះនៅសើមតិចៗទើបមិនខូចគុណភាពដី។



ផលប្រយោជន៍នៃការរៀបចំដីសម្រាប់បណ្តុះគឺ ៖

- គ្រាប់ងាយដុះឫស ហើយដុះលូតលាស់ល្អ
- កូនបន្លែមានជីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមដើម ស្លឹក ឫសលូតលាស់បានល្អ
- សម្លាប់មេរោគ(ជំងឺ) ដែលបង្កឱ្យកូនបន្លែរលួយ
- សម្លាប់គ្រាប់ស្មៅចង្រៃដែលដុះដណ្តើមយកជីពីកូនបន្លែ
- សម្លាប់ពងសត្វល្អិត និង សត្វល្អិតចង្រៃនៅក្នុងដីដែលបំផ្លាញគ្រាប់បន្លែ

ការបណ្តុះគ្រាប់ឪឡឹក

- យកដីបណ្តុះបានលីង ឬចំហុយហើយដាក់ក្នុងកន្ទោង ឬ ថាសបណ្តុះតែជៀសវាងសង្កត់ដីនោះ







- ស្រោចទឹកឲ្យជោគដីបណ្តុះទើបយកទៅដាក់ក្នុងរោងបណ្តុះ



- ដាក់គ្រាប់ឪឡឹក១គ្រាប់ក្នុង១ប្រលោះថាសបណ្តុះ ឬ១កន្ទោងរួចយកដីរោយលុបពីលើគ្រាប់។ មិនត្រូវកប់គ្រាប់ជ្រៅនោះទេ វាអាចធ្វើឱ្យគ្រាប់រលួយ ឬដុះយឺត។

របៀបថែទាំកូនឪឡឹក

- ស្រោចទឹកកូនឪឡឹកឱ្យជោគនៅពេលព្រឹក និងពេលថ្ងៃ ។ មិនគួរស្រោចទឹកនៅពេលល្ងាចទេ វានឹងធ្វើឱ្យដីសើមពេលយប់ បណ្ដាលឱ្យគ្រាប់សើមជ្រុល ឫសកូនឪឡឹកសើមពេក រួចហើយធ្វើឱ្យវាងាយរលួយយ៉ាងឆាប់រហ័ស។

## ៥ . ការដាំកូនឪឡឹក

- កូនឪឡឹកមានអាយុ៧ថ្ងៃ (មានស្លឹក២ពេញលេញ) បន្ទាប់ពីដុះគ្រាប់ហើយយើងអាចយកកូននោះទៅដាំបាន។ បើយើងដាំកូនឪឡឹកដែលមានអាយុចាស់ជាងនេះ យើងនិងខាតផលប្រយោជន៍ដូចជា៖
  - កូនឪឡឹកខ្សោយ(ស្គមៗ)
  - ដើមឪឡឹកដុះលូតលាស់យឺត
  - កាត់បន្ថយទិន្នផល
- ត្រូវពង្រឹងកូនឪឡឹកមុនពេលដកយកទៅដាំ (បន្ទាប់ពីកូនឪឡឹកដុះបាន២ទៅ៣ថ្ងៃត្រូវបើកដំបូលរោងឱ្យត្រូវពន្លឺថ្ងៃ ដោយជៀសវាងពេលថ្ងៃត្រង់) និងបន្ថយការស្រោចទឹករហូតដល់ពេលយកកូនទៅដាំ។



ការពង្រឹងកូនឪឡឹកត្រឹមត្រូវនឹងទទួលបានអត្ថប្រយោជន៍ដូចជា៖

- ដើមកូនឪឡឹករឹងមាំល្អ
- កូនឪឡឹកមិនចាញ់អាកាសធាតុខាងក្រៅ
- មានការដាច់ឫសតិចតួចបំផុតនៅពេលដកកូនយកទៅដាំ
- កូនឪឡឹកមិនសន្លប់(អន់)ឬមានតិចតួចបំផុតបន្ទាប់ពីដាំហើយ

- ស្រោចទឹកកូនចំនួន២-៣ម៉ោងមុនដកយកដាំទើបដីមិនបែក និងដាំវានៅពេលរសៀល
- ស្រោចនិងបញ្ចូលទឹកឱ្យជោគរងដាំនៅពេលព្រឹក។ បើយើងបានស្រោចទឹកឱ្យបានសព្វដីនៅពេលព្រឹកបែបនេះ គឺដីក្នុងរងមានភាពសើមបានយូរ ជួយកាត់បន្ថយការភាយកម្ដៅពីរងដែលគ្របប្លាស្ទីក រីឯកូនឪឡឹកងាប់មានចំនួនតិចតួចបំផុតបន្ទាប់ពីដាំហើយ ជាពិសេសយើងងាយស្រួលដើរទៅតាមចន្លោះរងក្នុងពេលដាំ។





របៀបដកកូនឪឡឹកចេញពីថាសបណ្ដុះ
- យកម្រាមដៃច្របាច់បាតថាសឬរុញដីក្នុងរន្ធនៅបាតថាសទៅលើ
- ដៃម្ខាងទៀតទាញគល់កូនឪឡឹកឡើង។



របៀបដាំកូនឪឡឹក
- ដាំកូនឪឡឹកត្រឹមដីកំណើត ទើបកូនដុះបានល្អ
- កប់វាក្នុងរណ្ដៅជ្រៅលិចបាត់ដីកំណើតនោះ កូនឪឡឹកលូតលាស់យឺតឬងាប់បន្ទាប់ពីដាំហើយ។



## ៦. ការថែទាំ

### ៦.១ ការប្រើប្រាស់ជី

ការជ្រើសរើសប្រភេទជីសម្រាប់ដាក់ឪឡឹកឱ្យត្រូវតាមពេលវេលាក្នុងដំណាក់កាលលូតលាស់នីមួយៗបានត្រឹមត្រូវជាមួយបរិមាណដែលដំណាំត្រូវការនោះ យើងពិតជាចំណាយថវិកាទិញជីអស់តិច ហើយឪឡឹកនឹងផ្ដល់ទិន្នផលបានខ្ពស់។

ក. ប្រភេទជីនិងពេលវេលាប្រើប្រាស់ជី

ពូជឪឡឹកបង្កាត់ (អីប្រ៊ីដ) ត្រូវដាក់ជីបំប៉នឱ្យបានទៀងទាត់ ទើបវាអាចផ្ដល់ផ្លែ ផ្កាបានច្រើន។ ជាការប្រសើរគួរដាក់ជីបំប៉នរៀងរាល់៧ទៅ១៥ថ្ងៃម្ដងបន្ទាប់ពីដាំកូនឪឡឹកហើយតែវាអាស្រ័យទៅតាមរដូវកាលដាំដុះ ប្រភេទដី និងស្ថានភាពលូតលាស់ឪឡឹកផងដែរ។ ឧទាហរណ៍ប្រភេទដីខ្សាច់ត្រូវដាក់ជីឱ្យបានញឹកញាប់តែដាក់បរិមាណតិចដោយសារប្រភេទដីនេះងាយហូរច្រោះជី ទឹកលឿន ដូច្នេះបើយើងដាក់ជីច្រើននោះវានិងបាត់បង់ដោយសារហូរតាមទឹក ហើយដំណាំស្រូបយកបានតិចតួច ។

ជៀសវាងជ្រើសរើសជីដែលខូចគុណភាព (មានកកជាដុំៗឬសើម)និងដាក់ជីនៅពេលថ្ងៃក្ដៅទៅលើបន្លែព្រោះថាកត្តាទាំងនេះនិងបង្កឱ្យឪឡឹកងាប់បាន។

### បរិមាណនិងពេលដាក់ជីលើដំណាំឪឡឹកលើផ្ទៃដី៥០០ម៉ែត្រការ៉េ

| ចំនួនថ្ងៃបន្ទាប់ពីដាំ | ប្រភេទជី | ចំនួនជី/ដើម | ចំនួនដើម | ជីសរុប(គ.ក្រ) | ទីតាំងកប់ជី (ចម្ងាយពីគល់) |
|---|---|---|---|---|---|
| ទ្រាប់បាត | ជី ២០-២០-១៥ | ១៥ក្រាម (១ស្លាបព្រាបាយ) | ២២០ | ៣,៣ | ពង្រាយជី & ច្របល់ |
| ១០ ថ្ងៃ | ជី ២០-២០-១៥ | ១០ក្រាម (១ស្លាបព្រាបាយ) | ២២០ | ២,២ | ១០សង់ទីម៉ែត្រ |
| | ជី៤៦-០-០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ២០ ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ១០សង់ទីម៉ែត្រ |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ៣០ ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥សង់ទីម៉ែត្រ |
| | ជី ០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ៤០ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥សង់ទីម៉ែត្រ |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ៥០ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥សង់ទីម៉ែត្រ |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |

### ប្រការជៀសវាងនៅពេលដាក់ជី

**គ្រប់ប្រភេទជីគឺមិនគ្រាប់ទាំងអស់ ៖**

- មិនត្រូវយកជី ដាក់នៅក្បែរគល់ឪឡឹកទេជីទាំងនោះ និងបង្កឱ្យឆ្លូលក្ដៅ ធ្វើឱ្យវាងាប់បានយ៉ាងលឿន
- មិនត្រូវយកជី ដាក់នៅលើដីចោលទេការដាក់ជីបែបនេះមានការខាតថវិកាជាច្រើន ព្រោះថាដំណាំពុំអាចស្រូបជីនោះបាន ដោយសារជីទាំងនោះបានបាត់បង់ដោយសារកម្ដៅថ្ងៃ និងខ្យល់ហួតអស់។



## ខ.របៀបដាក់ជីក្នុងរងគ្របប្លាស្ទីកគ្របដីនិងចំបើង




- យើងត្រូវយកឈើមកបុកជារណ្ដៅពីលើរងគ្របចំបើង ប្លាស្ទីកជម្រៅប្រមាណជា៥សង់ទីម៉ែត្រ (កន្លះតឹក) នៅសងខាងរណ្ដៅឪឡឹកសម្រាប់ដាក់ជី
- ជម្រៅរណ្ដៅដាក់ជីត្រូវតែរាក់ល្មម ទើបឫសដំណាំអាចចាប់យកជីនោះបាន។

## ៦.២ ការស្រោចទឹក

- ត្រូវស្រោចទឹកនៅពេលព្រឹក ដោយបញ្ចូលទឹកតាមចន្លោះរង។ បើស្រោចទឹកពេលថ្ងៃត្រង់ ឬ ពេលល្ងាច (ដីសើមនៅពេលយប់) អាចធ្វើឱ្យឪឡឹកមានបញ្ហាដូចជា រលួយ ឬ រលាកដើម។
- ត្រូវស្រោចទឹកឱ្យបានទៀងទាត់ មិនត្រូវឱ្យដីស្ងួតជាពិសេសបន្ទាប់ពីដាំកូនហើយ ។ ពីព្រោះកូនឪឡឹកត្រូវការទឹក ជីសម្រាប់ដុះលូតលាស់ ឫស ដើម ស្លឹក ផ្កា ផ្លែ។
- បើពិនិត្យឃើញនៅក្បែគល់ឪឡឹកស្ងួត(មិនអាចលុញជាដុំមូលបាន)ត្រូវស្រោចទឹកបន្ថែម។ បើដីនៅក្បែរគល់ឪឡឹកសើមខ្លាំង (ច្របាច់ដីមានទឹកហៀរតាមម្រាមដៃ) មិនត្រូវដាក់ទឹកបន្ថែមទេ។ ទឹកដក់ច្រើនពេកវាអាចឱ្យរលួយឫសឬងាប់ដើម។





ចង្អូររងសម្រាប់បញ្ចូលទឹក



៦.៣ ការជំរះស្មៅចង្រៃ

ត្រូវជម្រះស្មៅក្នុងចម្ការឱ្យបានស្អាត ទោះបីជារងគ្របចំបើង ឬ ប្លាស្ទិកគ្របដីក៏ដោយ ។ ស្មៅនៅតាមចន្លោះរងត្រូវដកចេញ ពីព្រោះវាជាជម្រកសត្វល្អិតចង្រៃបំផ្លាញឪឡឹក ហើយក៏ជាភ្នាក់ងារចំលងជំងឺដល់ឪឡឹកផងដែរ។

៦.៤ ការតាក់តែងខ្នែង

ការកាត់ខ្នែងឪឡឹក ត្រូវធ្វើនៅពេលវាមានស្លឹក (ថ្នាំង) ទី៥ ។ នៅពេលនោះ យើងត្រូវកាត់ត្រួយនៅស្លឹកទី ៦ ហើយវានឹងបែកចេញខ្នែងពីស្លឹកថ្នាំងដែលបានកាត់នោះ។ ក្នុងចំណោម ត្រួយខ្នែងដែលបែកអាច យើងត្រូវទុកតែត្រួយចំនួន ២ ទៅ ៣ (គឺ ត្រួយណា ដែលលូតលាស់ថ្លោសល្អ)បើសិនជាមានផ្កានៅចន្លោះស្លឹកចេញពីដើមមេទៅ ចំនួន ១២ ស្លឹក (ថ្នាំងដើមខ្នែង) ត្រូវបេះផ្កាញី ចោលទាំងអស់។ រក្សាផ្កា និង ក្តិបនៅចន្លោះពីស្លឹក/ថ្នាំង ទី១៣ ឡើងទៅប៉ុណ្ណោះ ។ ក្នុងខ្នែងនីមួយៗ ទុកតែក្តិបមួយណាដែលថ្លោសជាងគេ ឱ្យទៅជាផ្លែធំ។




ដើមមេកាត់(ក្រៀវ)ត្រួយ នៅស្លឹក(ថ្នាំង)ទី ៥



## ៧. ជំងឺ និងសត្វល្អិតចង្រៃ

### ៧. ១. ជំងឺដំណាំឪឡឹក

ក. ជំងឺដោនីមីជូ (Downy Mildew)

ជំងឺនេះ ច្រើនចាប់ផ្តើមរាតត្បាតពីស្លឹកឪឡឹកចាស់ៗមុន។ យើងអាចសង្កេតមើលឃើញនៅលើស្លឹកនោះមានចំណុចរាងជ្រុងពណ៌លឿងខ្ចី និងវិវត្តទៅរកពណ៌បៃតងប្រផេះលែតពីចំណុចជ្រុងតូចៗទៅធំ។ នៅដំណាក់កាលជំងឺរាតត្បាតខ្លាំងចំណុចរាងជ្រុងប្រែពណ៌ត្នោត ហើយស្លឹកស្ងួត។



ជំងឺនេះកើតឡើងនៅពេលណាមានអ័ព្ទ ធ្លាក់សន្សើមច្រើន មានភ្លៀងធ្លាក់ញឹកញាប់ បង្កឲ្យស្លឹកឪឡឹកសើមរយៈពេល៥ទៅ៦ម៉ោងក្នុងអំឡុងពេលដែលមានសីតុណ្ហភាពចុះមកត្រឹម២៥ទៅ៣០អងសាសេ នោះវាជាពេលវេលាដ៏ល្អសម្រាប់ជំងឺនេះដុះលូតលាស់បានយ៉ាងឆាប់រហ័ស។

ជំងឺនេះធ្វើឱ្យដើមឪឡឹកលូតលាស់មិនល្អ ដើមក្រិន ទិន្នផលថយចុះ។

**វិធីការពារជំងឺដោនីមីដ្ឌូ (Downy Mildew)**

- ជ្រើសរើសពូជដាំធន់និងជំងឺនេះ
- ត្រូវដាំពីគុម្ពមួយទៅគុម្ពមួយឱ្យរង្វើល ជួយមានពន្លឺ ខ្យល់ចេញចូលគ្រប់គ្រាន់ ស្លឹករហ័សស្ងួត
- មិនគួរស្រោចទឹកពីលើស្លឹក
- ជៀសវាងស្រោចទឹកពេលល្ងាច
- សំអាតដំណាំជម្រករបស់ជំងឺនេះចេញពីចម្ការ
- សំអាតកាកសំណល់បន្លែផ្សេងៗបន្ទាប់ពីប្រមូលផលហើយ
- មិនគួរដាំឪឡឹកនៅជិតចម្ការបន្លែដែលមានកើតជំងឺប្រភេទនេះទេ
- បាញ់ថ្នាំកំចាត់ផ្សិតរវាងពី៥ទៅ១០ថ្ងៃម្ដងដូចជាថ្នាំមេតាឡាក់ស៊ីល (Metalaxyl) ថ្នាំប្រូក្លរ៉េស (Prochlorraz) ឬថ្នាំហ្វូស៊ីលអាល់ (Fosetyl-Al)។ ថ្នាំនេះត្រូវបាញ់ឆ្លាស់គ្នាលាយជាមួយទឹកស្អិត ហើយបាញ់ពីក្រោមនិងលើផ្ទៃស្លឹកនៅពេលល្ងាច។

**វិធីកំចាត់ជំងឺដោនីមីដ្ឌូ (Downy Mildew)**

- កាត់ស្លឹកដែលមានជំងឺដាក់ថង់យកទៅកប់ចោល។ ការកាត់ស្លឹកមានជំងឺទម្លាក់ចោលក្នុងចម្ការ ស្ព័រជំងឺនេះនិងបាចសាចឆ្លងទៅដំណាំកាន់តែខ្លាំងជាងមុន។
- ជ្រើសរើសប្រភេទថ្នាំណាមួយបាញ់ឆ្លាស់គ្នាពីខាងលើនិងក្រោមស្លឹក ដូចជាថ្នាំក្លរ៉ូថាឡូនីល (Chlorothalonil) ថ្នាំម៉ង់កូសែប(Mancozeb) ថ្នាំប្រូប៉ាម៉ូកាប (Propamocarb) ឬថ្នាំទ្រីហ្វរហ្សីស្ត្រូប៊ីន (Trifloxystrobin)។ ថ្នាំនេះបាញ់មានប្រសិទ្ធភាពគួរលាយជាមួយទឹកស្អិត ហើយបាញ់នៅពេលល្ងាច។

**៧.២ សត្វល្អិតចង្រៃ**

ក. ទ្រីប(Trips)

ត្រូវពិនិត្យ វែកឆែករកមើល សត្វទ្រីបឱ្យបានញឹកញាប់ ជាពិសេសនៅផ្នែកត្រួយឪឡឹក។ ទ្រីប គឺជាមូលហេតុធ្វើឱ្យត្រួយដំណាំឈប់លូតលាស់។



**វិធីការពារ**

- គួរដាំដោយប្រើគម្របប្លាស្ទីក
- ត្រូវបាញ់ទឹកស្រោចឱ្យចំត្រួយដំណាំ (បើមានលទ្ធភាព១ថ្ងៃ ២ដង)

**វិធីកំចាត់**

- បន្ថយការប្រើប្រាស់ជី អ៊ុយរ៉េ (៤៦-0-0)





- ប្រើថ្នាំពុលកសិកម្មឆ្លាស់គ្នាណាមួយលាយជាមួយទឹកស្អិតដូចជាថ្នាំអាបាមិចទីន (Abamectin) ឌីណូតឺហ្វុយរង់ (Dinotefuran) អ៊ីមីដាក្លប្រីត (Imidacloprid) ថ្យាមេតូហ្សាម (Thiamethoxam) ឬថ្នាំឡាំដាស៊ីឡូស្រីន(Lambdacyhalothrin)។

ខ. ចៃ(Aprids)



ត្រូវពិនិត្យរកមើលចៃ ឱ្យបានញឹកញាប់ នៅផ្នែកខាងក្រោមស្លឹក ។ ចៃជាភ្នាក់ងារចម្លងជំងឺវីរុស ដែលបណ្តាលឱ្យស្លឹក និងត្រួយឪឡឹក រួញ។

វិធីការពារ

- ដាំឪឡឹកឱ្យរង្វើល
- កំចាត់ស្មៅនិងដំណាំជម្រកទ្រីបចេញពីក្នុងចម្ការ
- ស្រោចថ្នាំថ្យាមេថូហ្សាមនៅនិងកូនឪឡឹកមុន ពេលយកវាដាំ
- កប់ចោលកាកសំណល់ឪឡឹកនៅសល់បន្ទាប់ពីប្រមូលផលហើយ

វិធានការកំចាត់

- កាត់ស្លឹកដែលមានចៃយកទៅកប់-ដុតចោល ឬ ញោចចៃដោយដៃ
- ជ្រើសរើសថ្នាំកំចាត់សត្វល្អិតណាមួយប្រើឆ្លាស់គ្នាលាយនិងទឹកស្អិតហើយបាញ់នៅពេលត្រជាក់ដូចជាៈថ្នាំអាបាមិចទីន (Abamectin) ថ្នាំឌីណូតឺហ្វូរ៉ង់ (Dinotefuran) ឬថ្នាំហ្វីប្រូនីល (Fipronil) ថ្នាំឡាំដាស៊ីហាឡូស្រ៊ីន(Lamdacyhalothrin) ។

## ៨. ការប្រមូលផល



- ឪឡឹកអាចប្រមូលផលបានបន្ទាប់ពីដាំកូនបានរយៈពេល ពី៥០ ទៅ ៦០ថ្ងៃ តែវាអាស្រ័យទៅតាមប្រភេទពូជ
- ត្រូវបេះផ្លែឪឡឹកឱ្យមានទងជាប់ផ្លែ ដើម្បីរក្សាគុណភាពផ្លែ
- ត្រូវប្រើកាំបិតសម្រាប់កាត់ទងឪឡឹក
- មិនត្រូវទាញកន្ត្រាក់ផ្លែផ្តាច់ចេញពីដើមឡើយ។

# ឧបករណ៍ដាំស្រូវជាជួរសម្រាប់បំពាក់គោយន្ត

រៀបចំដោយ: នាយកដ្ឋានគ្រឿងយន្តកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

## ១. មុខងារ :

ឧបករណ៍នេះ មានតួនាទី សម្រប់ឆូតជាចង្អូរ បន្ទាប់មកគ្រាប់ធ្លាក់រោយ ជាជួរទៅក្នុងចង្អូរនោះហើយ បន្ទាប់មកទៀតទើបក្បៀរកៀដីលប់គ្រាប់ស្រូវ តាមជួរនីមួយៗ។

## ២. គ្រឿងបង្គុំទូទៅ :

១. តៅដាក់ពូជស្រូវ
២. ប៊ូឡុងរឺស័រសម្រាប់កែរសម្រួលកម្លាំងកៀដីលប់គ្រាប់។
៣.តង់ខ៉ូរកែសម្រួល
៤. អ័ក្សសម្រាប់ភ្ជាប់ទៅគោយន្ត
៥. រ៉ូឡូបែងចែកនិងទម្លាក់គ្រាប់ពូជ
៦. ថាសឆូតចង្អូរ
៧. ប៊ូឡុងទប់កង់បន្លា
៨. ដៃនិងហ្វាំងសម្រាប់លើក និង ផ្ដាច់ប្រព័ន្ធមេកានិច
បង្វិលទម្លាក់គ្រាប់ នៅពេលបត់ក្បាលងារ
៩. កង់បន្លាសម្រាប់បញ្ជូនកម្លាំង ទៅបង្វិលរ៉ូឡូទម្លាក់
និងបែងចែកគ្រាប់
១០. ក្បៀរកៀដីលប់គ្រាប់
១១. កង់ទ្រនិងកំណត់ជម្រៅឆូត

## ៣. លក្ខណៈបច្ចេកទេស :

- ទំហំទូទៅ ក x ទ x ប = ៧៧០ x ១១១០ x ១៥៤០
- ចំណុះតៅដាក់ស្រូវពូជ = ២០-៣០គីឡូក្រាម
- កំលាំងអូសទាញ = គោយន្តពី៨-៩សេះ
- ទម្ងន់ឧបករណ៍ដាំ =១៥០គីឡូក្រាម
- ទិន្នផលការងារ = ១,៥-២,៥ហិកតា/ថ្ងៃ
- ចន្លោះជួរ = ពី២០០-២៥០ម.ម
- ចំនួនជួរ = ៦ជួរ
- ប្រសិទ្ធភាពការងារ = ៧៥%។

## ៤. ការប្រើប្រាស់ :

បន្ទាប់ពីបានរៀបចំភ្ជួររាស់ដីស្រែបានម៉ត់ និងរាបស្មើរួចហើយយើងត្រូវអនុវត្តដូចតទៅ:

- ភ្ជាប់ឧបករណ៍ដាំពីក្រោយគោយន្តដោយកន្លា
- ដាក់គ្រាប់ពូជទៅក្នុងតៅនៃឧបករណ៍ដាំ
- បញ្ឆេះម៉ាស៊ីនគោយន្តហើយចល័តទីទៅដាក់នៅទីតាំងដែលត្រូវដាំ ពេលចល័តទីត្រូវចាប់លើកដៃលេខ៨ឱ្យថ្គក់ទៅនឹងគន្លឹះស្វ័យប្រវត្ត ទើបលែងដៃចេញ
- មុននឹងដាំ ត្រូវទុកក្បាលងារទាំងសងខាងនៃទទឹងស្រែចាប់ពី២ទៅ៣ងារសម្រាប់ទុកបត់គោយន្ត
- មុននឹងដាំ(មុននឹងបញ្ជារគោយន្តឱ្យទៅមុខ) ត្រូវចាប់ដៃនិងហ្វាំ(លេខ៨)បង្ហើបឡើងលើបន្តិចដើម្បីគន្លឹះស្វ័យប្រវត្តរបូតចេញពីទំពួក បន្ទាប់មកយើងទម្លាក់ដៃនោះចុះក្រោមដើម្បីឱ្យកង់បន្លាបានប៉ះដី
- បញ្ជារឱ្យគោយន្តទៅមុខត្រង់ រហូតដល់ក្បាលងាដែលបានកំណត់ បន្ទាប់មកដៃម្ខាង់ចាបដៃ(លេខ



- លើករហូតទំពួកត្រូវបានថ្លក់ជាប់ទៅនឹងគន្លឹះស្វ័យ ប្រវត្ត ទើបលែងដៃចេញ ហើយបត់គោយន្តប្រឡប់មកក្រោយវិញតាមគន្លងដែលយើងកំណត់ធ្វើរបៀបនេះទៅមកៗរហូតអស់ដីដែលត្រូវដាំ
- យើងអាចធ្វើការកែសម្រួលជម្រៅដាំបាន ដោយកែសម្រួលកង់លេខ១១
- យើអាចធ្វើការកែសម្រួលក្នុងការកំណត់បរិមាណពូជទៅតាមតម្រូវការជាក់ស្ដែង
- ក្រោពីដាំតាមបណ្ដោយស្រែរួចហើយ យើងដាំទទឹងក្បាលងារនូវដីដែលនៅសេសល់។

## ៥. ការថែទាំ:

- ក្រោយពេលប្រើប្រាស់រួចត្រូវលាងទឹកឱ្យស្អាត និងទុកដាក់នៅទីដែលមានសវត្ថិភាព និងជៀសវៀងកុំឱ្យក្មេងៗទៅលេងនាំឱ្យមានគ្រោះថ្នាក់ជាយថាហេតុ
- ត្រូវឧស្សាហ៍ត្រួតពិនិត្យដុំឆូតចង្អូរ និងដុំនែកង់ទ្របើធូរឬរលុងត្រូវរឹតវាឱ្យល្មម និងត្រូវដាក់ខ្លាញ់គោទៅក្នុងដុំប៉ាដាងទាំងនោះឱ្យបានគ្រប់គ្រាន់៕

---

# វិធីសាស្ត្រថ្លឹងស៊ូប៉ាប់ត្រាក់ទ័រ MODEL MTZ-800/820

រៀបចំដោយ: នាយកដ្ឋានគ្រឿងយន្តកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

## ១. ការងារប្រតិបត្តិ:

- រក្សាចលករក្នុងសីតុណ្ហភាពត្រជាក់
- ដោះគម្របក្បាលគុយឡាស់
- រឹតបណ្ដឹងប៊ូឡុងអ័ក្សដងរ៉ៃក ដោយប្រើម៉ូម៉ង់ក្នុងចន្លោះ ៦០-៩០Nm (ប្រើប្រាស់ប្រភេទសោរមាននាឡិកាស្ទង់ )
- ពិស្ដុងនៃស៊ីឡាំងទី១ និងស៊ូប៉ាប់លេខ១( ចាប់រាប់ពីមុខផ្លិតធុងទឹកត្រាក់ទ័រ )
- កំណត់គំលាតស៊ូប៉ាប់ខ្យល់ និង ស៊ូបាប់ភ្លើងក្នុងចន្លោះ ( 0.២០-0.៣៥ mm )



- កំណត់លំដាប់ស៊ីឡាំង ចាប់រាប់ពីមុខផ្លិតធុងទឹក
- ស៊ូប៉ាប់ខ្យល់ > ស៊ូប៉ាប់ភ្លើង
- ស៊ូប៉ាប់នៅជាប់បំពង់បឺតខ្យល់ ជាស៊ូប៉ាប់ខ្យល់
- ស៊ូប៉ាប់នៅជាប់បំពង់ផ្សែង ជាស៊ូប៉ាប់ភ្លើង

## ២. វិធីសាស្ត្រថ្លឹងស៊ូប៉ាប់:

- **វិធីថ្លឹងតាមលំដាប់ឆេះម៉ាស៊ីន ១ ៣ ៤ ២**

ក- ចាប់ផ្ដើមបង្វិលប៉ូលីវិលឡីប្រីកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្ដុងនៃស៊ីឡាំងទី១ឡើងដល់ចំណុចលើ បំផុត ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរបិទជិតនៃស៊ីឡាំងទី១ យើងចាប់ផ្ដើមថ្លឹងស៊ូប៉ាប់លេខ ១ និង ២ ។

ខ- បន្តបង្វិលប៉ូលីវិលឡីប្រីកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្ដុងនៃស៊ីឡាំងទី៣ឡើងដល់ចំណុចលើបំផុត ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរបិទជិតនៃ ស៊ីឡាំងទី៣ រួចយើងចាប់ផ្ដើមថ្លឹងស៊ូប៉ាប់លេខ ៥ និង ៦ ។

គ- បន្តបង្វិលប៉ូលីវិលឡឺប្រើកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្តុងនៃស៊ីឡាំងទី៤ ឡើងដល់ចំណុចលើបំផុត ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរបិទជិតនៃ ស៊ីឡាំងទី៤ រួចយើងចាប់ផ្ដើមថ្លឹងស៊ូប៉ាប់លេខ ៧ និង ៨ ។

ឃ- បន្តបង្វិលប៉ូលីវិលឡឺប្រើកាំងតាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្តុងនៃស៊ីឡាំងទី២ឡើងដល់ចំណុចលើបំផុត ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរបិទជិតនៃ ស៊ីឡាំងទី២ រួចយើងចាប់ផ្ដើមថ្លឹង ស៊ូប៉ាប់លេខ ៣ និង ៤ ។

### ☞ វិធីថ្លឹងតាមពិស្តុងឡើងនិងចុះគូស្មើគ្នា ១ ៤ ២ ៣

ក- ចាប់ផ្ដើមបង្វិលប៉ូលីវិលឡឺប្រើកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្តុងនៃស៊ីឡាំងទី១ឡើងរហូតពិនិត្យឃើញ ស៊ូប៉ាប់ភ្លើងលេខ១បិទ និងស៊ូប៉ាប់ខ្យល់លេខ២ចាប់ផ្ដើមបើក បន្ទាប់មកចាប់ថ្លឹងស៊ូប៉ាប់លេខ៧ និង ៨ របស់ស៊ីឡាំងទី៤ រួចយើងបន្តបង្វិលប៉ូលីវិលឡឺប្រើកាំងរហូតដល់ពិនិត្យឃើញស៊ូប៉ាប់ភ្លើងលេខ ៨ បិទ និងស៊ូប៉ាប់ខ្យល់លេខ ៧ ចាប់ផ្ដើមបើក បន្ទាប់មកចាប់ថ្លឹងស៊ូប៉ាប់លេខ១ និង២ របស់ស៊ីឡាំងទី ១។

ខ- ចាប់ផ្ដើមបង្វិលប៉ូលីវិលឡឺប្រើកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនរហូតដល់ពិស្តុងនៃស៊ីឡាំងទី២ ឡើងរហូតពិនិត្យ ឃើញស៊ូប៉ាប់ភ្លើងលេខ៤ បិទ និងស៊ូប៉ាប់ខ្យល់លេខ៣ ចាប់ផ្ដើមបើក បន្ទាប់មកចាប់ថ្លឹងស៊ូប៉ាប់លេខ ៥ និង ៦ របស់ស៊ី ឡាំងទី៣ រួចយើងបន្តបង្វិលប៉ូលីវិលឡឺប្រើកាំងរហូតដល់ពិនិត្យឃើញស៊ូប៉ាប់ភ្លើងលេខ៥ បិទ និងស៊ូប៉ាប់ខ្យល់លេខ ៦ ចាប់ផ្ដើមបើក បន្ទាប់មកចាប់ថ្លឹងស៊ូប៉ាប់លេខ ៣ និង ៤ របស់ស៊ីឡាំងទី ២ ។

## ម៉ាស៊ីនត្រាក់ទ័រ MTZ-800/820







### ☞ បង្វិលប៉ូលីវិលឡឺប្រើកាំងមុំ ៣៦០០ (ថ្លឹងបានស៊ូប៉ាប់ ៤ ដើម)

ក- ចាប់ផ្ដើមបង្វិលប៉ូលីវិលឡឺប្រើកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីន រហូតដល់ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរនៃស៊ីឡាំងទី១ ឡើងដល់ចំណុច ស៊ូប៉ាប់ខ្យល់ចាប់ផ្ដើមបើកនិងស៊ូប៉ាប់ភ្លើងបិត (OVERLAP) បន្ទាប់មកថ្លឹងស៊ូប៉ាប់លេខ ៤, ៦, ៧ និង ៨ ។

ខ- បន្តបង្វិលប៉ូលីវិលឡឺប្រើកាំង តាមទិសដៅវង្វិលឆេះរបស់ម៉ាស៊ីនឱ្យបានមួយជុំ ឬ ៣៦០០ រហូតដល់ពិនិត្យឃើញស៊ូប៉ាប់ទាំងពីរនៃស៊ីឡាំងទី៤ ឡើងដល់ចំណុចស៊ូប៉ាប់ខ្យល់ចាប់ផ្ដើមបើក និងស៊ូប៉ាប់ភ្លើងបិត (OVERLAP) បន្ទាប់មកថ្លឹង ស៊ូប៉ាប់លេខ ១, ២, ៣ និង ៥ ហើយរឹតបណ្ដឹងឲ្យបានត្រឹមត្រូវ ។

# ការសម្រួលស៊ូប៉ាប់







# ការបិទគំរបក្រោយការកែសម្រួល







- ដាក់គម្រប រួចមួលខ្មៅបញ្ចូល
- ពិនិត្យមើល ចុងក្រោយនូវខ្មៅ ដែលដាក់ រួចរឹតបន្តឹង
- បញ្ឆេះសាកល្បង



# បច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ

## បន្តពីលេខ ៥៦

រៀបចំដោយ: នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

**បញ្ហារលាក់ស្បូន**

- ចាក់ប្រូស្ដាគ្លង់ឌីន ដូចជាលុយតាលីស ៥សេសេ (Lutalyse) ដោយចាក់ពីរដង ហើយការចាក់លើកទី ២ ធ្វើឡើងក្នុងរយពេល ១១-១៤ថ្ងៃក្រោយលើកទី ១ ។
- ចាក់អង់ទីប៊ីយ៉ូទីក ដូចជាតេត្រាស៊ីគ្លីន (Tetracycline) ឬទីឡូស៊ីន (Tylosine) ៥ថ្ងៃជាប់គ្នា ។

**បាមានបញ្ហា**

- នៅពេលម្ចាស់សត្វប្រឈមមុខនឹងបញ្ហាដាក់មិនជាប់នេះហើយកំណត់ថា មកពីបា ដូចនេះគេមិនត្រូវប្រើបានេះទៀតឡើយ ។

### ៦.៣. បញ្ហាហូរខ្ទុះតាមផ្លូវបន្តពូជ

ក្រោយពេលកើតកូន ស្បូនមានមេរោគជាច្រើនចូលតាមផ្លូវបន្តពូជ ។ ជាធម្មតា ២-៣ថ្ងៃក្រោយ ស្បូនអាចធ្វើការបញ្ចេញមេរោគទាំងនោះមកក្រៅ និងការពារកុំឱ្យមានបញ្ហាបង្កជំងឺដល់វា ។



*ចាំបាច់ត្រូវពិនិត្យទ្វារបន្តពូជដោយផ្ទាល់ ដើម្បីអង្កេតលើបញ្ហាហូរខ្ទុះ*

**ការព្យាបាល**

- ចាក់ប្រូស្ដាគ្លង់ឌីន ដូចជាលុយតាលីស ៥សេសេ (Lutalyse) ដោយចាក់ពីរដង ហើយការចាក់លើកទី ២ ធ្វើឡើងក្នុងរយពេល ១១-១៤ថ្ងៃក្រោយលើក ទី ១ ។
- ចាក់អង់ទីប៊ីយ៉ូទីក ដូចជាតេត្រាស៊ីគ្លីន (Tetracycline) ឬទីឡូស៊ីន (Tylosine) ៥ថ្ងៃជាប់គ្នា ។

**ការការពារ**

ក្រោយមេគោកើតកូនបាន ២៤ម៉ោង ត្រូវចាក់ប្រូស្ដាគ្លង់ឌីន (Prostaglandin) ម្ដង ហើយត្រូវចាក់ម្ដងទៀតនៅ ២សប្ដាហ៍ក្រោយ ។




### ៦.៤. បញ្ហារលូតកូន

**ជំងឺប្រុយសែលឡូស៊ីស (Brucellosis)**

នៅប្រទេសកម្ពុជាយើងពុំទាន់រកឃើញប្រភេទជំងឺប្រុយសែលឡូស៊ីសនេះនៅឡើយ ។ ជំងឺនេះអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់មនុស្ស ។

គោឆ្លងជំងឺនេះដោយសារលេបចូលនូវបាក់តេរីដែលមានច្រើននៅក្នុងកូនរលូត ភ្នាសស្មើង ឬទឹករំអិលខ្ទុះហូរចេញពីស្បូន ។

ពេលបាក់តេរីចេញមកមជ្ឈដ្ឋានខាងក្រៅ វាអាចធ្វើការចម្លងទៅមនុស្ស ហើយបង្កជាបញ្ហាធ្ងន់ធ្ងរ ដូចជាគ្រុនក្តៅលោះពេល ឬមិនទៀងម្តងក្តៅ ម្តងត្រជាក់ ។

**ការព្យាបាល**

- ប្រើតេត្រាស៊ីគ្លីន (OTC) ឬយកល្អចាក់ក្លរតេត្រាស៊ីគ្លីន (Chlortetracycline) រយពេល ២ សប្តាហ៍ ។

**ជំងឺឡិបតូស្ពីរ៉ូស៊ីស (Leptospirosis)**

សត្វកណ្តុរ គឺជាអ្នកផ្ទុកជំងឺឡិបតូស្ពីរ៉ូស៊ីសហើយធ្វើការចម្លងតាមរយៈទឹកនោមរបស់វា ។

**ក. រោគសញ្ញា**

- រលូតកូន ពិសេសលើមេកូនដំបូង
- កូនស្លាប់ក្នុងពោះ ឬកូនកើតមិនគ្រប់ខែ ឬកូនកើតមកខ្សោយ
- ចំពោះកូនគោ មានរោគសញ្ញាគ្រុនក្តៅ មិនស៊ីចំណី ពិបាកដង្ហើម ខ័ណ្ឌលឿង នោមឈាម និងស្លេកស្លាំង ។

**ខ. ការព្យាបាល**

- តេត្រាស៊ីគ្លីន (Tetracycline)
- ឬប៉ង់ស្ទ្រិប ឬប៉េនីឌីអេចអេស (Peni DHS)

**ជំងឺសាល់ម៉ូណែលឡូស៊ីស (Salmonellosis)**

**ក. រោគសញ្ញា**

- រលូតកូន
- ប្រើទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa)
- អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin)

**៦.៥. បញ្ហាពិបាកកើតកូន**

**ការជួយសង្គ្រោះពេលជួបបញ្ហាពិបាកកើតកូន**

នៅប្រទេសកម្ពុជាយើង កូនគោកើតមកកម្រថ្លោសជ្រុលណាស់ តែមេគោត្រូវការជំនួយ ព្រោះកូនគោស្ថិតនៅទីតាំងខុសប្រក្រតី ។ តែមេគោដែលបង្កាត់ដោយសិប្បនិម្មិតជាមួយពូជសាន់តា កូនអាចថ្លោស ។

សម្រាប់មេគោ សម្រាលកូនរួចរាល់ជាធម្មតាចំណាយពេល ២ម៉ោង ក្រោយពេលបែកទឹកភ្លោះ ។ ប្រសិនបើលើសពីនេះ គេត្រូវលូកដៃចូលតាមប្រដាប់បន្តពូជ ដើម្បីកំណត់ពីបញ្ហានេះឱ្យបានច្បាស់លាស់ ។



*ថង់ទឹកភ្លោះចេញមកក្រៅ*



*សុកមានសភាពពណ៌លឿង*



*ក្បាលបត់ទៅក្រោយ*

**បញ្ហាច្រើនជួបប្រទះ**

- កូនក្នុងស្បូនដែលមានទីតាំងធម្មតាគឺជើងមុខទាំងពីរហុចទៅមុខ ហើយផ្នែកខាងស្តាំលើកឡើងរួមជាមួយចង្កាផ្តេកលើជើងមុខ ។
- តែជួនកាលកូនគោបង្វិលមកផ្លូវបង្កើតក្នុងទីតាំងខុសប្រក្រតីដូចជា បញ្ច្រាស ឬគូថមកមុន ជើងមុខមួយ ឬពីរបត់មកក្រោយ ក្បាលបត់ទៅក្រោយ ។

**បញ្ហាខុសប្រក្រតី ដែលគេជួបប្រទះ**

**ការលូកដៃ**

ត្រូវសម្អាតដៃឱ្យស្អាត ដោយកាត់ក្រចកឱ្យខ្លី រួចលូកដៃថ្នមៗចូលទៅក្នុងប្រដាប់បន្តពូជ ដើម្បីឱ្យដឹងច្បាស់ពីសភាពរបស់កូនគោ សភាពក្បាលឬគូថចេញមកមុន ទីតាំងជើង ។

ដើម្បីឱ្យដឹងថាកូនគោរស់ ឬស្លាប់ ត្រូវចុច អណ្តាតកូនគោ ប្រសិនបើនៅរស់កូនគោនឹងប្រឹងទាញអណ្តាតចូលវិញ ។



*ទីតាំងកូនធម្មតា*



*កូនបញ្ច្រាស*



*គូថចេញមកមុន*

**ការជួយកូនគោក្រោយពេលជួយបង្កើតរួច**

- ជូតសំអាតទឹករំអិលនៅមាត់ និងទ្រូង
- ជូតខ្លួនវាឱ្យស្ងួត ដើម្បីជួយសម្រួលឱ្យកូនគោដកដង្ហើម
- ត្រូវយកចំបើងចាក់ត្បាររន្ធច្រមុះ ឬ ដាក់វាឱ្យព្យួរសំយ៉ុងក្បាលចុះក្រោម ហើយទះ វាថ្នមៗ
- ប្រើអ៊ីយ៉ូឌីន ដើម្បីសំអាត និងសម្លាប់មេរោគនៅទងផ្ចិត



*លូកដៃថ្នមៗតាមប្រដាប់បន្តពូជ*

- ចាក់ប្រូស្តាគ្លង់ឌីន ដូចជាលុយតាលីស ៥សេ



*ជើងមុខមួយបត់ទៅក្រោយ*



*ប្រើខ្សែចងជើងមុខលើក្រចក*



*ជួយទាញជើងចេញ*



*ទាញកូនគោចេញមកក្រៅ*

- ប្រសិនបើមេគោមិនព្រមលិទ្ធកូន ត្រូវយកអំបិលមកលាបលើខ្លួនវា
- ត្រូវពិនិត្យមើលលើការបៅទឹកដោះដំបូង ។

**បញ្ហាសុកមិនធ្លាក់**

- ប្រសិនបើកើតកូនរួចបាន ២៤ម៉ោង សុកនៅតែមិនធ្លាក់ នោះវានឹងធ្វើឱ្យ មានបញ្ហា ដូចជា

**ការជួយបង្កើតកូន**

ស្បូនមិនរួញទៅ រកសភាពដើម និងមានការឆ្លងមេរោគ

- ២៤ម៉ោងក្រោយពេលកើត សុកនៅតែមិនធ្លាក់ ប្រសិនបើអាច ត្រូវទាញយកផ្នែកដែលធំចេញដោយទ្បេក មិនត្រូវយកដៃទាញយកសុកខាងក្នុងទាំងអស់ចេញនោះទេ ។



*ជូតសំអាតកូនគោ*

**ការព្យាបាល**

- ចាក់តេត្រាស៊ីគ្លីន (Tetracycline)



*ការទាញយកសុកចេញ*

សេ (Lutalyse) ដោយចាក់ពីរដង ហើយការចាក់លើកទី ២ នៅ ១៥ថ្ងៃក្រោយទៀត ។

**វិធានការបន្ទាន់**

- យកសុកនៅសល់ចេញ ហើយលាងសំអាតស្បូន
- ពេលរុញស្បូនចូលខាងក្នុងត្រូវចំទីតាំងល្អហើយត្រូវចាក់ថ្នាំអុកស៊ីតុកស៊ីន ៤សេសេ
- ដេរទ្វារបន្តពូជទុកចោលរយៈពេលបីថ្ងៃ
- ចាក់តេត្រាស៊ីគ្លីន (Tetracycline) រយៈពេលបីថ្ងៃ ។

### ៧. ជំងឺលាសដោះ (Mastitis)

ជំងឺលាសដោះបង្កឡើងដោយមេរោគចូលតាមមុខរបួស ឬរន្ធទឹកដោះ ហើយធ្វើឱ្យ៖

- ការផលិតទឹកដោះថយចុះ ធ្វើឱ្យកូនគោមិនអាចបៅបានគ្រប់គ្រាន់
- ទឹកដោះមានគុណភាពអន់ ធ្វើឱ្យកូនគោរាគធ្ងន់ធ្ងរ
- ក្នុងករណីស្រួចស្រាវ ធ្វើឱ្យមេគោឈឺធ្ងន់ធ្ងរ

**ការសម្គាល់លើបញ្ហាលាសដោះ**

- មេគោមិនឱ្យកូនបៅ ព្រោះវាមានការឈឺចាប់ខ្លាំង
- ទឹកដោះមិនស្អាត ពណ៌ខុសពីធម្មតា
- កន្សោមដោះមានសភាពក្តៅ ឈឺចាប់ និងហើម
- មេគោឈប់ស៊ីចំណី និងគ្រុនក្តៅ

**ការព្យាបាល**

ការព្យាបាលទទួលជោគជ័យទៅបានលុះត្រាតែ



*ក្បាលដោះពីរមានបញ្ហា*

ធ្វើការព្យាបាលឱ្យបានឆាប់ និងត្រឹមត្រូវដូចជា៖

- ចាក់អុកស៊ីតុកស៊ីន (Ocytocin) ដើម្បីសម្រួលឱ្យកន្សោមដោះកន្ត្រាក់បញ្ចេញទឹកដោះ
- ច្របាច់បញ្ចេញទឹកដោះកខ្វក់ចេញពីកន្សោមដោះ ដោយច្របាច់ ២ដងក្នុង ១ថ្ងៃ
- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) ហើយអាចចាក់បន្ថែមតេត្រាស៊ីគ្លីន (Tetracycline) ផងដែរ ក្នុងរយៈបីថ្ងៃ
- ប្រសិនបើកន្សោមដោះឡើងរឹង ត្រូវចាក់ដិចស្សាមេតាហ្សូន (Dexametsone) ឬ តុលហ្វេឌីន (Tolfedine) ម្តង ដើម្បីបន្ថយការរលាក

### ៨. បញ្ហា និងជំងឺលើជើង (Moving)

#### ៨.១. បញ្ហាដំបៅស្អុយនៅជើង

ដំបៅស្អុយនៅជើង ជាបញ្ហាធ្វើឱ្យដំបៅរលួយនៅចង្វែកជើង បណ្តាលមកពីការធ្វើការក្នុងភក់ ។

**ក. រោគសញ្ញា**

- ពិបាកដើរ ពិការជើង ជាទូទៅច្រើនកើតតែលើជើងម្ខាង
- ហើមនៅជើង
- របែកស្បែកនៅចង្វែកជើង ហើយអាចឃើញមានខ្ទុះតិចៗ

**ខ. ការព្យាបាល**

- ចាក់ស៊ុលហ្វា ៣៣ (Sulfa 33) តាម សរសៃវ៉ែន មានប្រសិទ្ធភាពបំផុត ។
- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) រយៈពេលបីថ្ងៃ ។

#### ៨.២. បញ្ហារលាកស្បែកនៅជិតក្រចកជើង

ជាបញ្ហាមួយដែលធ្វើឱ្យដាច់ស្បែកនៅចន្លោះក្រចកជើង និងខ្នែងជើង ហើយធ្វើឱ្យគោមានសភាពមិនស្រួល ថយកម្លាំងធ្វើការងារ ។ បញ្ហានេះច្រើនកើតឡើងនៅពេលគោធ្វើការនៅក្នុងភក់ ។

បញ្ហារលាកស្បែកនៅគល់ក្រចកជើងនេះ ងាយស្រួលក្លាយទៅជាដំបៅស្អុយរលួយនៅក្រចកជើង ។

**ការព្យាបាល**

- ប្រើហ្វ័រម៉ាលីន ៣% (Formaline 3%) ពីរ



*ស្បែករហែក និងហើមជើង*

ដងក្នុងមួយថ្ងៃ ប្រើរយៈពេលបីថ្ងៃ

- ប្រើទង់ដែងស៊ុលហ្វាត ៥% (Copper Sulfate 5%) ។

**៨.៣. រលាកសន្លាក់**

មូលហេតុដែលបង្កឲ្យរលាកសន្លាក់មាន ៖

**ក. បង្កឡើងដោយ**

- របួសនៅសន្លាក់
- ជំងឺឆ្លង (ប្រ៊ុយសែលឡូស៊ីស មីកូប្លាស្មា)
- គោបំបៅកូនដែលមានបញ្ហាខ្វះខាតនូវកាល់ស្យូម ផូស្វ័រ និងជីវជាតិផ្សេងទៀត

**ខ. រោគសញ្ញា**

- ពិការ
- ពេលស្ទាបនៅសន្លាក់ គោមានការឈឺចាប់ខ្លាំង
- មិនសូវស៊ីចំណី

**គ. ការព្យាបាល**

- ប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin) ឬទីឡូស៊ីន (Tylosin) ដោយប្រើរយៈពេលពី ៥-៧ថ្ងៃ
- ហ្វេនីប៊ុយតាហ្សូន (Phenybutazone)
- ឬឌីពីរ៉ូន (Dypirone) មានអាណាហ្សាំង (Analgine)
- ឬកាល់ម៉ាហ្សាំង (Calmalgine)
- ឬតុលហ្វេឌីន (Tolfedine)

**ក្រចកជើងដុះវែង**



*សន្ទាក់ហើម*

- ក្រចកជើងដុះជាប្រចាំ
- ជួនកាលក្រចកដុះលឿន ហើយវែងជ្រុល
- ធ្វើឱ្យគោនៅមិនសុខ និងបង្កឱ្យវាពិការ

**ការព្យាបាល**

- កាត់ក្រចកដែលដុះវែងនេះចេញ ដោយកាត់បន្តិចម្ដងៗ រហូតដល់ស្មើសាច់
- បន្ទាប់ពីកាត់រួច ត្រូវយកដែកឆាប មករូសតែមក្រចកឱ្យស្មើ ។

**របួសដោយសារវត្ថុផ្សេងៗកប់ក្នុងដី**

វត្ថុផ្សេងៗទៀតដូចជាដុំថ្ម អំបែងដប/កែវ ឬដែកគោល អាចមានបង្កប់ក្នុងដី ។

**ក. រោគសញ្ញា**

- គោដើររាងខ្ញើចជើងបន្តិច



*សភាពក្រចកមុនពេលកាត់*

- សភាពរបស់វាអាស្រ័យទៅលើទីតាំងដែលដីជ្រាបចូល ឬសភាព របួស

**ខ. ការព្យាបាល**

- ដកវត្ថុដែលមុតនោះចេញ
- លាងក្រចកជើងទាំងមូលជាមួយ អ៊ីត្រូសែនពីរ៉ុកស៊ីដ (Hydrogen Peroxyde)



*សភាពក្រចកមុនពេលកាត់*



*ត្រូវពិនិត្យមើលដីជាប់នៅបាតជើង*

- ចាក់អាម៉ុកស៊ីលីន អិលអេ (Amoxillin LA)

## ៩. បញ្ហាខ្វិន

### ៩.១. ខ្វិនដោយសារទន់ចង្កេះ

បណ្ដាលមកពីការចាក់ថ្នាំខុសទីតាំង ជាពិសេសពេលប្រើថ្នាំដែលមានសកម្មភាពបានយូរ ។

**ការព្យាបាល**

- ចាក់ដិចហ្សាមេតាហ្សូន (Dexamethasone) រៀងរាល់ ២ថ្ងៃម្ដង ដោយប្រើរយៈពេល ២ សប្ដាហ៍ ។

### ៩.២. ដេកយូរ

- គោទន់/ស្គមស្រពន់ជើងមុខ ដោយសារគោស្គម និងខ្សោយ មិនអាចក្រោកឈរយូរថ្ងៃ
- សាច់ដុំមិនអាចការពារប្រព័ន្ធប្រសាទបាន ហើយប្រព័ន្ធប្រសាទរងការខូចខាតនៅពេលគោដេកតែមួយចំហៀងខ្លួន ដោយមិនអាចប្រែខ្លួនបាននោះ ។

**ការព្យាបាល**

- ជួយគោដែលទន់ខ្សោយឱ្យក្រោកឈរ ២ដងក្នុងមួយថ្ងៃ



*កុំចាក់ថ្នាំដែលមានសកម្មភាពបានយូរ នៅសាច់ដុំត្រគៀក*

- ចាក់ថ្នាំជួយលើកកម្លាំងដូចជាការ៉ាស៊ីល (Carasil) អេម៉ាតូប៉ង់បេ ១២ (Hematopan B12)
- យកចំបើងមកជុសជូតនៅស្មា និងភ្លៅ ៕

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលជួបសវនាការជាមួយ លោកស្រី Nina Brandstrup តំណាងអង្គការ (FAO) នៅទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ជំនួបសវនាការជាមួយ ឯកឧត្ដម William A Heidt ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅកម្ពុជានិងសហការី នៅទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.




ជំនួបសវនាការជាមួយ លោក Azadine Beschaouch តំណាងអង្គការ UNESCO ប្រចាំនៅកម្ពុជា នៅទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





ជំនួបសវនការជាមួយគណៈប្រតិភូអញ្ជើញមកពីប្រទេសជប៉ុន
នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





ជំនួបសវនការជាមួយឯកឧត្តម George Edgar, ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា
និងសហការី នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





សកម្មភាពក្នុងពិធីផ្ទេរតំណែងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ





ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាព ក្នុងពិធីប្រកាសមុខតំណែងថ្នាក់ប្រធាននាយកដ្ឋាន និងបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកសិកម្ម






ឯកឧត្តម **ឌឹម គឹមសា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុង សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីភាពស៊ាំនឹងការប្រើប្រាស់ថ្នាំប្រឆាំងមេរោគ





ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញផ្តល់សម្ភារសម្រាប់ ដំណើរការកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)





ឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជួបសវនាការជាមួយ
គណៈប្រតិភូប្រទេសឥណ្ឌា នៅទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





ឯកឧត្តម **គង់ ចាន់** និង **ឯកឧត្តម គិត សេង** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្នុងពិធីទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី១០៥ ឆ្នាំ២០១៦ ក្រោមប្រធានបទ " វិនិយោគលើសមភាព
យេនឌ័រដើម្បីកិច្ចអភិវឌ្ឍប្រកបដោយចីរភាព "





ឯកឧត្តម **ចាន់ សុវណ្ណ** លោកជំទាវ **ម៉ុម ថានី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អញ្ជើញចូលរួមក្នុងពិធីបុណ្យដារលាន ប្រារព្ធធ្វើនៅភូមិស្ពកវាជ ឃុំអណ្ដូងស្នាយ ស្រុករលាប្អៀរ



# សារកំណាព្យ

# កិច្ចការព្រៃឈើ


បទកាកគតិ

និពន្ធដោយ ៖ លោក លិ វុឌ្ឍី

( រដ្ឋបាលព្រៃឈើ )


**បន្តពីទស្សនាវដ្តីសមិទ្ធផលកសិកម្ម ប្រចាំឆ្នាំ២០១៥**

| | | |
|---|---|---|
| សត្វស៊ីដង្កូវ | ជួយបន្ថយនូវ | ការរេចស្លឹកទង |
| ជួយត្រួយរុក្ខជាតិ | ឱ្យលូតឱ្យគង់ | ឱ្យបាត់ឱ្យបង់ |
| | សត្វល្អិតចង្រៃ ។ | |
| រៀនគ្រប់រៀនគ្រង | រៀនច្បាប់ទៀតផង | រៀនកែរៀនច្នៃ |
| តួនាទីភារកិច្ច | ស្ថាប័នច្រើនក្រៃ | ពាក់ព័ន្ធដទៃ |
| | ចូលរួមស្ថាបនា ។ | |
| បញ្ញត្តិព្រៃឈើ | គ្រប់គ្រងនឹងធ្វើ | ចំណាត់ចាត់ការ |
| ជាព្រៃផ្តល់ផល | ការពារផងណា | ប្រភេទគ្រួសារ |
| | ព្រៃសហគមន៍ ។ | |
| ព្រៃដាំធម្មជាតិ | គិតឈ្លកគិតឆ្លៀត | បង្កើនផលធំ |
| ចំណូលជូនរដ្ឋ | សេដ្ឋកិច្ចរឹងមាំ | ទាំងជាតិទាំងក្រុម |
| | ទាំងមីងទាំងអ៊ុំ ។ | |
| ចេះចាត់ព្រៃហើយ | គេមិនកន្តើយ | រៀនប្រមូលផ្តុំ |
| បែងចែកភោគផល | ជូនរដ្ឋឬក្រុម | រៀនបែងរៀនផ្តុំ |
| | សួយសារអាករ ។ | |
| រៀនកម្រិត ច្បាប់ | រៀនចងរៀនចាប់ | រៀនអាក្រក់ល្អ |
| បទល្មើសព្រៃឈើ | អំពើស្មោះស | សកម្មសាទរ |
| | ប្រើព្រៃបានយូរ ។ | |
| មេព្រៃខិតខំ | ចូកចែវប្រមុំ | ប្រឹងប្រែងតស៊ូ |
| ការពារដីព្រៃ | មិនខ្ជិលរអ៊ូរ | តាមគោលនយោ |
| | បាយរាជរដ្ឋា ។ | |

**សូមរងចាំអានបន្តនៅទស្សនាវដ្តីកសិកម្ម ប្រចាំត្រីមាសទី២ ឆ្នាំ២០១៦**








# ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម